អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2012, 15:48

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី៩៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល *(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់ *(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

លោកស្រី បេនី យេ *(Ms. Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្ទើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ស សៀក (TCW-609) | ខ្មែរ |
| លោក គឹម វុន (TCW-338) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ស សៀក ហៅ ស៊ីម** (TCW-609)

សួរដោយលោក ហ្សាស្ពើ ប៉ៅ ផ្ដើមពី៖ ........ ទំព័រ ៣

សួរដោយលោក សុន អរុណ ផ្ដើមពី៖ ........ ទំព័រ ៨

សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី៖ ........ ទំព័រ ១១

សួរដោយលោក គង់ សំអុន ផ្ដើមពី៖ ........ ទំព័រ ១៧

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី៖ ........ ទំព័រ ២៣

**ការសួរសំណួរទៅសាក្សី៖ លោក គីម វុន ហៅ ឆោម** (TCW-338)

សួរដោយលោកប្រធានអង្គជំនុំជម្រះ ផ្ដើមពី៖ ........ ទំព័រ ៣១

សួរដោយលោក វ៉េង ហ៊ត់ ផ្ដើមពី៖ ........ ទំព័រ ៣៦

សួរដោយលោក ឃីត រេយ៍ន័រ ផ្ដើមពី៖ ........ ទំព័រ ៤៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ កិច្ចនីតិវិធីនឹងប្រព្រឹត្តទៅដោយការតាំងសំណួរដេញដោលចំពោះសាក្សី ស សៀក ដោយក្រុមមេធាវីការពារក្ដី ដែលនឹងចាប់ផ្ដើមពីក្រុមមេធាវីការពារក្ដីលោក នួន ជា មុនមេធាវីពីរក្រុមទៀត។ តែមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះបានកោះអញ្ជើញឲ្យចូលរួមនៅក្នុងសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិ តាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំណែកឯសាក្សីបម្រុង ដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់ពីសាក្សី ស សៀក គឺសាក្សីដែលមានរហស្សនាមTCW-338។ សាក្សីរូបនេះនឹងមានវត្តមាននៅបន្ទប់រង់ចាំនៅម៉ោងដប់ព្រឹកនេះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែកកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ នេះ។ សូមអរគុណ។

[០៩:០២:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះសាលាដំបូង បានទទួលសំណើសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ

២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមនៅក្នុងសវនាការក្នុងបន្ទប់សវនាការនេះដោយផ្ទាល់ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត ឈា គន្ធារី គ្រូពេទ្យទទួលពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំង នៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ ហើយកត់សម្គាល់ឃើញថា ស្ថានភាពទូទៅមិនល្អ ដោយគាត់មានអាការៈហត់ខ្លាំង នៅពេលធ្វើចលនាបន្តិចបន្តួច បត់ជើងតូចញឹកញាប់ ឈឺជើង ឈឺចង្កេះ ហើយនិងហើមជើងពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរ អនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។

[០៩:០៣:៤៩]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាករដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយគាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្រប អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[០៩:០៥:០៧]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី ហើយជាពិសេសសូមជម្រាបសួរលោកស្រីសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** មុនពេលដែលខ្ញុំចាប់ផ្តើម ខ្ញុំសូមជម្រាបលោកស្រីថា ខ្ញុំមិនមានសំណួរច្រើនទេនៅថ្ងៃនេះ។ ខ្ញុំសង្ឃឹមថា សំណួរខ្ញុំប្រហែលជាបញ្ចប់ក្នុងរយៈពេល២០នាទី ឬក៏អាចតិចជាងនេះ។ លោកស្រី ស សៀក សំណួរទី១ របស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ ដែលលោកស្រីបានធ្វើជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយកិច្ចសម្ភាសន៍នេះធ្វើឡើងនៅថ្ងៃ២៤ ខែមីនា ឆ្នាំ ២០០៩។ ព្រះរាជអាជ្ញាបាននិយាយៗ អំពីការសម្ភាសនេះរួចរាល់ទៅហើយ ប៉ុន្តែសំណួររបស់ខ្ញុំបានចង់សួរថាតើលោកស្រីបាននិយាយ ឬក៏បានសម្ភាសជាមួយអ្នកស៊ើបអង្កេតនេះដែរឬទេ?

[០៩:០៦:១៦]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ នាងខ្ញុំបានធ្វើកិច្ចសម្ភាសន៍ជូន ខាងក្រុមសង្កេតការណ៍ មែនពិតលោក។

**ស៖** ខ្ញុំអាននូវប្រតិចារឹកមួយផ្នែក ដែលលោកស្រីបានធ្វើសម្ភាស នៅថ្ងៃទី២៤ មីនា ឆ្នាំ២០០៩ ហើយសម្រាប់កំណត់ត្រា ខ្ញុំសូមបង្ហាញនូវលេខ ERN គឺឯកសារដែលមានលេខ D200/6.8 ភាសាអង់គ្លេសមានលេខ 00834863 ដល់ 870, ភាសាខ្មែរគឺមានលេខ 00833490 ដល់ 497, ហើយភាសាបារាំងគឺមានលេខ 00835914 ដល់ 21។ ហើយកថាខណ្ឌដែលខ្ញុំចង់អានជូនលោកស្រី គឺមាននៅទំព័រភាសាអង់គ្លេសគឺមានលេខ 00834870 -- 867 ដល់ 868, ហើយភាសាខ្មែរគឺមានលេខ 00833494 ដល់ 495។ ហើយវាជាការនិយាយពាក់ព័ន្ធទៅនឹងគោលនយោបាយ ទាក់ទងទៅនឹងទាហានខ្មែរមួយរូបដែលអាចសម្រាប់ -- ដែលអាចសម្លាប់ពួកយួន ៣០នាក់។ ហើយខ្ញុំសូមដកស្រង់ពីប្រតិចារឹកដែលជាការសម្ភាសផ្ទាល់របស់លោកស្រី។

[០៩:០៨:២១]

ខ្ញុំសូមដកស្រង់៖ ជាដំបូងលោក តាវរណ្ណ បានសួរទៅលោកស្រីថា “ខ្ញុំចង់សួរលោកស្រីបន្ថែម

ក្នុងពេលដែលលោកស្រីធ្វើការខាងៗឃោសនាការនៅសម័យ ប៉ុល ពត នុំង គឺថាជាគោលការណ៍របស់របបកម្ពុជាប្រជាធិបតេយ្យ គឺនិយាយអំពីទាហានខ្មែរក្រហមមួយរូបអាចសម្លាប់ពួកយួន ៣០នាក់ ដែលបានផ្សព្វផ្សាយនៅតាមព័ត៌មាន។ ហើយយើងសូមសួរលោកស្រីថា នៅពេលដែលមានការវ៉ៃ -- នៅពេលដែលមានការប្រយុទ្ធគ្នានោះ គឺនៅពេលសម័យសង្គ្រាម។ ហើយនៅពេលដែលធ្វើការនៅក្រសួងឃោសនាការ តើលោកស្រីធ្លាប់ឮគេនិយាយអំពីការដែលថា ទាហានខ្មែរវ៉ៃពួកយួន ៣០នាក់ហ្នឹងដែរឬទេ?" លោកស្រីឆ្លើយថា៖ "អត់ដែលដឹងទេ"។ បន្ទាប់មកព្រះរាជអាជ្ញាសួរថា៖ "តើលោកស្រីធ្លាប់ឮដែរឬទេ ធ្លាប់ឮការផ្សព្វផ្សាយអំពីគោលការណ៍នេះដែរឬទេ?" ហើយលោកស្រីបាននិយាយថា៖ "ខ្ញុំអត់ចាំទេ ខ្ញុំភ្លេចអស់ហើយ"។ ព្រះរាជអាជ្ញា អ៎! អ្នកស៊ើបអង្កេតបានសួរទៀតថា៖ "តើលោកស្រីធ្លាប់ឮដែរទេ សូមលោកស្រីព្យាយាមរំឭកមកមើល?" លោកស្រីឆ្លើយថា៖ "ខ្ញុំអត់ដែលចាំអ្វីទាំងអស់ ប្រសិនបើខ្ញុំបានធ្លាប់ឮមែនក៏ប្រហែលជាខ្ញុំភ្លេចបាត់ទៅហើយ"។ បន្ទាប់មក អ្នកស៊ើបអង្កេតបានសួរថា៖ "អ៊ីចឹងហេស! អត់ចាំទេហេស! មិនចាំថា តើមានការផ្សាយ ឬក៏អត់ទេ?" ហើយលោកស្រីបានឆ្លើយថា៖ "ចាស"។

[០៩:១០:០០]

ដូច្នេះទាក់ទងទៅនឹងការដកស្រង់ប្រតិចារឹកមួយនេះ សំណួររបស់ខ្ញុំគឺចង់សួរលោកស្រី ស សៀក ដូចតទៅនេះ៖ តើខ្ញុំអាចនិយាយបានដែរឬទេ ថានៅខែមេសា ឆ្នាំ២០០៩ នៅពេលដែលគេសម្ភាសលោកស្រី គឺសម្ភាសដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺលោកស្រីមិនបានចាំថា តើមានគោលនយោបាយទាក់ទងទៅនឹងការកម្ទេចឬក៏ការវ៉ៃយួន៣០នាក់ ហ្នឹងមានផ្សព្វផ្សាយនៅក្នុងព័ត៌មានតាមវិទ្យុរបស់ខ្មែរក្រហមឬក៏អត់? ដូច្នេះ ខ្ញុំអាចនិយាយបានដែរឬទេ ថាលោកស្រីបានភ្លេច ឬក៏លោកស្រីមិនបានដឹង?

**ឆ៖** ចាស លោកខ្ញុំសូមឆ្លើយនូវសំណួរហ្នឹង ការពិតនាងខ្ញុំបានផ្តល់យោបល់ដល់អ្នកអង្កេតការណ៍មែន ពីព្រោះអីនេះជាពាក្យស្លោកមួយ ដើម្បីលើកទឹកចិត្តដល់កងទ័ព ហើយកងទ័ពខ្មែរម្នាក់អាចទប់ទល់នឹងខ្មាំង ៣០នាក់ ប៉ុន្តែគ្រាន់តែសំណួរដែលលោកចៅក្រមខាងនេះគាត់បានសួរ ខ្ញុំឆ្លើយថា មិនបានចាំ មិនបានភ្លេច ដោយខ្ញុំភ្លេចការសម្ភាសរបស់ផងខ្ញុំយូរថ្ងៃខែពេក ចាស។

[០៩:១១:៤៣]

**ស៖** សូមអរគុណលោកស្រី ស សៀក ចំពោះចម្លើយរបស់លោកស្រី។ ខ្ញុំសូមបន្តទៅនឹងអ្វី

ដែលបានធ្វើឡើងកាលពីសប្តាហ៍មុន គឺថ្ងៃ១៦ ខែ៨ នៅពេលដែលសហព្រះរាជអាជ្ញាបានសាកសួរលោកស្រីអំពីប្រធានបទមួយនេះ ហើយយើងអាចរកឃើញនៅក្នុងឯកសារដែលមានទំព័រ៧៤-៧៥ ដែលជាប្រតិចារឹកពង្រាង និងទំព័រ៧១ ជាភាសា -- ៦១ ជាភាសាខ្មែរ។ ព្រះរាជអាជ្ញាបានសួរលោកស្រីអំពីគោលនយោបាយទាក់ទងទៅនឹងទាហានខ្មែរមួយ វៃយួន ៣០នាក់នេះ ហើយខ្ញុំសូមដកស្រង់អំពីប្រតិចារឹកគឺនៅទំព័រ៧៤ ហើយខ្ញុំសូមដកស្រង់នូវចំ -- នៅព្រះរាជអាជ្ញា គឺនៅក្នុងឯកសារនេះមានកថាខណ្ឌមួយដែលគេអានអាចជូនលោកស្រីស្តាប់អំពីព្រះរាជ -- ដែលអានដោយសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំចង់សួរលោកស្រីអំពីបញ្ហាមួយនេះ។

[០៩:១៣:០១]

ហើយចុះក្រោមបន្តិច គឺព្រះរាជអាជ្ញា បានដកស្រង់នូវឃ្លានោះ ហើយខ្ញុំសូមដកស្រង់៖ “បក្សបានណែនាំឲ្យយើងកម្ទេចខ្មាំងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយនិងរក្សាកម្លាំងតាមដែលអាចធ្វើទៅបាន។ ហើយយើងត្រូវតែវាយកម្ទេចខ្មាំងឲ្យបានច្រើន ហើយដូច្នេះហើយយើងត្រូវតែរក្សាកម្លាំងរបស់យើងឲ្យបានជាអតិបរមា ហើយនិងព្យាយាមសម្លាប់ខ្មាំងឲ្យបានច្រើនបំផុត តាមដែលអាចធ្វើទៅបាន។ នេះ គឺជាពាក្យស្លោកដែលគេនិយាយថា ទាហានខ្មែរម្នាក់ កម្ទេចខ្មាំងយួន ៣០នាក់”។ ខ្ញុំសូមបញ្ចប់នូវការដកស្រង់។ ព្រះរាជអាជ្ញា បន្ទាប់មកបានសួរលោកស្រីបន្តទៀតថា “លោកស្រី ស សៀក តើលោកស្រីធ្លាប់ចាំថា មានការផ្សព្វផ្សាយអំពីទាហានខ្មែរមួយរូបអាចកម្ទេចខ្មាំងយួនបាន ៣០នាក់ ហ្នឹងបានដែរឬទេ?” ហើយលោកស្រីបានឆ្លើយថា “ចាស នៅក្នុងសំណួរនេះ នាងខ្ញុំដូចស្រពេចស្រពិល ហើយក៏ថាចាំមិនបានលោក”។ លោកស្រី ស សៀក អ្វីដែលខ្ញុំចង់សួរលោកស្រីថ្ងៃនេះ គឺថាតើខ្ញុំអាចនិយាយបានដែរឬទេ ថាកាលពីសប្តាហ៍មុនក៏លោកស្រីមិនបានចាំថា តើមានការផ្សព្វផ្សាយ ឬក៏ការប្រកាសតាមវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យអំពីបញ្ហានេះដែរទេ?

[០៩:១៤:៣៣]

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនឹងសំណួរហ្នឹង។ ក្រោយពីបានឆ្លើយ និងបំភ្លឺមកនាងខ្ញុំទៅដេកគិតត្រិះរិះនូវការសម្ភាសរបស់នាងខ្ញុំពីប៉ុន្មានខែ ប៉ុន្មានឆ្នាំមុនមក គឺនាងខ្ញុំបានគិតឃើញខ្លួនឯងថា នាងខ្ញុំបានផ្តល់យោបល់អ៊ីចឹងមែន ហើយក៏បានស្តាប់នូវការផ្សព្វផ្សាយ និងការអប់រំដល់កងទ័ពពីសម័យនោះមែន។

**ស៖** សូមអរគុណលោកស្រី។ ហើយបន្ទាប់មកព្រះរាជអាជ្ញាក៏បានអានជូនលោកស្រីនូវ

ចម្លើយដែលលោកស្រីបានធ្វើឡើងពីពេលមុនជាមួយនឹងសហចៅក្រមស៊ើបអង្កេត។ ហើយព្រះរាជអាជ្ញាបានដកស្រង់នូវចម្លើយ ដែលបានធ្វើជាមួយសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងអ្វីដែលខ្ញុំទើបតែអានជូនលោកស្រី ហើយខ្ញុំសូមដកស្រង់៖ "តើកថាខណ្ឌនេះជាមាគ៌ាបក្សទេ?" ហើយលោកស្រីបានឆ្លើយថា "ពិតហើយជាមាគ៌ា។ តាមអ្វីដែលខ្ញុំយល់ពាក្យថា "យើង" យោងទៅរកមេដឹកនាំជាន់ខ្ពស់នៅក្នុងនោះ គឺថាមាន ប៉ុល ពត ហើយនិង អនុរបស់គាត់"។ សំណួរ "តើពាក្យថា កម្ទេច មានន័យថាដូចម្ដេច។ តាមទស្សនៈរបស់លោកស្រី តើពាក្យឃោសនាបែបនេះមានន័យដូចម្ដេច?"។ ឆ្លើយ "ពាក្យថា កម្ទេច គឺចំពោះមនុស្ស គឺមានន័យថា សម្លាប់ បើចំពោះសម្ភារគឺការបំផ្លាញ"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ ហើយកាលពីសប្ដាហ៍មុន ព្រះរាជអាជ្ញាបានសួរលោកស្រីថា "តើនេះជាចម្លើយត្រឹមត្រូវដែលលោកស្រីបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ ចំពោះកថាខណ្ឌដែលទើបតែបានអានអម្បាញ់មិញនេះ?"។

[០៩:១៦:៣១]

ហើយកាលពីសប្ដាហ៍មុនដែរ លោកស្រីបានឆ្លើយថា "ចាស" នៅលើសំណួរនេះ និងខ្ញុំបានផ្ដល់យោបល់។ ប៉ុន្តែគ្រាន់ថា ពេលនោះក្នុងការស្រពេចស្រពិលខ្លះ ប៉ុន្តែដោយមានការពិភាក្សាទៅ ក៏អាចបញ្ជាក់នៅក្នុងត្រង់ហ្នឹង។

សំណួររបស់ខ្ញុំដែលខ្ញុំចង់សួរចំពោះលោកស្រីសាក្សីនៅថ្ងៃនេះ គឺថាពាក្យថា "យើង" ដែលមាននៅក្នុងកថាខណ្ឌដែលខ្ញុំទើបតែអានលោកស្រីស្ដាប់អម្បាញ់មិញនេះ តើ "យើង" ហ្នឹងយោងទៅរកអ្នកណា? សំដៅទៅរកអ្នកណាដែរតាមលោកស្រីយល់?

**ឆ៖** ចាស លោកប្រធាន ពាក្យដែលថា "យើង" រួមមួយម៉ាត់នេះ ខ្ញុំចង់និយាយសំដៅទៅដល់អ៊ំៗ គាត់ជាអ្នកគ្រប់គ្រង។ សំខាន់ គឺអ្នកដឹកនាំតែម្ដង។

**លោក ហ្សាស្ដើ ប៉ោះ**

សូមអរគុណ។ ខ្ញុំមិនមានសំណួរបន្ថែមទៀតទេជូនចំពោះលោកស្រីនៅថ្ងៃនេះ។ ខ្ញុំចង់បញ្ជាក់ដើម្បីជាកំណត់ត្រា ខ្ញុំនឹងស្នើសុំនូវផ្នែកដែលពាក់ព័ន្ធនៃកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតឲ្យមានធ្វើជាប្រតិចារឹក។ ព្រោះថាវាបានបញ្ជាក់ថា តាមគំនិតរបស់យើង គឺថាអ្វីដែលបានកើតឡើងនៅក្នុងកិច្ចសម្ភាសន៍នេះ គឺថាព័ត៌មានភាគច្រើនត្រូវបានគេប្រាប់ទៅដល់សាក្សី។ ហើយទោះបីថាក្រោយពេលហ្នឹងមក ៣ឆ្នាំក៏ដោយ ក៏មិនអាចផ្ដល់សក្ខីកម្មបានដែរ។ ទោះបីយ៉ាងក៏ដោយ ៣ឆ្នាំក្រោយមក

លោកស្រីនៅតែមិនអាចដឹងអំពីព័ត៌មានទាំងអស់នេះ។

[០៩:១៨:១៩]

ខ្ញុំមិននិយាយលម្អិតអំពីបញ្ហានេះទេ ព្រោះវាធ្វើឱ្យសក្ខីកម្មហ្នឹងនឹងមានភាពស្មុគស្មាញបន្តទៅមុខទៀត។ ប៉ុន្តែអ្វីដែលខ្ញុំចង់បញ្ជាក់ គឺខ្ញុំចង់ឱ្យមានការធ្វើកំណត់ត្រា ហើយខ្ញុំនឹងធ្វើនូវសំណើសុំបែបនេះ។ ហើយយើងនឹងដាក់នូវសំណើសុំបែបនេះនៅសប្តាហ៍នេះ ឬក៏--។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំមិនចង់ជំទាស់អ្វីនោះទេ វាគ្រាន់តែជាបញ្ហានៃការលំដាប់លំដោយ។ វាជាការមិនសមស្រប ដែលយើងធ្វើការបញ្ចេញមតិយោបល់បែបនេះនៅចំពោះមុខសាក្សី។ វាហាក់ដូចជាការបញ្ជាក់ ឬក៏ជាប្រាប់ទៅដល់សាក្សីដូច្នេះដែរ។ ទាក់ទងទៅនឹងអ្វីដែលមេធាវីគាត់ចង់ធ្វើពាក្យសុំ ឬក៏សំណើសុំ ព្រោះថាការធ្វើសំណើសុំ ឬក៏ធ្វើពាក្យសុំបែបនេះ គួរតែធ្វើដោយមិនមានវត្តមានរបស់សាក្សី។ គាត់អាចបញ្ជាក់នៅពេលដែលគ្មានសាក្សី ហើយគាត់ក៏មិនចាំបាច់ត្រូវមកបញ្ជាក់នៅពេលនេះដែរ ឬក៏គាត់យកជាការល្អ គឺគាត់គួរតែធ្វើនៅពេលដែលសាក្សីបានចាកចេញពីបន្ទប់សវនាការ។ ហើយខ្ញុំយល់ថា នេះជាការមិនត្រឹមត្រូវទាល់តែសោះ។

[០៩:១៩:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ហើយប្រសិនបើមានចង់ធ្វើការសន្និដ្ឋាន ឬក៏វាយតម្លៃចំពោះសាក្សីនីមួយៗនៅពេលដែលតាំងសំណួរចប់ ឬក៏ដេញដោលនូវអង្គហេតុណាមួយចប់នោះ គឺសូមឱ្យភាគពាក់ព័ន្ធអនុវត្តនូវខ្លឹមសារនៃវិធានដែលមានចែងនៅក្នុងវិធាន៩២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ សេចក្តីសន្និដ្ឋានពាក់កណ្តាលទីដែលត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជាបន្តជូនទៅក្រុមមេធាវីការពារក្តីលោក -- នៅ?

សូមអញ្ជើញបាទ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន និងសូមអរគុណលោកប្រធានអនុញ្ញាតឱ្យ

ខ្ញុំបន្តការសាកសួរទៅសាក្សីឈ្មោះ ស សៀក។ ខ្ញុំមានសំណួរខ្លីតិច ប្រហែលជា១៥នាទី ឬ២០នាទីចប់។

[០៩:២១:០៧]

**សួរដោយលោក សុន អរុណ៖**

**ស៖** ជម្រាបសួរលោកស្រី ស សៀក! សំណួរទី១របស់ខ្ញុំថ្ងៃនេះ -- ខ្ញុំភ្លេចជម្រាប ខ្ញុំឈ្មោះ សុន អរុណ ជាមេធាវីការពារលោក នួន ជា ជាមួយសហការីរបស់ខ្ញុំ។

លោកស្រី ស សៀក បានចូលបដិវត្តន៍ពីឆ្នាំណា? សូមមានប្រសាសន៍សាថ្មីម្តងទៀត បើសិនជាអាចធ្វើបាន?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស នៅឆ្នាំ១៩៧២។

**ស៖** អរគុណ។ ពេលនោះអ្នកស្រីមានអាយុប៉ុន្មាន?

**ឆ៖** នាងខ្ញុំបើគិតជាឆ្នាំកើត ឆ្នាំ១៩៦៦ ប្រហែលជា១៤ ឬ១៥ ស្មានលោក។

**ស៖** អរគុណ។ ពេលនោះនរណាណែនាំ ដឹកនាំអ្នកស្រីឲ្យចូលក្នុងបដិវត្តន៍? ឈ្មោះអី?

**ឆ៖** ចាស តាមរយៈដែលនាងខ្ញុំធ្លាប់ឃ្វាលគោពីដើមមក នាងខ្ញុំចេះច្រៀងខាងផ្នែកអាយ៉ៃបន្តិចបន្តួចអីចឹង។ ក្រោយមក មិនដឹងថាគោលការណ៍ខាងលើរៀបចំស្អី ខ្ញុំមិនដឹងទេ ស្រុកទើបរំ -- រដ្ឋប្រហារហើយភ្លាមៗ។ តែគ្រាន់ថាមានប្រធានភូមិឈ្មោះ ពុំ នៅភូមិខ្ញុំហ្នឹងបានមកសាកសួរថា ជ្រើសរើសដើម្បីបង្កើតសិល្បៈស្រុកព្រៃវែង។ តាមរយៈហ្នឹងលោក។

[០៩:២២:៥៩]

**ស៖** អរគុណ។ ការណែនាំរបស់គណៈស្រុកដើម្បីទាញអ្នកស្រីឲ្យចូលទៅក្នុងបដិវត្តន៍កាលអ្នកស្រីនៅក្មេងនៅឡើយ តើរបៀបគេឃោសនា និងបញ្ចូល -- បញ្ចុះបញ្ចូលអ្នកស្រីហ្នឹង អ្នកស្រីអាចជម្រាបតុលាការបានពេលនេះ បានខ្លះទេ? នៅចាំបានខ្លះទេ?

**ឆ៖** ចាស នៅពេលនោះប្រធានភូមិខ្ញុំក៏មិនបាននិយាយបកស្រាយអីពីរឿងថា ស្រុកយើងកើតសង្គ្រាម ឥឡូវមានការដឹកនាំអីចេះមួយ អីចេះពីរ ត្រូវតែរៀបចំអីចេះមួយ អីចេះពីរ អត់មានផងលោក។ គ្រាន់ថាជ្រើសរើសមកអីចឹង ប៉ុន្តែពេលនោះយើងកើតកងឈ្លបហើយនៅតាមភូមិ។ ប៉ុន្តែគ្រាន់តែខ្ញុំមិនទាន់ស្គាល់ថា ពីណាមួយដែលអ្នកដឹកនាំការងារហ្នឹងបន្តៗមកអត់ដឹងដែរ។

**ស៖** ខ្ញុំៗចង់សួរអីចេះ ខ្ញុំចង់សួរថា ការណែនាំ ការណែនាំការឃោសនារបស់គណៈស្រុកហ្នឹង

ដើម្បីធ្វើឲ្យអ្នកស្រីមានចិត្តចង់ចូលក្នុងបដិវត្តន៍នៅពេលដែលអ្នកស្រីនៅក្មេងនៅឡើយនោះ តើគេឃោសនារបៀបម៉េចជម្រាបអ្នកស្រី?

**ឆ៖** ចាស ការពិតនាងខ្ញុំមិនមានការឃោសនាអប់រំ បំភ្លឺថា បម្រើការងារហ្នឹងចំណេញអ៊ីចេះៗ អត់មានទេ គ្រាន់តែថា អានេះវាជាចំណង់របស់នាងខ្ញុំតាំងពីក្មេងមក។ ពីក្មេងមក សូមរាយរាប់បន្តិចចុះ សូម្បីតែជាមួយម្ដាយខ្ញុំៗថាធំទៅ ខ្ញុំអត់ធ្វើស្រែទេ ខ្ញុំលេងយីកេហើយម៉ែអើយ។ ចាស អត់មានយល់អីទាំងអស់។

[០៩:២៤:៥៧]

**ស៖** បើអ៊ីចឹង អ្នកស្រីយល់ថា ចំណងរបស់អ្នកស្រីហ្នឹង ឲ្យតែគេរើសខាងសិល្បៈ អ្នកស្រីចូលអ៊ីចឹងតែម្ដង អត់យល់ពីរឿងថា បដិវត្តន៍យ៉ាងម៉េចៗ នយោបាយយ៉ាងម៉េចៗ អត់យល់អីទាំងអស់។ ដឹងថាអាហ្នឹង ចិត្តដែលចង់ថាចូលសិល្បៈ ដល់គេរើស ខាងគណៈស្រុកហ្នឹង គេរើសចូលសិល្បៈ អ្នកស្រីចូលតែម្ដង។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ពិតមែនលោកប្រធាន។

**ស៖** សូមអរគុណ។ សំណួរទី២ របស់ខ្ញុំ រួចក្រោយមកអ្នកស្រី បានធ្វើការនៅក្រសួងឃោសនាការ ក្រោយពីដូរទីកន្លែងពីដីក្រហមមក អ្នកស្រីបានធ្វើការនៅក្រសួងឃោសនាការនៅភ្នំពេញក្រោយឆ្នាំ១៩៧៥ នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានលោក ហ៊ូ នឹម ជារដ្ឋមន្ត្រីអ៊ីចឹង ពិតអ៊ីចឹងមែនទេ?

[០៩:២៦:១០]

**ឆ៖** ចាស លោក មែនហើយ ព្រោះអី គាត់ទទួលខុសត្រូវក្រសួងរបស់ផងខ្ញុំ។

**ស៖** អ្នកស្រីនៅធ្វើការជាមួយលោក ហ៊ូ នឹម រហូតដល់លោក ហ៊ូ នឹម បាត់ខ្លួន ឬដល់ពេលណា ដែលអ្នកស្រីចេញក្រសួងឃោសនាការហ្នឹង?

**ឆ៖** ចាស ចេញពីក្រសួង -- ខ្ញុំនៅរហូត តាំងពីរំដោះទីក្រុងភ្នំពេញមក នៅជាមួយក្រសួងរបស់លោករហូត។ តែដល់ក្រោយមក ឆ្នាំ៧៧ នាងខ្ញុំត្រូវដកខ្លួន គេដកនាងខ្ញុំមកធ្វើសៀវភៅទស្សនាវដ្ដីរូបភាព នៅមន្ទីរ២៧ ជិតរោងកុនសូរិយាពីសង្គម។

**ស៖** ពេលនុ៎ង លោក ហ៊ូ នឹម គាត់បានចាកចេញពីក្រសួងឃោសនាការហើយឬនៅ? ពេលដែលអ្នកស្រីគេដកចេញពីហ្នឹង?

**ផ៖** ចាស លោក ហ៊ូ នឹម គាត់បានចេញហើយ។ នាងខ្ញុំមកមន្ទីរ២៧ហ្នឹង ក្រោមការគ្រប់គ្រងរបស់ ពូ ឆយ គាត់មកជំនួស ចាស។

[០៩:២៧:៥៣]

**ស៖** អ្នកស្រីធ្វើការក្រោមការគ្រប់គ្រងរបស់រដ្ឋមន្ត្រី ហ៊ូ នឹម។ អ្នកស្រីដឹងថា ហ៊ូ នឹម គេដកចេញពីក្រសួងឃោសនាការ មានមូលហេតុអីទេ?

**ផ៖** ចាស ពេលនោះ នាងខ្ញុំអត់ដឹងផង ព្រោះអីថ្ងៃនុ៎ង មានការប្រជុំកែលម្អដកពិសោធន៍ នៅក្នុងការងារផ្នែកក្រសួងនាងខ្ញុំ ហើយក៏ឮសូរទូរស័ព្ទរោទិ៍មក គាត់ក៏ចេញទៅទទួល ហើយគាត់ក៏ផ្អាកការងារហ្នឹងទៅ គាត់ទៅខ្លួនឯង។ ថ្ងៃនុ៎ង ខ្ញុំឃើញគាត់ទៅ ជិះឡានខ្លួនឯង ពាក់ជើងពុម្ព ហើយបង់កក្រមាក្រឡាការ៉ូ ក្រមាហ្នឹង គេថាក្រមានៅព្រៃឈរ តែខ្ញុំឃើញជាក់ស្ដែង។ ចាស គាត់ទៅហើយ មិនឃើញមកវិញផង។

**ស៖** បន្ទាប់ពីគេ -- គាត់ទៅបាត់យូរទៅ មានអ្នកណាមកជំនួសគាត់នៅក្រសួងឃោសនាការហ្នឹង?

**ផ៖** ចាស ក្រោយមាន ពូ ឆយ។ ចាស មកមន្ទីរឃោសនាការហ្នឹង មាន ពូឆយ ប៉ុន្តែគ្រាន់តែអង្គភាពក្រសួងឃោសនាការ និងក្រសួងឃោសនាអប់រំហ្នឹង ខ្ញុំបានបញ្ជាក់នឹងសំណួរលោកចៅក្រមលើកមុនហើយ។ លោកស្រី យុន យ៉ាត គាត់អ្នកទទួល។ ក្រសួងពីរហ្នឹង រំលាយចូលគ្នា ទៅជាក្រសួងឃោសនាអប់រំ។

**ស៖** អរគុណ។ អ្នកស្រីបានជម្រាបតុលាការរួចមកហើយ ថាអ្នកស្រីបានចូលខាងសិល្បៈ រាំរែក និងច្រៀង។ ក្រៅពីនេះ តើអ្នកស្រីដែលបានគេឲ្យនិយាយវិទ្យុរបស់ក្រសួងឃោសនាការហ្នឹងទេ? អានជាអត្ថបទ ឬក៏អ្វីៗអីចឹង ដូចរបៀបអីចឹង មានទេ?

[០៩:៣០:០៤]

**ផ៖** ចាស អត់មានទេ ពីព្រោះអីផ្នែកខុសគ្នា។ អ្នកអានមានស្រីៗខ្លះ ប្រុសៗខ្លះ ហ្នឹងផ្នែករបស់ផងគេអ្នកអានវិទ្យុ តែនាងខ្ញុំតែផ្នែកសិល្បៈ អត់ដែលបានអានទេ។ ម្យ៉ាងវប្បធម៌នាងខ្ញុំមិនសូវជ្រៅជ្រះផង តែខ្ញុំគ្មានសមត្ថភាពអីទៅប្រកួតប្រជែងជាមួយការងាររបស់បងៗ។

**ស៖** សូមសួរតទៅទៀត។ អ្នកស្រីបានឆ្លើយទៅព្រះរាជអាជ្ញាកន្លងផុតទៅហើយនោះថ្មីៗនេះថា "នៅឆ្នាំរំដោះ១៩៧៥ វិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យបានផ្សាយពីរឿងវៀតណាមឈ្លានពានទឹកដី

ព្រំដែនកោះ ហើយប្រជាជនមានការឈឺចាប់ ហើយដាស់តឿន -- សុំទោស! ប្រជាជនមានការឈឺចាប់ ហើយបានដាស់តឿនកូនចៅ ឲ្យតស៊ូការពារទឹកដីរបស់ខ្លួនឲ្យបានមុតមាំ”។ បន្ទាប់ពីអ្នកស្រី មាន ប្រសាសន៍ជម្រាបព្រះរាជអាជ្ញារួចមកហើយ កាលពីអាទិត្យមុននុ៎ង តើអ្នកស្រីមានចងចាំថា គំនិត របស់រដ្ឋាភិបាលរបស់ឃោសនាការហ្នឹង មានគំនិតអ្វី ឬក៏ពាក្យសម្ដីអ្វី ដើម្បីផ្ដាំផ្ញើក្រៅពី ខ្ញុំអានអំមិញ ជម្រាបអំមិញលើសហ្នឹងទៀតទេ?

[០៩:៣២:០៦]

**ឆ៖** ចាស នាងខ្ញុំមិនបានចងចាំទេ។

**ស៖** អរគុណ។ ក្រៅពីសិល្បៈផ្សព្វផ្សាយពីរឿងភ្លេង ពីរឿងច្រៀង ការតស៊ូ តើអ្នកស្រីមាន បានស្ដាប់ ហើយនៅចាំ -- ចងចាំថា ក្រសួងឃោសនាការ និងអប់រំហ្នឹង មានបាននិយាយពីរឿង សន្តិសុខ បញ្ហាសន្តិសុខក្នុងផ្ទៃប្រទេស ឬផ្សព្វផ្សាយអំពីការងារការពារជាតិរបស់ប្រទេសទេ?

**ឆ៖** ចាស នៅក្នុងសំណួរនេះនាងខ្ញុំមិនបានចាំទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមអរគុណអ្នកស្រី ខាងក្រុម នួន ជា អស់មានសំណួរសួរអ្នកស្រី តទៀតហើយ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទជាបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បី មានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្ដីលោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ អស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ និងក្រៅបន្ទប់សវនាការ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សួស្ដីលោកស្រី! ខ្ញុំ ម៉ៃខល កាណាវាស ជាមួយនឹងលោក អាង ឧត្ដម តំណាងការពារក្ដី លោក អៀង សារី។ ខ្ញុំមានសំណួរមួយចំនួនតូចតែប៉ុណ្ណោះ។ មួយគឺសំណួរសួរបន្ត ពីសំណួររបស់

សហព្រះរាជអាជ្ញា ដោយផ្អែកទៅលើអ្វីដែលលោកស្រីឆ្លើយនៅក្នុងចម្លើយរបស់លោកស្រី។ ដូច្នេះ ខ្ញុំនឹងយោងសំណួរដែលសួរដោយសហព្រះរាជអាជ្ញា ដែលបានចោទសួរលោកស្រីនៅថ្ងៃ១៥ ខែសីហា ឆ្នាំ២០១២ ត្រង់ទំព័រ៨០ ជាភាសាអង់គ្លេស ខ្មែរ ៦៨ បារាំង ៨៥។ គេសួរលោកស្រី នៅក្នុងកំណត់ហេតុមុខចៅក្រមស៊ើបអង្កេត លោកស្រីបានលើកឡើងថា “លោកស្រីក៏បានដឹងអំពីវត្តមានរបស់លោក អៀង សារី នៅកន្លែងនោះផងដែរ”។ ហើយលោកស្រីបានលើកឡើងថា “លោក អៀង សារី ធ្វើការនៅក្រសួងការបរទេស”។ តើលោកស្រីចង់មានយោបល់អ្វីបន្ថែមទៀតដែរឬទេ? បើសិនជាគ្មានទេ សូមមេត្តា -- ខ្ញុំសូមបញ្ចប់សំណួរ បាទអរគុណ។

[០៩:៣៥:០៨]

កាលនោះគឺវាពាក់ព័ន្ធទៅនឹងសម័យថ្ងៃទី១៧ ខែសីហា ឆ្នាំ៧៥ ហើយលោកស្រីបានឆ្លើយថា៖ “អត់ទេលោក ខ្ញុំអត់បានឃើញផង”។ នេះជាចម្លើយដែលលោកស្រីបានឆ្លើយ។ នៅក្នុងចម្លើយរបស់លោកស្រី ដែលលោកស្រីបានឆ្លើយជូនចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ ខ្ញុំយោងទៅលើឯកសារ E3/379 ជាពិសេសត្រង់ទំព័រ៧ ជាភាសាអង់គ្លេស, ខ្មែរគឺ 00294803, បារាំងគឺ 00385199, អង់គ្លេសគឺ 00323327។ នៅក្នុងឯកសារនោះគឺមានសំណួរដូចតទៅ គេសួរថា៖ “តើមានឃើញលោក ប៉ុល ពត, អៀង សារី និង នួន ជា ឬទេ?”។ លោកស្រីឆ្លើយនៅពេលនោះ ជូនចៅក្រមស៊ើបអង្កេតថា៖ “អត់ឃើញទេ។ ប៉ុន្តែ អៀង សារី គាត់កាលនោះនៅក្រសួងការបរទេស”។

[០៩:៣៦:៣៣]

ជាថ្មីម្តងទៀតបរិបទ ពាក់ព័ន្ធទៅនឹងហេតុការណ៍នេះ នៅទំព័រមុននោះបានបង្ហាញថា នៅក្នុងថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥។ ដូច្នេះ ខ្ញុំសូមសួរលោកស្រីដូចតទៅ តើលោកស្រីអាចពន្យល់ជូនយើងខ្ញុំបានដែរឬទេ ថាហេតុអ្វីបានជាលោកស្រីឆ្លើយចម្លើយបែបនេះ នៅចំពោះមុខចៅក្រមស៊ើបអង្កេត ហើយថែមទាំងបានចុះហត្ថលេខា នៅលើឯកសារនោះថា វាជាចម្លើយសង្ខេប នៃអ្វីដែលលោកស្រីបានឆ្លើយ ដែលក្នុងនោះវាផ្ទុះបញ្ជាំងថា អ្វីដែលឆ្លើយនៅក្នុងចម្លើយនេះគឺត្រឹមត្រូវ និងពេញលេញ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនូវសំណួរហ្នឹង។ ការពិតនាងខ្ញុំធ្វើដំណើរ -- ការសម្អាសហ្នឹងចង់សំដៅថា នាងខ្ញុំដែលបានធ្វើដំណើរពីដីក្រហម ទៅចូលទីក្រុងភ្នំពេញហ្នឹង មានមេដឹកនាំរបស់ផងនាងខ្ញុំហ្នឹងឈ្មោះអីខ្លះដែលទៅជាមួយពេលនោះ។ ដល់អីចឹងនាងខ្ញុំថា អត់មានបានឃើញទេ អី! លោក ប៉ុល ពត,

នួន ជា, អៀង សារី អត់បានឃើញទេ តែគ្រាន់នាងខ្ញុំបញ្ជាក់ថា តាមនាងខ្ញុំដឹងខ្លះៗ លោក អៀង សារី គាត់ទទួលខុសត្រូវខាងក្រសួងការបរទេស គ្រាន់ដឹងតែប៉ុណ្ណឹងលោក។ ហើយរឿងដែលខ្ញុំបានចុះហត្ថលេខា និងផ្តិតមេដៃនេះ សាក្សីហ្នឹងអានឲ្យនាងខ្ញុំស្តាប់ដែរ ប៉ុន្តែគ្រាន់ថា ការសម្ភាសវាយូរម៉ោងដែរ អីចឹងការហេរហាត់ក៏វាច្រើន អីចឹងខ្ញុំក៏មិនបានថា បញ្ជាក់ថា ខ្លឹមសារត្រង់នេះៗអីវាត្រូវការលើសលស់អីឬមួយយ៉ាងម៉េច នាងខ្ញុំក៏មិនបានហ្មត់ចត់ត្រង់ហ្នឹងដែរ។ គ្រាន់ថា ការសម្ភាសរបស់នាងខ្ញុំ វាយល់ប៉ុន្មានដឹងប៉ុន្មាន នាងខ្ញុំនិយាយប៉ុណ្ណឹង ហើយក្នុងការដែលនាងខ្ញុំប៉ានចុះហ្នឹង គឺនាងខ្ញុំ បានន័យថា ទទួលខុសត្រូវខ្លួនឯង ថានាងខ្ញុំបានដឹងមែនពិតចាស។ កន្លែងខ្លះដែលស្រពេចស្រពិល នាងខ្ញុំបានប្រាប់ថា ភ្លេចភ្លាំងនៅចាំតិចតួចអីចឹងលោក។

[០៩:៣៩:១០]

**ស៖** សូមអរគុណយ៉ាងច្រើន ចំពោះចម្លើយនេះ។ ដើម្បីឲ្យខ្ញុំយល់ឲ្យបានច្បាស់ អ្វីដែលលោកស្រីឆ្លើយនៅក្នុងថ្ងៃនេះ គឺអ្វីដែលសរសេរនៅក្នុងចម្លើយ ដោយចៅក្រមស៊ើបអង្កេតនោះ គឺគេបានអានឲ្យលោកស្រីបានស្តាប់ផងដែរៗ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

នេះគឺជាការនិយាយខុស នូវអ្វីដែលសាក្សីបានឆ្លើយ។ សាក្សីបានបញ្ជាក់ហើយថា គេបានអានឲ្យគាត់ស្តាប់។ សាក្សីបានបញ្ជាក់ហើយថា គាត់បានស្តាប់ ក៏ប៉ុន្តែមិនចាំចំណុចគ្រប់ទាំងអស់នោះទេ។ ដូច្នេះហើយ យើងឃើញថា វាមិនមានអ្វីដែលវាចន្លោះប្រហោង រវាងចៅក្រមស៊ើបអង្កេត និងអ្វីដែលឆ្លើយនៅក្នុងតុលាការនេះទេ ហើយខ្ញុំមិនដឹងច្បាស់ថាតើមេធាវីកំពុងតែលើកចំណុចណានោះឡើយ។

[០៩:៤០:០១]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកស្រីមានប្រាប់អ្នកស៊ើបអង្កេតខាងចៅក្រមស៊ើបអង្កេតនោះថា លោកស្រីបានឃើញលោក អៀង សារី នៅក្រសួងការបរទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដែរឬទេ? នេះជាសំណួររបស់ខ្ញុំ តើលោកស្រីមាននិយាយប្រាប់អ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតនៅពេលនោះដូច្នោះដែរឬទេថា លោកស្រីបានឃើញលោក អៀង សារី នៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកប្រធាន ខ្ញុំសូមឆ្លើយនឹងសំណួរហ្នឹង ពីព្រោះអីខ្ញុំអត់បានឃើញទេ មានក្រសួងការបរទេសអីណាភ្លាម បើទីក្រុងមិនទាន់បានរៀបចំផងចាស។ អត់មានទីកន្លែងលោក។ ពេលនុ៎ងអត់មានទីកន្លែងទេ តែក្រោយមកខ្ញុំមិនដឹងទេ ក៏គ្រាន់ខ្ញុំដឹងថាគាត់ក្រសួងការបរទេសតែប៉ុណ្ណឹងចាស។

[០៩:៤១:០១]

**ស៖** សូមអរគុណច្រើន។ សំណួររបស់ខ្ញុំគឺជាក់លាក់ ហើយវាឆ្លើយតបទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ដែលគាត់ចង់ដឹង។ តើលោកស្រីមានប្រាប់អ្នកស៊ើបអង្កេត -- តើលោកស្រីមានប្រាប់អ្នកស៊ើបអង្កេតថា លោក អៀង សារី នៅក្រសួងការបរទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដែរឬទេ? តើលោកស្រីមានប្រាប់អ្នកស៊ើបអង្កេតដូច្នេះដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំអត់មានគូសវាសថា កំណត់ថាថ្ងៃ១៧ មេសា លោក អៀង សារី នៅក្រសួងការបរទេសទេ គ្រាន់តែប្រាប់ជារួមថា គាត់ទទួលបន្ទុកក្រសួងការបរទេសតែប៉ុណ្ណឹង។ ចប់។

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំសូមចូលទៅដល់អ្វីដែលខ្ញុំសួរពីមុន។ នេះគឺជាអ្នកស៊ើបអង្កេត -- គឺជាឯកសារដែលស៊ើបអង្កេតបានធ្វើការសង្ខេបការសម្ភាសស្ដាប់ចម្លើយលោកស្រី បន្ទាប់មកគេអានឲ្យលោកស្រីបានស្ដាប់ ហើយគេឲ្យលោកស្រីផ្ដិតមេដៃថា វាជាការពិតនូវអ្វីដែលលោកស្រីបានឆ្លើយ។ ហើយគេបានលើកឡើងថា -- នៅក្នុងនេះបានសរសេរថា -- បានឆ្លើយថាលោក អៀង សារី នោះនៅក្រសួងការបរទេសនោះនៅថ្ងៃទី១៧ ខែមេសា ដូច្នេះសូមលោកស្រីអាចបញ្ជាក់បានដែរឬទេនរណាគេជាអ្នកសរសេរខុស ឬក៏ឆ្លើយខុសនៅក្នុងហ្នឹង។ គេសរសេរខុស ឬក៏លោកស្រីឆ្លើយខុស ទើបបានគេសរសេរសង្ខេបដូច្នេះនៅក្នុងហ្នឹង?

[០៩:៤២:៤១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមជំទាស់នឹងសំណួរនេះ។ ខ្ញុំឃើញថាអ្នកសាក្សីនេះបានពន្យល់ច្បាស់ហើយថា គាត់និយាយថាមិនមែនលោក អៀង សារី មិនមែននៅក្រសួងការបរទេសនៅថ្ងៃទី១៧ មេសា នោះទេ ក៏ប៉ុន្តែសហការីខ្ញុំហ្នឹងគាត់បកស្រាយផ្សេងទៀត ហើយធ្វើយ៉ាងណាឲ្យគាត់ដូរពាក្យពេចន៍របស់គាត់វិញ។ នេះជា

របៀបសួរដែលមិនសមស្របទាល់តែសោះ ដែលធ្វើឲ្យសាក្សីហ្នឹងកែប្រែចម្លើយរបស់ខ្លួនហ្នឹង។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានជាទីគោរព! ខ្ញុំព្យាយាមកំណត់ថា តើអ្នកណាគេជាអ្នកប្រព្រឹត្តកំហុសនៅក្នុងនេះ? សហព្រះរាជអាជ្ញាបានក្រោកឈរជំទាស់ហើយអះអាងថា យើងមិនគួរធ្វើការសង្កេតនៅចំពោះមុខសាក្សី។ ដូច្នេះ ខ្ញុំមិនចង់ដឹកមុខសាក្សី។ ក៏ប៉ុន្តែការលើកឡើងរបស់មេធាវី នួន ជា នោះ បានបញ្ជាក់ថា ការសង្ខេបនេះ គឺដែលថៅក្រមថា វាជាការពិតពេញលេញនិងទុកចិត្តនោះ ក៏ប៉ុន្តែវាអាចមានចំណុចខ្វះខាត។ ដូច្នេះ ក្នុងនេះយើងឃើញហើយដែលសាក្សីនោះ គឺគាត់បានកែចម្លើយរបស់គាត់ ហើយយើងព្យាយាមបញ្ជាក់ថាវាមានអនិយ័តភាព ភាពមិនត្រឹមត្រូវនៅក្នុងនេះផងដែរ ដែលវាទាក់ទងទៅនឹងចំណុចមួយចំនួនក្នុងន័យទូទៅ។ ដូច្នេះហើយនេះជាឧទាហរណ៍មួយដែលល្អបំផុត ដែលខ្ញុំព្យាយាមចង់សួរទៅកាន់សាក្សី តើអ្នកណាគេជាអ្នកប្រព្រឹត្តខុស សរសេរខុសនៅក្នុងនេះ។ ដោយសារតែអ្នកស៊ើបអង្កេតជាអ្នករៀបចំសេចក្តីព្រាងកំណត់ហេតុនេះឡើង បន្ទាប់មកអានស្តាប់ ឲ្យផ្តិតមេដៃ។

[០៩:៤៤:៣៤]

លោកស្រីបានបញ្ជាក់ហើយថា គាត់មិនដែលឆ្លើយដូច្នោះនោះទេ ដូច្នេះហើយប្រហែលជាការសរសេរខុសនៅក្នុងហ្នឹង។ ហើយលោកស្រីគាត់បានបញ្ជាក់ថា គាត់ហត់នៅពេលនោះ ដូច្នេះហើយទើបសរសេរបញ្ចូលយ៉ាងម៉េចនៅក្នុងនេះ ហើយខ្ញុំគ្រាន់តែសួរបញ្ជាក់ថា តើនរណាគេជាអ្នកសរសេរខុស ឬឆ្លើយខុសនៅក្នុងនេះតែប៉ុណ្ណោះ។

[០៩:៤៥:០១]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ!

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកប្រធាន ខ្ញុំសូមឆ្លើយបញ្ជាក់នូវសំណួរហ្នឹង ពីព្រោះអីការពិតនាងខ្ញុំការអត់បានឃើញគាត់មែន ប៉ុន្តែថា ក្រុមសង្កេតការណ៍អាច តាមការគាត់សរសេរច្រឡំ ឬយ៉ាងម៉េចទេ អានេះ ឬមួយក៏គាត់ចាក់ឲ្យនាងខ្ញុំស្តាប់ នាងខ្ញុំស្តាប់អត់ទាន់ ដូច្នេះខ្ញុំក៏មិនបានដកនិងលុបចោលនូវខ្លឹមសារនេះដែរ។ ព្រោះវាលឿន ចាស សូមលោកអធ្យាស្រ័យត្រង់ហ្នឹង ការពិត ខ្ញុំអត់បានឃើញទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំសួរសំណួរមួយចំនួនទៀតពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងដែលនៅពេលនោះចៅក្រម -- នៅក្នុងនោះយើងឃើញថា ចៅក្រមកាលពីម្សិលមិញបានចោទសួរសំណួរមួយចំនួនទៅកាន់លោកស្រី ខ្ញុំសួរលោកស្រី តើលោកស្រីធ្លាប់ចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែរឬទេ?

[០៩:៤៦:០៧]

**ឆ៖** ចាស នាងខ្ញុំអត់ដែលផង។

**ស៖** ដូច្នេះ ក្រៅពីកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ តើមានធ្លាប់ចូលរួមកិច្ចប្រជុំរបស់គណៈមជ្ឈិមដែរឬទេ?

**ឆ៖** ភ្លេចអស់ហើយលោក។

**ស៖** លោកស្រីបានជម្រាបនៅក្នុងសក្ខីកម្មរបស់លោកស្រីថា លោកស្រីមានការលំបាកមិនសូវ -- មានការលំបាកក្នុងការអាន តើលោកស្រីអាចប្រាប់បានដែរឬទេ ថានៅពេលដែលលោកស្រីបម្រើការងារនៅក្នុងក្រសួងឃោសនាការ តើគេមានចែកឯកសារពីគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ឲ្យលោកស្រីធ្វើការវិភាគដើម្បីឲ្យយល់ថា តើមានអ្វីកើតឡើងខ្លះនៅក្នុងគណៈអចិន្ត្រៃយ៍និងគណៈមជ្ឈិមដែរឬទេ?

[០៩:៤៧:១០]

**ឆ៖** អត់ដែលលោក។ ខ្ញុំមិនចាំ។

**ស៖** សំណួរជាក់លាក់មួយដែលខ្ញុំចង់សួរទៅកាន់លោកស្រី គឺខ្ញុំចង់សួរដូចតទៅ៖ គឺត្រង់ទំព័រ ១០៩ ក្នុងប្រតិចារឹកខ្មែរ គឺទំព័រ៨៩ ខ្ញុំអត់មានទំព័រជាភាសាបារាំងទេ។ គេសួរលោកស្រីដូចតទៅ៖ “តើលោកស្រីជឿ គិតថាអ៊ំៗទាំងអស់នោះ ព្រួយបារម្ភថាព័ត៌មានដែលអាចឲ្យមានការរិះគន់ ទិតៀន ហើយត្រូវចៀសវាងការទិតៀនដោយមាន ដូច្នេះមិនត្រូវផ្តល់ព័ត៌មាននោះទៅផ្សព្វផ្សាយព័ត៌មាននោះ ដើម្បីកុំឲ្យមានការទិតៀននោះ តើអ៊ីចឹងមែនទេ?”។ តើលោកស្រីនៅពេលនោះអាចដឹងថា អ៊ំៗនោះកំពុងគិតអ្វីដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំអត់បានដឹង។ មិនបានវិភាគផង។

[០៩:៣៨:២៦]

**លោក ម៉ែខល ការណាវ៉ាស៖**

សូមអរគុណច្រើន។ ខ្ញុំពុំមានសំណួរទៀតទេលោកស្រី ខ្ញុំសូមថ្លែងអំណរគុណលោកស្រីដែលជាសាក្សីមកផ្តល់សក្ខីកម្មទាំងនេះ។ ក្នុងនាមជាមេធាវីការពារក្តីលោក អៀង សារី រួមជាមួយលោក អាង ឧត្តម សូមថ្លែងអំណរគុណលោកស្រីច្រើន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំបាទឈ្មោះ គង់ សំអុន ជាមេធាវីការពាររបស់លោក ខៀវ សំផន ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីសួរអ្នកស្រីទាក់ទងទៅនឹងករណីរបស់លោក ខៀវ សំផន។ បាទ ជាបឋមខ្ញុំសូមជម្រាបបញ្ជាក់អំពីអ្វីដែលលោកស្រីបានឆ្លើយក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកថា អ្នកស្រីធ្លាប់បានជួបលោក ខៀវ សំផន នៅក្នុងកម្មវិធីបុណ្យតាំងពីសម័យមុនឆ្នាំ៧៥ ម្ល៉េះបាទ។ លោកស្រីអាចបញ្ជាក់បានទេថា តើកម្មវិធីបុណ្យដែលលោកស្រីនិយាយនោះជាកម្មវិធីបុណ្យអ្វីដែរ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកប្រធាន ខ្ញុំឆ្លើយនឹងសំណួរនេះ។ កម្មវិធីបុណ្យនៅទីក្រុងភ្នំពេញ បុណ្យអបអរសាទរទទួលកងទ័ពយើងរំដោះថ្ងៃ១៧ មេសា ម្តងចាស។

[០៩:៥០:០៦]

**ស៖** បាទ សូមទោស។ ខ្ញុំសូមបញ្ជាក់សាឡើងវិញ។ គឺខ្ញុំចង់និយាយអំពីបុណ្យមុនរំដោះឆ្នាំ១៩៧៥ បាទ។ អ៊ីចឹងសូមលោកស្រីជួយឆ្លើយបញ្ជាក់ទាក់ទងនឹងចំណុចនេះបាទ។

**ឆ៖** ចាស អង្កាល់ពីយើងមុនរំដោះហ្នឹង ខ្ញុំបានជួបគាត់ ខ្ញុំភ្លេចមន្ទីរនោះឈ្មោះ ៗមន្ទីរហើយប៉ុន្តែពួកនាងខ្ញុំទាំងអស់គ្នាហ្នឹង ក្នុងក្រុមសិល្បៈបានទៅចូលរួម។ អង្កាល់នុ៎ង បុណ្យចូលឆ្នាំ នៅឆ្នាំចិតសិប-- បើមិន៧៤ ៗហ្នឹង ចាស។

[០៩:៥១:០២]

**ស៖** បាទ សូមអរគុណ។ លោកស្រីជួបគាត់ក្នុងពិធីបុណ្យហ្នឹងប៉ុន្មានដងដែរ ក្នុងរយៈពេលមុនឆ្នាំ៧៥?

**ឆ៖** ចាស ខ្ញុំជួបគាត់តែម្តងហ្នឹង ចាស។ ជួបហ្នឹងក្នុងន័យគាត់ជាភ្ញៀវកិត្តិយសដែលទៅចូលក្នុងពិធីបុណ្យប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំអត់ច្បាស់អំមិញ លោកស្រីថា លោកស្រីមិនស្គាល់ទីតាំងកន្លែងធ្វើបុណ្យហ្នឹងទេ ឬមួយក៏អ្នកស្រីអាចបញ្ជាក់កន្លែងដែលកម្មពិធីបុណ្យហ្នឹងត្រូវបានប្រព្រឹត្តឡើងដែរ?

**ឆ៖** ចាស នោះក្នុងព្រៃឆ្ងាយពីមន្ទីរនាងខ្ញុំ។ ខ្ញុំភ្លេចឈ្មោះមន្ទីរហ្នឹង។ ចាស នាងខ្ញុំភ្លេចមន្ទីរហ្នឹងហើយ។

**ស៖** បាទ សូមអរគុណ។ ក្នុងពិធីបុណ្យនោះ គេធ្វើអ្វីខ្លះនៅក្នុងនុ៎ង? គ្រាន់តែនិយាយតែអំពីរឿងកម្មពិធីបុណ្យ អត់មានការឃោសនាអីផ្សេងទៀតទេ ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស ក្នុងកម្មពិធីហ្នឹងមានតែបុណ្យទាន ប្រពៃណីចូលឆ្នាំប៉ុណ្ណឹង ហើយមានទទួលបាយទឹកអីមួយពេល គគ្រឹកគគ្រេងដែរលោក។ តែប៉ុណ្ណឹង។

[០៩:៥២:៥១]

**ស៖** បាទ សូមអរគុណ។ ខ្ញុំបាទសូមត្រឡប់មកកាន់កំណត់ហេតុជាប្រតិចារឹករបស់លោកស្រីដែលបានឆ្លើយជាមួយក្រុមស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតដែលមានលេខសម្គាល់ E3/379 ត្រង់លេខ ERN ជាភាសាខ្មែរ 00294798, ជាភាសាបារាំង 00385193, ជាភាសាអង់គ្លេស 00323322 ដល់ 23។ នៅក្នុងចំណុចនេះ អ្នកស្រីបានបញ្ជាក់ថា "អ្នកស្រីត្រូវបានស្នើដោយមជ្ឈិម នៅពេលដែលអ្នកស្រីធ្វើជាក្រុមសិល្បៈ ជាសមាជិកក្រុមសិល្បៈម្នាក់នៅក្នុងស្រុក"។ ខ្ញុំចង់សួរបញ្ជាក់ថាតើអ្នកស្រីស្គាល់ពាក្យថា "មជ្ឈិម" ហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ នាងខ្ញុំបានសម្គាល់ ហើយចាំ ខ្ញុំថានេះជាលំដាប់ថ្នាក់ភូមិ។ ខ្ញុំរាប់ពីភូមិ មកសង្កាត់, សង្កាត់មកស្រុក, ស្រុកមកតំបន់, តំបន់មកភូមិភាគ, ភូមិភាគមកមជ្ឈិម។ ចាស ពេលនោះខ្ញុំស្គាល់ថាមជ្ឈិមហ្នឹង ជាកន្លែងលំដាប់លំដោយខ្ពស់ជាងភូមិភាគតំបន់ ឬភូមិអីចឹង ចាស។

[០៩:៥៥:០៥]

**ស៖** បាទ សូមអរគុណ។ លោកស្រីដឹងថា អ្នកណាដែលនៅមជ្ឈិម ដែលលោកស្រីថាមជ្ឈិម

ហ្នឹងជាអ្នកស្នើទៅហ្នឹង គេស្នើក្នុងលក្ខខណ្ឌអីជា មានលិខិតស្នាមអីបញ្ជាក់ មានសេចក្ដីសម្រេចអីបញ្ជាក់ ឬក៏មានបុគ្គលណាម្នាក់ដែលទៅហៅក្រុមអ្នកស្រីហ្នឹងឲ្យមក?

**ឆ៖** ចាស នាងខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ព្រោះអីតាមរយៈដែលនាងខ្ញុំបានៗគេជ្រើសរើសមកសិល្បៈហ្នឹងតាមរយៈលោក ទីវ អុល។ កាលនុំងលោក ទីវ អុល គាត់បានចុះទៅឃុំមួយនៅឯស្រុកនាងខ្ញុំ តំបន់២០ ហៅថាឃុំៗជាខ្លាង។ ចាស គាត់ទៅហ្នឹង គាត់ទៅបើកវគ្គបង្រៀនរៀនសូត្រប្រជាជននៅនោះទេ ប៉ុន្តែចង់ថាចប់វគ្គទៅ សិល្បៈបានទៅសម្ដែងជូនភ្ញៀវកិត្តិសយទាំងអស់ប៉ុណ្ណឹង ហើយគាត់បានឃើញដូចថានាងខ្ញុំមាននិស្ស័យខាងអាយ៉ៃអីតិចតួចអ៊ីចឹង កាលនុំង។ ក្រោយមក គាត់មកកន្លែងគាត់វិញមក ស្រាប់តែមានដំណឹងគេជ្រើសរើសមួយតំបន់ពីរនាក់ដែលមកនោះ តំបន់២០ នាងខ្ញុំមកពីរនាក់។ តំបន់ ខ្ញុំភ្លេចឈ្មោះហើយ នៅខាងស្វាយរៀងមកពីរនាក់។ ហើយនាងខ្ញុំហ្នឹង ស្រុកព្រៃវែងហ្នឹង មកពីរនាក់។ ប្រុសមួយ ហើយនាងខ្ញុំហ្នឹងមួយ។ ចាស តាមរយៈអ៊ីចឹងលោក។

[០៩:៥៦:៥៥៧]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងអ្នកដែលជម្រាបអ្នកស្រីហ្នឹង គឺមានឈ្មោះ ទីវ អុល អ៊ីចឹងមែនទេ?

**ឆ៖** ចាស មិនមែនគាត់ផ្ទាល់ទេ ដែលឲ្យនាងខ្ញុំមកហ្នឹង គ្រាន់ថាតាមរយៈដែលគាត់ឃើញនិស្ស័យសិល្បៈពួកខ្ញុំអ៊ីចឹង ដល់គាត់មកអ៊ីចឹង តាមខ្ញុំប៉ាន់ស្មានថា តាមរយៈគាត់ទៅ ពីព្រោះអីក្រោយមកបានមានប្រធានសិល្បៈស្រុកខ្ញុំហ្នឹងបានឧទ្ទេសនាមប្រាប់ថា ឲ្យមកសិល្បៈមជ្ឈិម ឈប់ឲ្យនៅនុំងហើយ។ ចាស និងដកនាងខ្ញុំមក តែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមឲ្យអ្នកស្រីបញ្ជាក់សាឡើងវិញថា អ្នកស្រីអត់បានដឹងថាជាការសម្រេចរបស់មជ្ឈិមដោយផ្ទាល់ទេ ប៉ុន្តែអ្នកស្រីបានដឹងតាមរយៈមាន ទីវ អុល និងអ្នកផ្សេងទៀតបាទ។ សូមអ្នកស្រីឆ្លើយតែប៉ុណ្ណឹងបានហើយ។

[០៩:៥៨:២១]

**ឆ៖** ចាស ពិតមែន នាងខ្ញុំយល់អ៊ីចឹង ពីព្រោះអីគេជ្រើសរើសនាងខ្ញុំអាចតាមរយៈលោក ទីវ អុល ហ្នឹងហើយ តាមនាងខ្ញុំស្មានទេ ក្នុងខ្លួនឯង ពីព្រោះថាគាត់ទៅឃើញនាងខ្ញុំមាននិស្ស័យ ហើយច្រៀងអាយ៉ៃអីអ៊ីចឹងទៅ។ ហើយនិងតាមរយៈផ្ទាល់ប្រធានសិល្បៈនាងខ្ញុំឈ្មោះៗ ពូលី។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលមកប្រធានបទមួយទៀតទាក់ទងទៅនឹងថ្ងៃ១៧ មេសា

១៩៧៥។ នៅពេលនុ៎ងអ្នកស្រីបានឆ្លើយកន្លងមកថា "អ្នកស្រីបានរៀបចំចេញពីប-២០ ពីតំបន់មួយនៅស្រុកស្ទឹងត្រង់ ដើម្បីត្រៀមចូលភ្នំពេញ ក្រោយពីបានដំណឹងថាបានទទួលជ័យជម្នះហើយ។ ហើយអ្នកស្រីបានធ្វើដំណើរមកភ្នំពេញ ប៉ុន្តែមិនមែនចូលមកភ្នំពេញផ្ទាល់ទេ គឺទៅភ្នំអង្គរស្នួសិន ខាងឧដុង្គ។ ហើយនៅទីនោះ អ្នកស្រីថាបានឃើញលោក ខៀវ សំផន នៅក្នុងរថយន្តហ្ស៊ីបជាមួយអ្នកផ្សេងទៀតមានស្ត្រីពីរនាក់ជាអ្នកអានសារព័ត៌មានបាទ"។ សូមអ្នកស្រីបញ្ជាក់ឡើងវិញថា តើខ្ញុំនិយាយអម្បាញ់មិញនេះត្រឹមត្រូវអ៊ីចឹងទេ?

[០៩:៥៩:៥០]

**ផ៖** ចាស លោក នាងខ្ញុំ -- សំណួរលោកឆ្លើយមកហ្នឹង នាងខ្ញុំបានឆ្លើយរួចហើយ ព្រោះអីនាងខ្ញុំក្រោយថ្ងៃរំដោះ១៧ មេសាហ្នឹង នៅក្នុងក្រុមនាងខ្ញុំទាំងអស់ហ្នឹង រៀបចំអីវ៉ាន់ហ្នឹង ត្រៀមខ្លួនមកមែន ហើយនិងជួបលោកមែន។ ចាស ខ្ញុំសូមបញ្ជាក់ឈ្មោះដែលស្រីជិះឡានជាមួយលោក មានឈ្មោះ មិត្តយ៉េត មួយហើយនិងឈ្មោះ និមល មួយ។ បងមលៗ ហ្នឹង គ្រួសារគាត់ឈ្មោះ បាន។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីឃើញក្នុងចម្ងាយប្រហែលប៉ុនណាដែរ? អាចបញ្ជាក់ជូនក្រុមប្រឹក្សាជំនុំជម្រះផង។

[១០:០០:៤៥]

**ផ៖** ចាស ខ្ញុំជិះឡានធំ អ៊ីចឹងឃើញគាត់ជិតដែរ។ ចាស ខ្ញុំស្គាល់ច្បាស់ណាស់លោក។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចចាំកាលៈទេសៈនៅពេលហ្នឹងទេ ថាចម្ងាយដែលអ្នកស្រីឃើញហ្នឹង ប្រហែលប៉ុន្មានម៉ែត្រ បើសិនជាអ្នកស្រីអាចវាយតម្លៃបាន?

**ផ៖** ចាស លោក ខ្ញុំសូមឆ្លើយនូវសំណួរនេះ ដូចខ្ញុំកំណត់ជាចម្ងាយប្រហែលពីលោកប្រធានមកខ្ញុំ ឡាន។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីឃើញច្បាស់ទេ មើលឃើញច្បាស់ទេ ពេលនុ៎ង?

**ផ៖** ចាស ខ្ញុំអត់មានស្រពេចស្រពិលទេ នាងខ្ញុំច្បាស់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបញ្ជាក់តទៀត ទាក់ទងទៅនឹងការធ្វើដំណើរការរបស់អ្នកស្រីចេញពីអង្គរស្នួមកចូលភ្នំពេញ។ អ្នកស្រីបានបញ្ជាក់ថា អ្នកស្រីបានសម្រាកនៅទីនោះ នៅអង្គរស្នួហ្នឹង ភ្នំអង្គរស្នួហ្នឹង គឺបីយប់។ ហើយបានមកភ្នំពេញ អ៊ីចឹង ត្រូវថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ បានអ្នកស្រីចូលមកភ្នំពេញ។ ហើយអ្នកស្រីបានបញ្ជាក់ថា ក្រុមរបស់អ៊ំៗហ្នឹង គាត់ចេញមកមុន ប្រហែលជា

១ម៉ោង។

[១០:០២:៤៥]

ខ្ញុំចង់ -- ប្រហែលជា១ម៉ោង ឬក៏២ម៉ោង ខ្ញុំចង់សួរបញ្ជាក់ថា តើលោកស្រីដឹងដោយរបៀបណាដែរ បានដឹងថា គាត់ចេញមកមុន ១ម៉ោង ឬក៏២ម៉ោងនោះ?

**ឆ៖** ចាស នាងខ្ញុំសន្និដ្ឋានថាអ៊ីចឹង ព្រោះអីអត់ឃើញគាត់នៅហ្នឹង ទៀតផង។ ចាស មានតែពួកខ្ញុំ នៅមកក្រោយ។

**ស៖** បាទ សូមអរគុណ។ អត់មានការនិយាយលាគ្នា ថា អូ! ទៅមុនហើយ អីអ៊ីចឹងទេ មានស្ថានភាពបែបហ្នឹងទេ? លោកស្រីអាចចាំបានទេ?

[១០:០៣:៣៩]

**ឆ៖** ចាស ព្រោះអីនាងខ្ញុំអត់រវីរវល់នឹងលោកទេ ពីព្រោះអីនាងខ្ញុំកំពុងតែហាត់។ ហាត់ចម្រៀង។ ហាត់ចម្រៀងហ្នឹង ចម្រៀងថ្ងៃ១៧ មេសា ដែលយើងត្រូវរំដោះហ្នឹង ចាស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរប្រធានបទថ្មីមួយទៀត ទាក់ទងទៅនឹងខ្សែអាត់សំឡេងរបស់លោកស្រី ដែលមានលេខសម្គាល់ D200/6.8 នៅទំព័រចុងក្រោយគេបំផុត ដោយសារអ្នកស្រីពិបាកអាន ចាំខ្ញុំអានជូន។ ERN ជាភាសាខ្មែរលេខ 00833497, ជាភាសាបារាំង 00835921, ជាភាសាអង់គ្លេស 00834870។

[១០:០៥:១០]

សំណួររបស់អ្នកស៊ើបអង្កេត បានសួរទាក់ទងទៅនឹងអ្នកដឹកនាំមួយចំនួន មានលោក អៀង សារី លោក នួន ជា អ៊ីចឹងទៅ ហើយបានមកដល់លោក ខៀវ សំផន។ ពេលហ្នឹងសួរថា៖ “ចុះលោក ខៀវ សំផន?” លោកស្រីបានឆ្លើយថា៖ “ខៀវ សំផន គាត់ច្រើន កាលហ្នឹងគាត់ជាប់ជាមួយសម្តេចភាគច្រើន”។ លោកស្រីមាននឹកឃើញសម្តីនេះទេ? ចាំថាធ្លាប់បាននិយាយជាមួយនឹងអ្នកស៊ើបអង្កេតរបស់តុលាការនេះទេ?

**ឆ៖** ចាស នាងខ្ញុំបានរាយរាប់ប្រាប់លោកដែរ ចាស។

**ស៖** ខ្ញុំមានសំណួរមួយចំនួនដើម្បីបញ្ជាក់ទៅលើចំណុចនេះ ទី១ ពាក្យថា“ជាប់ជាមួយសម្តេច” ហ្នឹងលោកស្រីចង់មានន័យថាម៉េច?

**ឆ៖** ចាស នាងខ្ញុំសូមឆ្លើយនឹងសំណួរហ្នឹងថា ជាប់នឹងការងារ ដោយថា លោកច្រើនទៅក្រៅ

ទៅអីអ៊ីចឹង ឃើញឧស្សាហ៍ជួបតាមខ្ញុំស្តាប់វិទ្យុអីអ៊ីចឹង។ តែរឿងការងារអី ខ្ញុំអត់ដឹងដែរចាស។ ឃើញលោក បើថាទៅធ្វើទស្សនកិច្ចអីអ៊ីចឹងទៅ តែងតែឮលោកទៅជួបអី សួរសុខទុក្ខអី ឈឺថ្កាត់អីដល់ព្រះអង្គអ៊ីចឹង ចាស។

[១០:០៦:៥២]

**ស៖** ខ្ញុំបាទ សូមបញ្ជាក់បន្ថែម ពាក្យថា "ចេញទៅក្រៅ" នេះ ចង់និយាយចេញទៅតាមតំបន់ផ្សេងៗនៅក្នុងស្រុក ឬក្រៅប្រទេស?

**ឆ៖** ចាស ក្រៅប្រទេស។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោកស្រីសំដៅទៅដល់មុនឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ៧៥ ក្នុងបរិបទនេះ?

**ឆ៖** ចាស ក្រោយឆ្នាំ៧៥ ពេលនាងខ្ញុំបានដឹងខ្លះ។ ចាស ក្រោយឆ្នាំ៧៥ ប៉ុន្តែមិនយូរទេលោក។ ក្នុង៧៥ ហ្នឹងសម្តេចលោកយាងមកស្រុកវិញហើយ ចាស។

**ស៖** សូមទោស ក្រោយឆ្នាំ៧៥ មានន័យថា ឆ្នាំ៧៦ អ៊ីចឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ចាំក្បាលមីក្រូ សិនបាទ។

**ឆ៖** ចាស មុនៗ៧៥ លោក ប្រហែលជា៧៤ អីនាងខ្ញុំបានស្តាប់វិទ្យុម្តងម្កាល។

**ស៖** បាទ សូមអរគុណ។ ហើយខ្ញុំសូមបញ្ជាក់បន្ថែម ពាក្យថា "សម្តេច" នៅទីនេះ គឺសំដៅទៅដល់សម្តេចណាមួយដែរ?

[១០:០៨:២៥]

**ឆ៖** ចាស សម្តេចតា។

**ស៖** បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

ខ្ញុំបាទអស់សំណួរហើយ។ អរគុណចំពោះសាក្សីដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំកន្លងមក។ ខ្ញុំសូមជូនសហការីរបស់ខ្ញុំសួរបន្តបាទ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

អស់លោក លោកស្រីចៅក្រមជាទីគោរព! ភាគីទាំងអស់ជាទីគោរព!

[១០:០៩:២២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរអ្នកស្រី ស សៀក។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំសូមសួរសំណួរអ្នកស្រីបន្តិចបន្តួច ហើយមិនស៊ីពេលយូរទេ។ ខ្ញុំ -- ជាបឋមខ្ញុំសូមត្រឡប់ និយាយអំពីចម្លើយរបស់អ្នកស្រីអម្បាញ់មិញ នៅពេលដែលលោកឆ្លើយទៅសហភាគ កាណាវាស របស់ខ្ញុំ លោកបាននិយាយអំពីកិច្ចសម្ភាសន៍របស់អ្នកស្រី ជាមួយនឹងអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ហើយលោកបាននិយាយអំពីពេលដែលអ្នកស្រីបានអានចម្លើយរបស់អ្នកស្រីឡើងវិញ។ និយាយឱ្យច្បាស់តែម្តង គឺថានៅពេលដែលគេអានចម្លើយរបស់អ្នកស្រីឡើងវិញឱ្យអ្នកស្រីស្តាប់ អ្នកស្រីបានជម្រាបថានៅពេលនោះអ្នកស្រីអស់កម្លាំង ហើយអ្នកស្រីមិនបានចាប់អារម្មណ៍ទៅនឹងព័ត៌មានលម្អិតនោះទេ។ សំណួរទី១ ទាក់ទងនឹងបញ្ហានេះអ្នកស្រី ខ្ញុំចង់ឱ្យអ្នកស្រីជម្រាបអង្គតុលាការថា កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនេះចំណាយពេលអស់រយៈពេលប៉ុន្មាន?

[១០:១០:៣៧]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស នាងខ្ញុំអត់បានចាំពេល និងម៉ោងផងលោកស្រី។ តែមានពេលយូរ តាមនាងខ្ញុំចាំដូចថា សម្រាកហូបបាយហើយបន្តទៀត ឬមួយក៏យ៉ាងម៉េច។ ខ្ញុំមិនបានចាំ។

**ស៖** តើអ្នកស្រីចាំថា កិច្ចសម្ភាសន៍នេះធ្វើឡើងតែរយៈពេលមួយថ្ងៃទេ ឬក៏ច្រើនថ្ងៃ?

**ឆ៖** ចាសនាងខ្ញុំចាំមិនពិតប្រាកដទេ ដូចថា ព្រឹក និងល្ងាច ឬមួយបន្តទៀតទេ នាងខ្ញុំមិនបានចាំទេលោក។

**ស៖** អ្នកស្រីសាក្សីដើម្បីរំឭកការចងចាំរបស់អ្នកស្រី ខ្ញុំសូមយោងទៅឯកសារ E3/379 ដែលជាចម្លើយរបស់អ្នកស្រី នៅថ្ងៃទី២៤ មីនា ឆ្នាំ២០០៩។ នៅទំព័រទី១ នៃឯកសារនេះ ជាភាសាបារាំង ERN ជាភាសាបារាំងគឺ 00385192, ជាភាសាខ្មែរគឺ 00294797, ហើយជាភាសាអង់គ្លេស ខ្ញុំរកមិនឃើញទេឥឡូវនេះ ក៏ប៉ុន្តែខ្ញុំដឹងថាជាទំព័រទី១ នៃចម្លើយរបស់អ្នកស្រី។ នៅទំព័រទី១ នេះ យើងមើល

ឃើញថា កិច្ចសម្ភាសន៍នេះចាប់ផ្ដើមនៅថ្ងៃទី២៤ មីនា ឆ្នាំ២០០៩ ហើយជាភាសាខ្មែរនោះ នៅទំព័រចុងក្រោយ នៃកិច្ចសម្ភាសន៍របស់អ្នកស្រីនោះ ជាភាសាខ្មែរ ERN ជាភាសាខ្មែរគឺ 00294814, ហើយនៅក្នុងសំណៅជាភាសាខ្មែរនេះ យើងឃើញថា កិច្ចសម្ភាសន៍នេះ ត្រូវធ្វើបញ្ចប់នៅថ្ងៃទី២៦ មីនា ឆ្នាំ២០០៩។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ ដើម្បីជាកំណត់ត្រាតុលាការ គឺថាជាភាសាបារាំងគឺថា ប្រហែលជាមានបញ្ហាបកប្រែ ព្រោះថា ថ្ងៃទី២៤ ខែមីនា នៅចុងទំព័រ ERN ជាភាសាបារាំងនោះគឺ 00385211។ ប៉ុន្តែអ្នកស្រីសាក្សី ដោយសារសំណៅជាភាសាខ្មែរ ជាសំណៅដើម បើតាមអ្នកស៊ើបអង្កេតនោះគឺថា កិច្ចសម្ភាសន៍នេះបញ្ចប់នៅថ្ងៃទី២៦ មីនា តើអ្នកស្រីអាចនឹកឃើញទេ ចាំបានទេ?

[១០:១៤:១១]

**ឆ៖** ចាស នាងខ្ញុំមិនបានចាំថា មួយថ្ងៃ ឬមួយក៏ -- មួយពេលព្រឹក ឬមួយក៏ល្ងាចទេ ដូចហើយឬមួយក៏ស្អែកបន្តទៀតទេ នាងខ្ញុំអត់បានចាំត្រង់ហ្នឹង។

**ស៖** មិនបញ្ហាអ្វីទេ អ្នកស្រីសាក្សី ខ្ញុំគ្រាន់តែចង់រំឭកការចងចាំរបស់អ្នកស្រីតែប៉ុណ្ណោះ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក្តី យើងទាំងអស់គ្នាឯកភាពថា កិច្ចសម្ភាសន៍នេះគឺថា ស៊ីពេលយូរអ៊ីចឹងមែនទេ? អ្នកស្រីយល់ស្របទេ?

**ឆ៖** ចាស យូរបន្តិច។

[១០:១៥:០៣]

**ស៖** សូមអរគុណលោកស្រី។ នៅក្នុងក្របខ័ណ្ឌនៃចម្លើយរបស់អ្នកស្រីទៅលោកសហព្រះរាជអាជ្ញា លោកស្រីបានឆ្លើយជាច្រើនដងទាក់ទងទៅនឹងសេចក្តីសម្រេច ការជម្លៀសប្រជាជន អ្នកស្រីឆ្លើយថា៖ “អ្នកស្រីមិនដឹងថា សេចក្តីសម្រេច -- ការបញ្ជាជម្លៀសនេះមិនដឹងមកពីណាទេ ហើយមេរបស់អ្នកស្រីជាអ្នកប្រាប់អ្នកស្រី”។ សំណួរខ្ញុំដូចតទៅនេះ៖ តើអ្នកស្រីចាំថាអ្នកស្រីបានឆ្លើយយ៉ាងដូច្នេះនៅពេលលោកស្រីផ្តល់កិច្ចសម្ភាសន៍ទៅដល់អ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតដែរឬទេ? លោកស្រីនៅចាំទេថា អ្នកស្រីបានប្រាប់អ្នកសង្កេតថាអ្នកស្រីមិនចាំថាបទបញ្ជានេះមកពីខាងណានោះទេ។ ចាំដែរឬទេ?

**ឆ៖** ចាស ពេលនេះ នាងខ្ញុំចាំ ចាំថា ប្រជាជនជម្លៀសក៏នាងខ្ញុំមិនដឹងថា ពីណាមួយជាអ្នកបញ្ជាទេ ហាក់ដូចជាមានការរៀបចំហើយអ៊ីចឹងដែលនាងខ្ញុំទៅទាន់នោះ។

[១០:១៦:៣៦]

**ស៖** សូមអរគុណអ្នកស្រី។ ដើម្បីជាកំណត់ត្រាតុលាការ ខ្ញុំសូមយោងទៅនឹងប្រតិចារឹកដោយផ្នែកជាខ្មែរអាត់គឺថា D200/6.8 ERN ជាភាសាបារាំងគឺ 00835914, ERN ជាភាសាអង់គ្លេស 00834863, ERN ជាភាសាខ្មែរ 00833490។ ខ្ញុំសូមដកស្រង់ៗ សម្រង់មួយទៅសាក្សី។ សំណួរដែលចោទសួរដោយអ្នកស៊ើបសង្កេតនៅទំព័រនេះ នៅនាទីទី២០ ៤០សីហ្គុង លោក គូណែល អ្នកស៊ើបអង្កេតសួរដូចតទៅនេះ៖ “នៅពេលនោះ តើលោកបានឮប្រធានរបស់លោកនិយាយពីឈ្មោះអ្នកដែលចេញបញ្ជាឲ្យជម្លៀសប្រជាជនដែរឬទេ? ចម្លើយរបស់អ្នកស្រីគឺថា៖ ទេ អត់ដឹងទេ”។ អ្នកស្រី តើអ្នកស្រីនៅចាំថា អ្នកស្រីបានឆ្លើយយ៉ាងដូច្នេះដែរឬទេ នៅថ្ងៃទី២៤ មីនា ឆ្នាំ២០០៩ នោះ?

**ឆ៖** ចាស អ្នកស្រីសូមផ្តល់សំណួរម្តងទៀត នាងខ្ញុំដូចចាប់អត់ទាន់បាន។

**ស៖** ខ្ញុំទើបតែដកស្រង់ផ្នែកមួយនៃប្រតិចារឹកខ្មែរអាត់នៃកិច្ចសម្ភាសន៍របស់អ្នកស្រីជាមួយអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត។ ហើយសំណួរដែលគេសួរទៅអ្នកស្រីនៅក្នុងកិច្ចសម្ភាសន៍នេះគឺថា៖ “តើនៅពេលនោះអ្នកស្រីមានបានឮប្រធានរបស់អ្នកស្រីប្រាប់ឈ្មោះអ្នកដែលចេញបញ្ជាជម្លៀសប្រជាជនដែរឬទេ?” អ្នកស្រីបានឆ្លើយ៖ “ទេ ខ្ញុំមិនដឹងទេ”។ អ៊ីចឹងខ្ញុំគ្រាន់តែចង់បញ្ជាក់ជាមួយអ្នកស្រី តើអ្នកស្រីមានចាំថាបាន -- ថាអ្នកស្រីខ្លួនឯងផ្ទាល់នេះមានបានឆ្លើយយ៉ាងដូច្នេះដែរឬទេ នៅថ្ងៃទី២៤ មីនា ឆ្នាំ២០០៩?

**ឆ៖** ចាស នៅក្នុងកិច្ចសម្ភាសន៍ហ្នឹង ខាងក្រុមសង្កេតការណ៍បានសួរនាងខ្ញុំ នាងខ្ញុំអត់បានដឹងថា ពីណាមួយអ្នកបញ្ជាឲ្យប្រជាជននោះទេ តែនាងខ្ញុំនៅចាំថា នាងខ្ញុំឆ្លើយថា “អត់ដឹងមែន”។

[១០:១៩:៥៥]

**ស៖** សូមអរគុណ។ ឥឡូវហ្នឹង ខ្ញុំសូមចូលទៅនិយាយអំពីចំណុចមួយទៀតនៃនៃចម្លើយរបស់អ្នកស្រី។ អ្នកស្រីបានឆ្លើយថា អ្នកស្រីបាន -- នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ អ្នកស្រីបានជួបលោក ខៀវ សំផន នៅភ្នំអង្គរស្ស ហើយអ្នកស្រីបានបញ្ជាក់ទៅកាន់សហភាតាខ្ញុំអម្បាញ់មិញនេះ ថាឡានរបស់លោក ខៀវ សំផន បើតាមអ្នកស្រីចាំនោះគឺថាចេញដំណើរមកភ្នំពេញមុនអ្នកស្រី។ សំណួរខ្ញុំចង់ដឹងថា តើអ្នកស្រីដឹងថាឡានហ្នឹងទៅណាដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងថាឡានគាត់ចេញទៅច្រកណាទេ។

**ស៖** សូមអរគុណ។ បើសិនជាខ្ញុំសង្ខេបពីអ្វីដែលអ្នកស្រីបានរៀបរាប់ជូនតុលាការប៉ុន្មានថ្ងៃចុងក្រោយនេះ -- បន្ទាប់ពីបានស្នាក់នៅរយៈពេល ៣ថ្ងៃ នៅម្តុំខាងឧដុង្គជាមួយនិងក្រុមសិល្បកររបស់អ្នក

ស្រីនោះ អ្នកស្រីបានធ្វើដំណើរឆ្ពោះមកទីក្រុងភ្នំពេញ ហើយបន្ទាប់មកទៀតអ្នកស្រីបានមកដល់ពហុកីឡដ្ឋានជាតិ ហើយអ្នកស្រីស្នាក់នៅមួយយប់ ហើយបន្ទាប់មកទៀតអ្នកស្រីបានទៅក្រសួងឃោសនាការ។ តើខ្ញុំសង្ខេបពីខ្សែដំណើររបស់អ្នកស្រីហ្នឹងត្រឹមត្រូវដែរឬទេនៅពេលនេះ?

[១០:២១:៥៦]

**ឆ៖** ចាស នាងខ្ញុំចេញពីភ្នំអង្គរស្នួមក មកសម្រាកនៅវាលស្រែមួយមានខ្ទមស្បូវមួយយប់ចាស។ ការពិតទម្រាំចូលដល់ភ្នំពេញហ្នឹងអស់ពេលបួនយប់ហើយ។ ហើយចេញពីហ្នឹងមកមួយថ្ងៃចង់វាល់ល្ងាច នាងខ្ញុំមកអី -- មកសម្រាកនៅស្តាតហ្នឹងមួយយប់។ ថ្ងៃព្រឹកឡើងបាននាងខ្ញុំបានមកដល់កន្លែងឃោសនាការ។ អស់ចម្លើយហើយ។

**ស៖** សូមអរគុណ។ ពេលដំបូងនោះ នៅក្នុងពេលសវនាការថ្ងៃទី១៥ សីហា អ្នកស្រីបាននិយាយថា អ្នកស្រីមិនបានឃើញលោក ខៀវ សំផន នៅក្នុង -- ចេញពីនុំងមកអ្នកស្រីមិនបានឃើញគាត់ទេ ហើយនៅពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញា លោកស្រីបាននិយាយថា លោកស្រីបានជួបគាត់នៅ -- បានឃើញគាត់នៅក្រសួងឃោសនាការម្តងទៀត។ ខ្ញុំចង់ដឹងថា តើអ្នកស្រីបានឃើញគាត់ហ្នឹង នៅពេលណា? ប្រហាក់ប្រហែល អ្នកស្រីបានទៅដល់ក្រសួងឃោសនាការបន្ទាប់ពីបានស្នាក់នៅស្តាតអូឡាំពិកមួយយប់ តើអ្នកស្រីចាំថាអ្នកស្រីបានជួបលោក ខៀវ សំផន នៅក្រសួងឃោសនាការនោះរយៈពេលប៉ុន្មានក្រោយមក តើ ១ថ្ងៃ, ២ថ្ងៃ អ្នកស្រីចាំបានទេ ពេលដែលអ្នកស្រីឃើញលោក ខៀវ សំផន ជាថ្មី?

[១០:២៣:៥២]

**ឆ៖** ចាស នាងខ្ញុំចាំ ក្រោយពីនាងខ្ញុំទៅហើយ ថ្មើរល្ងាចខ្ញុំឃើញលោកនៅហ្នឹង ប៉ុន្តែគ្រាន់ថាទៅដល់ភ្លាមនាងខ្ញុំមិននៅមួយកន្លែងទេ រកឧសរកអីដាំបាយ ហើយម្យ៉ាងទៀតនាងខ្ញុំដើររកមើលបន្ទប់ងូតទឹកអីហ្នឹង។ ក្រោយមកបានឃើញលោកសម្រាកនៅកន្លែងហ្នឹងចាស។

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះ ចង់ដឹងថាតើអ្នកស្រីអាចប្រាប់ចំនួនថ្ងៃ បន្ទាប់ពីអ្នកស្រីបានមកដល់ក្រសួងឃោសនាការនោះ ប៉ុន្មានថ្ងៃក្រោយមកបានអ្នកស្រីបានជួបលោក ខៀវ សំផន។ បើតាមអ្នកស្រីចាំនោះ តើអាចជម្រាបជូនបានទេថា រយៈពេលប៉ុន្មានថ្ងៃ? ខ្ញុំមិនសូមឲ្យបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់ទេ គ្រាន់តែថា ចង់ប៉ាន់ស្មានថារយៈពេលប្រហែលប៉ុន្មានថ្ងៃ អ៊ីចឹងសូមអ្នកស្រីប៉ាន់ស្មានមើលតើប៉ុន្មានថ្ងៃបន្ទាប់ពីអ្នកស្រីមកដល់ក្រសួងឃោសនាការហើយនេះបានបានជួបលោក ខៀវ សំផន?

[១០:២៥:០១]

**ធ៖** ចាស នាងខ្ញុំសូមឆ្លើយនូវសំណួរហ្នឹង។ ប្រហែលជាពេលព្រឹក នាងខ្ញុំមកដល់ -- ប្រហែលម៉ោងប្រាំបីប្រាំបួន នាងខ្ញុំមកដល់ក្រសួងឃោសនាការ។ ចាស ហើយអ៊ីចឹងនាងខ្ញុំក៏មកនៅហ្នឹងដែរ ដាក់អីវ៉ាន់ ដាក់អីហើយៗរកខស រកអី ខ្លះមុជទឹក ខ្លះអីទៅ ខ្លះសម្អាតកន្លែងអីដេកទៅ តាមដែលគេដើរចង្អុលថា កន្លែងនេះអាចស្នាក់បានអីៗអ៊ីចឹងចាស។ ប្រហែលជា ជាក់ស្ដែងគឺក្នុងថ្ងៃហ្នឹងឯងដែលខ្ញុំបានជួបលោក ប៉ុន្តែវេលាល្ងាចទៅហើយ ចាស។ ថ្ងៃដែលនាងខ្ញុំទៅដល់។

**ស៖** សូមអរគុណ ដែលបានបញ្ជាក់បំភ្លឺនេះ នៅពេលដែលអ្នកស្រីបានជួបគាត់នោះ គឺថាតើអ្នកស្រីអាចបញ្ជាក់ទេថា នៅកន្លែងណា នៅក្នុងក្រសួងឃោសនាការនេះ ដែលអ្នកស្រីបានជួបគាត់។ អាចបញ្ជាក់បានទេ កន្លែងច្បាស់លាស់?

[១០:២៦:១០]

**ធ៖** ចាស នាងខ្ញុំបញ្ជាក់បាន នៅទាល់មុខ*ស្ទឹតយោ*លេខ៥។ ចាស ចន្លោះមានលំហធំដែរកន្លែងហ្នឹង។

**ស៖** ពេលដែលឆ្លើយទៅសហព្រះរាជអាជ្ញា អ្នកស្រីបានឆ្លើយថា អ្នកស្រីបានឃើញគាត់អង្គុយនៅលើគ្រែ។ តើកន្លែងដែលគាត់នៅនោះ ជាផ្នែកមួយនៃក្រសួងឃោសនាការ គឺថាជាកន្លែងដែលគេប្រើសម្រាប់ឲ្យបុគ្គលិកនៃក្រសួងឃោសនាការនុំងស្នាក់នៅ ឬក៏យ៉ាងម៉េច?

**ធ៖** ចាស កន្លែងហ្នឹងមិនទាន់មានការរៀបចំទេ គ្រាន់ថានេះជាកន្លែងជុំវិញក្រសួងឃោសនា-ការ ពិតមែនលោកស្រី ពីព្រោះអីៗកន្លែងថតរឿង កន្លែងហ្នឹង។ ក្រោយមកនាងខ្ញុំស្គាល់ថាកន្លែងថតរឿង ហើយបន្ទប់ធំជាងគេ។ *ស្ទឹតយោ* កន្លែងហ្នឹងនោះ ធំ ចាស។ ក្រោយមក បានគេរៀបចំក្មេងៗបុគ្គលិក និងពួកនាងខ្ញុំហ្នឹងចែកគ្នានៅតាមផ្ទះ ប៉ុន្តែនៅឆ្ងាយពីហ្នឹងប្រហែលជា១០០ម៉ែត្រចាស។ កន្លែងនេះ ជាកន្លែងធ្វើការ។

**ស៖** តើអ្នកស្រីចាំថា លោក ខៀវ សំផន ស្នាក់នៅក្នុងបន្ទប់ហ្នឹងរយៈពេលប៉ុន្មានថ្ងៃ? នៅពេលដែលលោកស្រីឆ្លើយទៅសហព្រះរាជអាជ្ញាប៉ុន្មានថ្ងៃមុននេះ លោកស្រីឆ្លើយថា គាត់ស្នាក់នៅទីនោះ២-៣ថ្ងៃ ហើយបន្ទាប់មកលោកស្រីលែងឃើញ -- លែងជួបគាត់ទៀតហើយ។ សំណួរខ្ញុំចង់ដឹងថា តើអ្នកស្រីចាំពីរយៈពេលដែលលោក ខៀវ សំផន បានស្នាក់នៅទីនោះដែរឬទេ?

[១០:២៨:១៩]

**ឆ៖** ចាស នាងខ្ញុំមិនបានចាំពិតប្រាកដ ប៉ុន្តែនាងខ្ញុំស្មានថា ប្រហែលជា២ ឬ៣ថ្ងៃ គាត់នឹងចេញទៅកន្លែងផ្សេង តែមិនដឹងឯណា ខ្ញុំអត់ដែលបានដឹងគាត់។ លោក ហ៊ូ នឹម ក៏គាត់បានចេញពីហ្នឹងដែរ អ្នកស្រី អត់មាននៅហ្នឹងទេ ព្រោះនៅម្ដុំនោះសុទ្ធតែក្មេងៗម្ដុំពួកខ្ញុំ។

**ស៖** នៅសវនាការថ្ងៃៗទី១៥ ខែ៨ ២០១២ អ្នកស្រីបានលើកឡើងអំពីវត្តមានរបស់លោក ហ៊ូ នឹម ក្នុងរយៈពេល៣ថ្ងៃនេះ នៅក្រសួងឃោសនាការ ហើយអ្នកស្រីបានបញ្ជាក់ថា គឺថា ហ៊ូ នឹម បានមកទីនុ៎ងដែរ។ ខ្ញុំសូមដកស្រង់ ទំព័រ១១១ ជាភាសាបារាំង ខ្ញុំសូមដកស្រង់។ ហើយយោងជាភាសាផ្សេងទៀតនោះ គឺម៉ោង១៥:៥៣ អ្នកស្រីបាននិយាយថា នៅពេលដែលអ្នកស្រីនិយាយអំពីលោក ហ៊ូ នឹម និយាយថា ពីដំបូងគាត់មកក្រសួងឃោសនាការពី ១ថ្ងៃ ឬក៏២ថ្ងៃ ហើយកន្លែងដែលគាត់ស្នាក់នៅនោះ មិនស្អាតទេ។ ខ្ញុំមិនដឹងថាគាត់ស្នាក់នៅកន្លែងណាទេ។

[១០:៣០:02]

នេះត្រង់ចំណុចនេះហើយដែលខ្ញុំចាប់អារម្មណ៍។ អ្នកស្រីទើបតែនិយាយអម្បាញ់មិញនេះថា កន្លែងនុ៎ងមិនបានរៀបចំបានស្អាតបាតទេ ពីដំបូងនោះ ហើយអ្នកស្រីក៏បានបញ្ជាក់ផងដែរថា នៅថ្ងៃនោះការ -- កន្លែងស្នាក់នៅនោះមិនស្អាតទេ។ តើការដែលកន្លែងស្នាក់នៅមិនស្អាតនោះ ជំរុញអ្នកឲ្យផ្សេង អ្នកដែលនៅទីនោះមួយចំនួននោះទៅរកកន្លែងផ្សេងស្នាក់នៅ។ តើអ្នកស្រីដឹងដែរឬទេថាមកពីមូលហេតុអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស លោកស្រីនៅសំណួរនេះលោស្រីចង់សួរថា រកកន្លែងឲ្យលោក ខៀវ សំផន និង ហ៊ូ នឹម ស្នាក់នៅ ឬមួយក៏ពួកខ្ញុំ? ខ្ញុំចង់សួរឡើងបន្តិចអ្នកស្រី។

**ស៖** ខ្ញុំនិយាយអំពីលោក ហ៊ូ នឹម ហើយនិងលោក ខៀវ សំផន។

**ឆ៖** ចាស ការពិតមែនលោកស្រី លោក ហ៊ូ នឹម, លោក ខៀវ សំផន គាត់នៅហ្នឹងរយៈ២ ឬ៣ថ្ងៃ ទាំងអស់គ្នាមែន ហើយពួកខ្ញុំក៏នៅហ្នឹងដែរ។ គ្រាន់ថាការសម្រាកផ្សេងៗគ្នា នៅក្នុងបរិវេណហ្នឹងវាធំចាស។ ហើយក្រោយមកបានពួកនាងខ្ញុំមានកន្លែងស្នាក់នៅជាផ្ទះ ជាបន្ទប់រៀងៗខ្លួនតាមពួកតាមក្រុមចាស។ ហើយលោកក៏ចេញពីហ្នឹងទៅមិនដឹងទៅទីកន្លែងណា។

[១០:៣២:០៩]

**ប្រធានអង្គជំនុំ៖**

លោកស្រីនៅមានសំណួរច្រើនទេ? លោកស្រីនៅចំណាយពេលវេលាប្រហែលប៉ុន្មានទៀតទៅ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសួរជិតចប់ហើយលោកប្រធាន ប្រហែលជាត្រូវការពីរបីនាទីទៀតទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តឲ្យចប់ ពីព្រោះដល់ពេលត្រូវសម្រាក ប្រសិនបើនៅត្រូវការពេលវែងយើងនឹងត្រូវសម្រាក តែបើពេលតិចយើងអនុញ្ញាតឲ្យលោកស្រីសួរបញ្ចប់ ដើម្បីឲ្យគាត់ សាក្សីហ្នឹងមានលទ្ធភាពអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១០:៣៣:០២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ្នកស្រីសាក្សី ខ្ញុំសួរអ្នកស្រីជិតចប់ហើយ។ សំណួរមួយទៀត អ្នកស្រីបាននិយាយថាអ្នកស្រីបានឃើញលោក ខៀវ សំផន នៅលើគ្រែដែក នៅក្រសួងឃោសនាការ។ អ្នកស្រីបានបញ្ជាក់ផងដែរថា អ្នកស្រីពុំបានពិភាក្សាជាមួយគាត់ទេ។ ទន្ទឹមនឹងនេះ តើអ្នកស្រីដឹងដែរឬទេថាគាត់ស្នាក់នៅក្នុងបរិវេណក្រសួងឃោសនាការនេះដែរឬទេ ក្នុងរយៈពេលដែលគាត់ស្នាក់នៅ៣ថ្ងៃនេះ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ក្រោយពី៣ថ្ងៃហ្នឹងលោកមិនបាននៅហ្នឹងទេ នេះជាការស្នាក់នៅបណ្ដោះអាសន្ន។ ចាស ទាំងខ្ញុំ ទាំងលោក ទាំងមហាជនទូទៅ ចាស អ្នកស្រី។

**ស៖** ខ្ញុំសូមសួរបញ្ជាក់មួយ។ នៅពេលដែលអ្នកស្រី -- ខ្ញុំសូមរៀបសំណួរឡើងវិញ តើអ្នកស្រី -- អ្នកស្រីនិយាយថា គាត់ស្នាក់នៅក្រសួងឃោសនាការរយៈពេល៣ថ្ងៃ តើអ្នកស្រីឃើញគាត់ហ្នឹងរាល់ថ្ងៃក្នុងរយៈពេល៣ថ្ងៃនេះ ដែរឬទេ ឬក៏អ្នកស្រីបានឃើញគាត់តែមួយដងទេក្នុងរយៈពេល៣ថ្ងៃនេះ?

**ឆ៖** ចាស នាងខ្ញុំឆ្លើយនូវសំណួរនេះ ពីព្រោះអីគាត់នៅហ្នឹងស្នាក់នៅហ្នឹងរយៈពេលប៉ុណ្ណឹង គឺខ្ញុំឃើញរាល់ថ្ងៃ គាត់បានសម្រាកនៅហ្នឹង ហើយបាយទឹកអី គឺក្រុមក្មេងៗម្ដុំនាងខ្ញុំហ្នឹងធ្វើទទួលគាត់។ ចាស អត់មានចុងភៅអីគាត់ទៅជាមួយផងចាស។ ចប់ហើយលោក។

[១០:៣៥:១២]

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមអរគុណដែលបានបំភ្លឺ។ ហើយសំណួរនេះ ជាសំណួរចុងក្រោយរបស់ខ្ញុំហើយ អម្បាញ់មិញនេះ។ អ៊ីចឹងសូមអរគុណច្រើន អរគុណច្រើនលោកប្រធាន។

[០៩:៣៥:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ លោកស្រី ស សៀក ការស្តាប់សក្ខីកម្មរបស់លោកស្រី រហូតដល់ពេលនេះបានចាប់ហើយ។ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោកស្រី ឬក៏គោលដៅដែលលោកស្រីមានបំណងចង់ទៅបានហើយ។

អង្គជំនុំជម្រះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រី ដែលបានធ្វើដំណើរមកពីឆ្ងាយ ហើយនិងចំណាយពេលវេលាដ៏មានតម្លៃ អស់ច្រើនថ្ងៃ អញ្ជើញចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ តាមការកោះហៅរបស់អង្គជំនុំជម្រះ ហើយបានខិតខំអស់ពីលទ្ធភាពក្នុងការផ្តល់សក្ខីកម្ម។ សក្ខីកម្មរបស់លោកស្រីនឹងរួមវិភាគទាន -- នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយសូមលោកស្រីមានសុខភាពល្អ ហើយជួបតែសំណាងល្អ ហើយនិងវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ឬក៏ទីកន្លែងដែលគាត់មានគោលបំណងចង់ទៅបានហើយ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនថា កិច្ចដំណើរការសវនាការនៅពេលបន្ទាប់ពីសម្រាកនេះគឺអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សីមួយរូបទៀត គឺដែលរហស្សនាម TCW-336 ដែលនឹងផ្តើមការតាំងសំណួរដោយក្រុមតំណាងសហព្រះរាជអាជ្ញា បន្ទាប់ពីសំណួរបឋមរបស់អង្គជំនុំជម្រះ។

ឥឡូវនេះ ដល់ពេលសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៧ នាទី ដល់ម៉ោង១០:៥៨នាទី)*

[១០:៥៨:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការជាបន្តដូចអង្គជំនុំជម្រះបានជម្រាបអម្បាញ់មិញនេះ ប៉ុន្តែអាចមានការភ័ន្តច្រឡំបន្តិច គឺសាក្សីដែលមានរហស្សនាម TCW-338 មិនមែន 336 ទេ។ មានការភ័ន្តច្រឡំបន្តិច សូមកែតម្រូវ។ ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១១:០១:០៩]

**ប្រធានអង្គជំនុំ៖**

សួស្ដីសាក្សី! សាក្សីបានស្ដាប់ការណែនាំរបស់មន្ត្រីរដ្ឋបាលតុលាការហើយ អំពីការប្រើប្រាស់ក្បាលមីក្រូក្នុងការឆ្លើយតប។ យើងរំឭកបន្ថែមថា នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួរដែលសួរ សូមលោករង់ចាំមើលក្បាលមីក្រូ ឬក៏សញ្ញាភ្លើងនៅខាងក្រោមនោះ ឲ្យភ្លើងសញ្ញាក្រហមសិន សឹមលោកឆ្លើយ ទើបប្រព័ន្ធសំឡេងដែលលោកឆ្លើយផ្ដល់សក្ខីកម្មហ្នឹងបានចូលក្នុងប្រព័ន្ធការបកប្រែភាសា ទើបធ្វើការកត់ត្រានៅក្នុងតុលាការនេះ។ អ៊ីចឹងនៅពេលដែលគេសួរ ភាគីពាក់ព័ន្ធ ឬអង្គជំនុំជម្រះសួរទៅលោក លោកបង្អង់បន្តិចសិន រង់ចាំមើលភ្លើង សញ្ញាភ្លើងក្រហមនៅចំពោះមុខ។ បានន័យថា ក្បាលមីក្រូធ្វើប្រតិបត្តិការសឹមឆ្លើយតប។

[១១:០២:០៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី តើលោកឈ្មោះមានអី? នាមត្រកូលនិងនាមខ្លួនរបស់លោក តើលោកអាច

ប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ?

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំបាទឈ្មោះ គឹម វុន ឈ្មោះបដិវត្តន៍ ឆោម។

**ស៖** បាទ អរគុណ។ ហើយតើលោកអាយុប៉ុន្មាន?

**ឆ៖** អាយុ៥៣ឆ្នាំ។

**ស៖** បាទ អរគុណ។ តើទីលំនៅរបស់លោកសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** លោកប្រធាន ខ្ញុំបាទរស់នៅភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន។

[១១:០៣:០៦]

**ស៖** បាទ អរគុណ។ ហើយតើលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំបាទជាមន្ត្រីរាជការ ជាអនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តប៉ៃលិន។

**ស៖** បាទ អរគុណ។ ហើយតើឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** បាទ ឪពុករបស់ខ្ញុំគាត់ស្លាប់បាត់ហើយ។ គាត់ឈ្មោះ ពេជ។

**ស៖** ត្រកូលអីទៅ ពេជ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកចាំសិន អង់បន្តិច លោកចាំមើលភ្លើងក្រហម សញ្ញាភ្លើងក្រហមជាសញ្ញាថា ឧបករណ៍នៅមុខលោកហ្នឹងធ្វើប្រតិបត្តិការ។ ទើបអាចទៅក្នុងប្រព័ន្ធបកប្រែភាសា ហើយនិងប្រព័ន្ធស្តាប់សំឡេងនៅទីនេះ។ ត្រកូលឪពុករបស់លោក?

**ឆ៖** ត្រកូលឈ្មោះ គឹម ពេជ។

**ស៖** បាទ អរគុណ។ ចុះម្តាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ម្តាយឈ្មោះ ទូច ស្តើង ប៉ុន្តែស្លាប់ទាំងពីរនាក់។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ប្រពន្ធរបស់លោកបច្ចុប្បន្ននេះ គាត់ឈ្មោះអី?

**ឆ៖** ប្រពន្ធបច្ចុប្បន្នឈ្មោះ មាស សំនៀង។

[១១:០៥:០២]

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានកូនតែម្នាក់ កូនស្រី។

**ស៖** បាទ អរគុណ។ ហើយលោកបានរៀនអក្សរខ្មែរទេ? ហើយបើរៀន រៀនដល់ថ្នាក់កម្រិតណាដែរ?

**ឆ៖** នៅសង្គមចាស់នៅក្មេង ដូច្នេះមិនសូវបានរៀនសូត្រច្រើនទេ បានរៀនតិចដែរ ប៉ុន្តែគិតជាកម្រិតថ្នាក់ទី៧។

**ស៖** លោកអាចអាន ឬអាចសរសេរអក្សរខ្មែរបានល្អទេសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំអាចសរសេរខ្មែរបានល្អ។

[១១:០៦:០៨]

**ស៖** បាទ អរគុណ។ លោក គឹម វុន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកបានដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី០០២នេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូបដែរ គឺលោក នួន ជា, លោក អៀង សារី និងលោកខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** បាទ អរគុណ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកបានស្បថរួចហើយនៅចំពោះមុខអ្នកតាដំបងដែក កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ កន្លងទៅនេះ មុននឹងលោកចូលមកផ្តល់សក្ខីកម្មនេះ តើពិតមែនដែរទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** ឥឡូវនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោក ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក គឹម វុន នៅក្នុងលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ ទន្ទឹមនឹងនេះ លោកក៏មានករណីយកិច្ចដូចខាងក្រោមនេះ៖

[១១:០៧:៥៣]

ក្នុងនាមជាសាក្សី លោកត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំ

ជម្រះនេះ គឺលោកត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះបានសួរលោក។ លើកលែងតែក្នុងករណីដែលឆ្លើយនឹងសំណួរ ឬក៏ធ្វើអត្ថាធិប្បាយណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ លោកជាសាក្សីត្រូវឆ្លើយតែការណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ បានចាំ ឬមានបទពិសោធន៍បានជួបប្រទះ ឬការធ្វើសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរឬទេ?

**ឆ៖** ខ្ញុំបានយល់អស់ហើយបាទ។

[១១:០៨:៥៥]

**ស៖** បាទ អរគុណ។ លោក គឹម វុន តើលោកមានដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ រយៈពេលកន្លងមក មុននឹងលោកមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃនេះ? ហើយប្រសិនបើមាន តើធ្វើសម្ភាសនោះប្រព្រឹត្តទៅប៉ុន្មានលើក? នៅទីកន្លែងណា? នៅពេលណា?

**ឆ៖** ខ្ញុំបានផ្តល់សម្ភាសចំនួនបីលើក ប៉ុន្តែនៅក្នុងឯកសារជាផ្លូវការនេះមានតែពីរលើកទេ។

**ស៖** លោកចាំទេថា លើកទី១ ធ្វើសម្ភាសជាមួយលោកហ្នឹងនៅកន្លែងណា? ហើយនៅថ្ងៃខែឆ្នាំណា?

**ឆ៖** លោកប្រធានខ្ញុំអត់ចាំទេ។ ប៉ុន្តែដឹងថាមានបីលើក។

[១១:១០:០២]

**ឆ៖** លោកប្រធាន ខ្ញុំអត់ចាំ ប៉ុន្តែដឹងថា មានបីលើក។

**ស៖** តើធ្វើនៅកន្លែងណាដែរ កាលធ្វើសម្ភាសជាមួយលោក ធ្វើនៅទីកន្លែងណា?

**ឆ៖** កន្លែងដែលខ្ញុំផ្តល់សម្ភាសគឺ នៅកន្លែងមន្ទីរប្រៃសណីយ៍ទូរគមនាគមន៍ខេត្ត។

**ស៖** លោកនិយាយថា ធ្វើសម្ភាសបីលើក ហើយឯកសារកំណត់ហេតុមានតែពីរលើក វាមានហេតុផលយ៉ាងម៉េចទៅ បានជាមានបញ្ហាដូច្នេះ?

**ឆ៖** សូមជម្រាបលោកប្រធាន នៅលើកទី៣ ខ្ញុំបាទ ចូលរួមសិក្ខាសាលាធ្វើផែនការវិនិយោគ។ ដល់អ៊ីចឹងខាងចៅក្រមអត់បានចាំខ្ញុំ អ៊ីចឹងគាត់ប្រញាប់មកធ្វើការកន្លែងផ្សេងវិញ។

**ស៖** អរគុណ។ ហើយនៅមុនពេលចូលមកកាន់ ចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបាន

ពិនិត្យមើល ឬក៏បានអានទូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោក ដែលបានធ្វើនៅជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតពីរដងកន្លែងមក ដើម្បីរំឭកការចងចាំដែរឬទេ?

[១១:១១:៤៥]

**ផ៖** ខ្ញុំបាទបានមើលខ្លះដែរ លោកប្រធាន។

**ស៖** ហើយបើតាមសមត្ថភាព ដែលលោកអាចដឹង អាចចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់សក្ខីកម្មរបស់លោក ដែលលោកបានអាន ឬក៏បានពិនិត្យមើលឡើងវិញហ្នឹង ដើម្បីរំឭកការចងចាំហ្នឹង គឺពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នា ឬក៏ស្របគ្នាទៅនឹងចម្លើយរបស់លោក ដែលបានធ្វើ -- ផ្តល់បទសម្ភាសន៍ ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុនៗនោះដែរឬទេ?

**ផ៖** ជម្រាបលោកប្រធាន ស្របគ្នា។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ សូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀត។

ហើយអង្គជំនុំជម្រះ សូមរំឭកផងដែរថា ពេលវេលាដែលបានបែងចែកជូនភាគី នៅក្នុងការតាំងសំណួរដេញដោលសាក្សីរូបនេះ គឺក្នុងភាគីនីមួយៗមានពេលវេលាតែមួយភាគបួនថ្ងៃ បានន័យថា បីពេលនៃដំណើរការសវនាការប៉ុណ្ណោះ ប្រសិនបើយើងចែកពេលវេលាពេលព្រឹកពីរពេល ពេលរសៀលពីរពេល។ អ៊ីចឹងភាគីនីមួយៗមានពេលវេលាតែបីពេលទេ។

ដូច្នេះសូមរំឭកបញ្ជាក់បញ្ហានេះ ដើម្បីឲ្យកិច្ចប្រឹងប្រែងក្នុងការជ្រើសរើស កំណត់យកនូវសំណួរដេញដោលដែលមានសក្តានុពល ដើម្បីជាការឲ្យដំណើរការប្រព្រឹត្តទៅឆាប់រហ័សនិងមានប្រសិទ្ធភាព។

សូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា!

[១១:១៣:៣៥]

**លោក វេង ហ៊ត់៖**

អរគុណលោកប្រធាន។ សូមគោរពលោកប្រធាន អង្គជំនុំជម្រះ សូមគោពក្រុមប្រឹក្សាចៅក្រម និងសូមគោរពលោក លោកស្រីទាំងអស់ ដែលបានចូលរួមនៅក្នុងអង្គសវនាការនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** សួស្តី លោក គឹម វុន! ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំនឹងសួរសំណួរលោកទាក់ទងជាមួយនឹងបញ្ហារោងពុម្ព។ ក៏ប៉ុន្តែប្រសិនបើសំណួររបស់ខ្ញុំ លោកយល់ថា លោកមិនយល់ លោកកុំរារែក លោកសួរខ្ញុំវិញ ឬក៏ឲ្យខ្ញុំសួរលោកម្តងទៀត។ សំណួរខ្ញុំនៅពេលនេះ ខ្ញុំចង់បញ្ជាក់នូវចំណុចដែលលោកបានប្រាប់ទៅសហចៅក្រមស៊ើបអង្កេតកាលពីលើកមុន លោកប្រាប់ថា៖ “នៅខែកុម្ភៈ ឆ្នាំ១៩៧១ ខ្ញុំចូលធ្វើការនៅរោងពុម្ពរណសិរ្ស នៅក្នុងស្រុកសន្ទុក តាមដងស្ទឹងជីនិត ដែលជាមូលដ្ឋានរបស់ ប៉ុល ពត។ អ្នកដែលគ្រប់គ្រងមន្ទីរនោះ គឺឈ្មោះ ប៉ង់”។

[១១:១៥:00]

ខ្ញុំសូមបង្ហាញឯកសារទៅដល់ភាគីគឺឯកសារលេខ 00357197 ជាភាសាខ្មែរ, ភាសាអង់គ្លេស 00365642 និង ERN ជាភាសាបារាំង 00485429។ ទាក់ទងនឹងអ្វីដែលលោកបានឆ្លើយនេះ ខ្ញុំក៏មានសំណួរ។ សូមសួរថា តើហេតុអ្វីបានលោកទៅធ្វើការនៅរោងពុម្ពមជ្ឈិម? ហើយហេតុអ្វីក៏លោកមិនទៅធ្វើការនៅកន្លែងផ្សេង?

**លោក គឹម វុន៖**

**ឆ៖** ពីព្រោះខ្ញុំ ក្នុងសម័យរណសិរ្សរួបរួមជាតិកម្ពុជា ថ្នាក់ដឹកនាំមានខាងផ្នែកថ្នាក់ស្រុក និងថ្នាក់មជ្ឈិមទៅធ្វើការនៅមូលដ្ឋាន។ ដូច្នេះខាងស្រុកមានមិត្តភក្តិ និងបងៗតែងតែមកល្បួងលោមខ្ញុំឲ្យចេញពីភូមិដើម្បីទៅធ្វើការងារស្រុក។ ប៉ុន្តែនៅសម័យនោះ ខ្ញុំធ្វើការនៅភូមិ នៅក្នុងអង្គការយុវជនយុវនារីស្នេហាជាតិ។ ហើយម៉្យាងទៀត សម័យនោះគឺថា ខ្ញុំអត់មានជម្រើសទេ ព្រោះន៎ម្តាយ។ មានតែម្តាយ ដល់អ៊ីចឹង អត់ដាច់ចិត្តទៅទេ។ ហើយបងៗមកអ៊ីចឹង ទាំងខាងស្រុក ទាំងខាងមជ្ឈិមមកបងៗមកពីភាគខាងជើង ដល់អ៊ីចឹងទៅ ខ្ញុំសម្រេចដេកគិតមើលទៅ នឹកថា បើទៅធ្វើកន្លែងមជ្ឈិមឲ្យដឹងថាកន្លែងណាដែលជាក់លាក់ ហ្នឹងមួយ ហើយអាចមកវិល មកលេងស្រុកកំណើតវិញបាន ហ្នឹងទី១។ ទី២ បើទៅធ្វើការស្រុក ធម្មតាស្រុក ទោះបីធ្វើមេធ្វើកូនក៏ដោយគឺថា នៅភាគច្រើននៅក្នុងកងកម្លាំងប្រដាប់អាវុធហើយ។ ដូច្នេះ បើនិយាយពីអតីតភាពរបស់ខ្ញុំគឺជា ក្មេងកំព្រា។

**ស៖** អរគុណលោក។ ខ្ញុំសូមសួរសំណួរលោក វុន បន្តទៀត។ ថាតើលោកមានជំនាញខាងៗរោងពុម្ពហ្នឹងដែរទេកន្លងមក ដែលលោកបានចូលទៅធ្វើការនៅទីនោះ?

ឆ៖ ខ្ញុំមិនទាន់មានជំនាញខាងផ្នែករោងពុម្ពទេ ប៉ុន្តែខ្ញុំអាចចេះសរសេរអក្សរខ្មែរបានស្អាត។ ខ្ញុំអាចនៅធ្វើការងារនៅការិយាល័យបាន។

សៈ កាលណោះ លោកមានអាយុប៉ុន្មានដែរបាទ?

ឆ៖ *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

សាក្សីអត់ទាន់ -- ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ កុំអាលទាន់ឆ្លើយបាទៗ។

**សួរដោយលោក វ៉េង ហ៊ត់៖**

សៈ ខ្ញុំសូមសួរលោកមួយសាទៀត។ ពេលដែលលោកធ្វើការនៅរោងពុម្ពនោះ លោកថាលោកគ្មានជម្រើសទេ។ អ៊ីចឹងខ្ញុំសួរថា តើលោកគ្មានជម្រើសហ្នឹងពេលនោះ លោកនៅអាយុប៉ុន្មានដែរបាទ?

[១១:១៩:០៦]

**លោក គឹម វុន៖**

ឆ៖ សម័យនោះ ខ្ញុំទើបតែអាយុជាង១០ឆ្នាំ។

សៈ នៅក្នុងចម្លើយរបស់លោក តាមរយៈអ្នកស៊ើបអង្កេត លោកបានប្រាប់ថា លោកមានអាយុ ១២ឆ្នាំ កាលណោះ។ ខ្ញុំចង់សួរថា ពេលនោះគេរើសក្មេងៗសុទ្ធតែក្មេងៗអាយុតូចៗ ដូចជាលោកឱ្យទៅធ្វើការរោងពុម្ព ឬក៏យ៉ាងម៉េចដែរបាទ? សូមអធ្យាស្រ័យលោក ចាំពេលឃើញភ្លើងក្រហមចាំឆ្លើយ។

ឆ៖ បាទ សូមជម្រាប នៅសម័យនោះក្មេងៗជាច្រើន ពិសេសបងប្អូនក្មួយខ្ញុំ គឺថាចូលមុនខ្ញុំទៅទៀត តែខ្ញុំជាប់រវល់នៅក្នុងភូមិ ការងារនៅក្នុងភូមិខ្ញុំអត់បានចូលទេ។ មែនទែនមានសាច់ញាតិជាក្មួយអីចូលមុនខ្ញុំទៀត កុមារ ប៉ុន្តែនៅធ្វើការខាងស្រុក។

សៈ ខ្ញុំសូមសួរលោកទៀត រួមទាំងលោកផង គឺក្មេងៗជាច្រើនទៅធ្វើការនៅរោងពុម្ពសុទ្ធតែជាកុមារ តើកុមារទាំងនោះរួមទាំងលោកផ្ទាល់នោះ លោកមានអារម្មណ៍យ៉ាងម៉េចដែរនៅស្ថានភាពដំបូងដែលលោកចូលទៅនោះ?

ឆ៖ បាទ ខ្ញុំអត់មានអារម្មណ៍យ៉ាងម៉េចទេ ព្រោះនៅធ្វើការហ្នឹងជាការចាត់តាំងគឺត្រូវតែ -- បើចាត់តាំងឲ្យធ្វើការងារអីហើយ គឺត្រូវតែធ្វើការងារដោយប្រាកដប្រជា។

[១១:២១:២៤]

សៈ អរគុណលោក ខ្ញុំបញ្ជាក់ទៅកន្លែងរោងពុម្ពរបស់លោកវិញ។ លោកថា រោងពុម្ពរបស់

លោកនៅស្រុកសន្ទុកតាមដងស្ទឹងជីនិត អ៊ីចឹងខ្ញុំចង់សួរឲ្យលោកផ្ដល់យោបល់ថា តើនៅរោងពុម្ពនោះនៅចម្ងាយប៉ុន្មានដែរពីកន្លែងរបស់ ប៉ុល ពត នៅហ្នឹង?

**ឆ៖** កន្លែងរោងពុម្ពហ្នឹងនៅឆ្ងាយច្រើនគីឡូម៉ែត្រដែរ ខ្ញុំមិនចាំ នៅក្នុងព្រៃធំ។

**ស៖** នៅពេលដែលលោកចូលធ្វើការនៅរោងពុម្ព តើរយៈពេលប៉ុន្មានដែរ ដែលលោកបានជួបលោក ប៉ង់?

**ឆ៖** មែនទែន ខ្ញុំត្រូវសម្រាកនៅមន្ទីរ ត-៤០ នៅបឹងល្វា ហើយបានបន្តដំណើរទៅឆ្លងស្ទឹងជីនិតទៅ ល-៣ ហើយបានឆ្លងពីហ្នឹងទៅ ល-៦៤ ទៅសម្រាកនៅហ្នឹង។

[១១:២២:៥៥]

**ស៖** ខ្ញុំចង់សួរលោកថា តើពេលណាដែលលោកជួប ប៉ង់ ហើយ ប៉ង់ ហ្នឹងទទួលខុសត្រូវនៅខាងរោងពុម្ពហ្នឹងដែរឬទេ?

**ឆ៖** តាមពិតមុនដំបូងខ្ញុំអត់បានជួប បងប៉ង់ ទេ ប៉ុន្តែដឹងថាកន្លែងហ្នឹងមន្ទីរ បងប៉ង់ ទទួលខុសត្រូវ។

**ស៖** ជំនាញរបស់លោកជាក់ស្ដែងពេលនុ៎ងលោកមានជំនាញផ្នែកអ្វីដែរ?

**ឆ៖** តាមការចាត់ចែងឲ្យធ្វើការហ្នឹង គឺខ្ញុំនៅខាងសរសេរ។ សរសេរមុនដំបូងសរសេរនៅលើក្រដាស ទ្រាប់កាបូនដើម្បីរៀនសរសេរអក្សរឲ្យស្អាត ក្នុងមួយច្បាប់ហ្នឹងយើងអាចសរសេរបាននៅលើក្រដាសធ្យូង ហើយបានជាបីច្បាប់ ហើយរៀនតែសរសេរហ្នឹងរាល់ថ្ងៃ។

[១១:២៤:១០]

**ស៖** លោកបានចាំទេ ថាតើលោកសរសេរអំពីអ្វីដែរនៅក្នុងអារម្មណ៍លោក ពេលនុ៎ងលោកសរសេរអំពីអ្វី?

**ឆ៖** សរសេរនៅពេលនោះ គឺខ្ញុំរៀនសរសេរនៅលើក្រដាស ប៊ិក និងក្រដាសហើយ ដាក់កាបូននៅពីក្រោម ធ្វើម៉េចរៀនសរសេរហ្នឹងឲ្យស្អាត់ ឲ្យអក្សរស្អាត ដើម្បីបានអក្សរល្អត្រឹមត្រូវតាមហ្នឹងហើយបានឈានទៅសរសេរលើផ្ទាំងស៊ីល។

**ស៖** លោកយល់ខ្លឹមសារនៃការសរសេរហ្នឹងទេ តើគេសរសេរអំពីអ្វី? លោកអាចបញ្ជាក់បានទេ? ជាឧទាហរណ៍។

[១១:២៥:០៩]

**ឆ៖** ឯកសារដែលខ្ញុំសរសេរធ្វើ។ មុនដំបូងធ្វើជាកូនសៀវភៅ តាមខ្ញុំចាំនៅពេលនោះ គឺកូនសៀវភៅនោះនិយាយពីរឿង កែវ ញ៉ិល។

**ស៖** សូមលោកបញ្ជាក់មួយសាទៀត អំមិញខ្ញុំចាប់អត់បានថា កូនសៀវភៅហ្នឹងគេសរសេរពីអ្វីដែរ?

**ឆ៖** កូនសៀវភៅដែលខ្ញុំរៀនសរសេរហ្នឹង គឺដូចខាងដើមខ្ញុំថា សរសេរនៅលើក្រដាសហ្នឹង ហើយផ្តិតឱ្យបានបីច្បាប់។ ដល់សរសេរចប់ហើយ បានយកមកចងក្រងធ្វើជាសៀវភៅ។ ហើយសៀវភៅនោះ តាមខ្ញុំចាំគឺ សៀវភៅនិយាយពី កែវ ញ៉ិល និយាយពីរឿងអ្នកតស៊ូនៅក្នុងខេត្តកំពង់ចាម នៅខាង -- ពីប្រវត្តិគាត់ធ្វើការពលកម្ម។

[១១:២៦:២៧]

**ស៖** អរគុណលោក។ នៅក្នុងរោងពុម្ពនេះ ហើយដែលលោកបានជួប ប៉ង់ នេះតើបុគ្គលិកនៅក្នុងរឿងពុម្ពទាំងអស់ រួមទាំងកុមារតូចៗដូចជាលោកហ្នឹងប្រហែលជាចំនួនប៉ុន្មានដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

លោកៗ អត់ទាន់ -- ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ។ លោកចងចាំឡើងវិញ ចាំៗមានសញ្ញាភ្លើងក្រហមសិន សឹមលោកចាប់ផ្តើមនិយាយណ៎ះ!

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** ខ្ញុំសួរលោកមួយសាទៀត។ លោកនិយាយខាងដើមអម្បាញ់មិញថា ប៉ង់ ជាប្រធាន និងជាអ្នកទទួលបន្ទុកខាងរោងពុម្ព។ ហើយឥឡូវនេះ ខ្ញុំសួរលោកថា តើរោងពុម្ពទាំងអស់នេះ ហើយជាមួយនឹងកន្លែងបោះពុម្ពនេះ មានបុគ្គលិកប៉ុន្មាននាក់? ហើយមានកុមារតូចៗដែលលោកបាននិយាយថា មានគេទៅធ្វើមុនលោកទៀតនោះ ហើយចំនួនប៉ុន្មានសរុប?

**លោក គឹម វុន៖**

**ឆ៖** មុនដំបូង គឺមានតែក្មេងពីរនាក់ទេ។ ទី១ ខ្ញុំ, ទី២ កុល។ ហើយក្រៅពីនោះ មានកូនសិស្សមកពីខាងខេត្តក្រចេះ ហើយបងៗជាគ្រូបង្រៀន។ សរុបទៅ មុនដំបូងមានគ្នាតែបួននាក់ទេ។

**ស៖** អរគុណលោក។ ខ្ញុំចង់សួរ ចង់ដឹងពីលោកវិញថា តើនៅក្នុងរោងពុម្ពហ្នឹង គេបោះពុម្ពហ្នឹង ប្រភេទឯកសាររបៀបម៉េចដែរ?

**ឆ៖** ឯកសារដែលខ្ញុំបានឃើញ ដូចជម្រាបពីខាងដើម គឺខ្ញុំបានឃើញតែឯកសារដែលគេចាត់ចែងឲ្យសរសេរ រៀនសរសេរដំបូងតែប៉ុណ្ណឹង។ ហើយក្រៅពីនោះនៅមានឯកសារជាច្រើនទាក់ទងនឹងការងាររណសិរ្ស ជាដំណឹងសម្រាប់ផ្តល់ទៅខាងវិទ្យុ។ ព្រោះនៅក្នុងរោងពុម្ពហ្នឹងក៏មានទូរលេខដែរសម្រាប់បញ្ជូនសារទូរលេខដែរ។ ច្រើនបងៗមកភាគខាងជើង មាន បងលឹម និង បងយឿង។

[១១:២៩:៣៧]

**ស៖** បាទ អរគុណ។ តើលោកមានបានឃើញ ឬក៏លោកធ្លាប់ឃើញមានឯកសារទស្សនាវដ្តីទង់បដិវត្ត យុវជន-យុវនារីបដិវត្ត បោះពុម្ពនៅទីនោះទេពេលនុ៎ង?

**ឆ៖** នៅទីនេះដែលខ្ញុំចាំ គឺច្រើនតែឯកសារទាក់ទងនឹងការងាររណសិរ្ស។

**ស៖** តើលោកដឹងព័ត៌មានទាក់ទងនឹងការងាររណសិរ្សនេះស្អីខ្លះ? សូមលោកជួយរៀបរាប់បន្តិចមក។

**ឆ៖** ការងាររណសិរ្សនៅពេលនោះ គឺមានជាដំណឹង ជាដំណឹងសមរភូមិ ជាសេចក្តីថ្លែងការណ៍ផ្សេងៗរបស់ថ្នាក់ដឹកនាំ ជាភាសាបារាំង ឬក៏សរសេរជាឡាតាំង។ ហ្នឹងទៅខាងផ្នែកទូរលេខ ប៉ុន្តែការងារខ្ញុំ ការងារខាងរោងពុម្ព គឺការងារមានតែរៀនសរសេរទេ។

**ស៖** ខ្ញុំចង់ដឹងដែរ ថាតើឯកសារទាំងនោះគេវាយជាអង្គុលីលេខ ឬក៏សរសេរដៃ ដែលយកមកបោះពុម្ពហ្នឹង?

**ឆ៖** ឯកសារនៅសម័យនោះ ភាគច្រើនសរសេរដោយដៃ។ សរសេរដោយដៃ គេចម្លងដាក់កាបូន និងសរសេរដៃលើផ្ទាំងស៊ីល ហើយបោះពុម្ព។

**ស៖** លោកដែលធ្លាប់ពិនិត្យមើលឯកសារទាំងនោះ ឬមួយក៏ធ្លាប់ស្តាប់អំពីព័ត៌មាននៃឯកសារទាំងនោះដែរឬទេ?

**ឆ៖** ឯកសារទាំងនោះ ខ្ញុំមានទាំងខ្លឹមសារឲ្យយល់ហើយ ទើបខ្ញុំរៀនសរសេរ។

[១១:៣២:២៩]

**លោក វ៉េង ហ៊ាត់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន សុំបង្ហាញឯកសារមួយដែលមានៗលេខសម្គាល់ E3/637។ ERN ជាភាសាខ្មែរ 00442332, ERN ជាភាសាអង់គ្លេស 00740938, ERN ជាភាសាបារាំង 00752174។ ខ្ញុំសូមអានជូនសាក្សីតែម្តង។ ប្រសិនបើសាក្សីដឹងខ្លឹមសារហើយ ខ្ញុំនឹង

ស្សួរអំពីការបោះពុម្ពតទៅទៀត។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** នៅក្នុងខ្លឹមសារចុងក្រោយឯកសារទាំងនេះ ស្រែកថា "ជយោ! ប្រជាជន និងកងកម្លាំងប្រដាប់អាវុធ ប្រជាជនរំដោះជាតិកម្ពុជាទូទាំងប្រទេសដ៏អង់អាចក្លាហាន" នេះពាក្យមួយ។ ពាក្យទី២ "ជយោ! ជ័យជម្នះដ៏អស្ចារ្យរបស់ប្រជាជន និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា នៅគ្រប់សមរភូមិ"។ លោកបាននិយាយអម្បាញ់មិញថា លោកបានអាន -- ហើយនិងបានស្តាប់ទាំងខ្លឹមសារ តើខ្លឹមសារនេះ លោកបានអាន ហើយនិងត្រូវបានគេបោះពុម្ពនៅក្នុងរោងពុម្ពនុ៎ងដែរឬទេ? ខ្លឹមសារវាលោកឮទេ?

[១១:៣៤:៥៤]

**ប្រធានអង្គជំនុំ៖**

លោក គឹម វុន ឆ្លើយ! លោកអាចឆ្លើយបានទេ?

បើឆ្លើយមិនបាន ដោយសារមិនចងចាំ សូមលោកឲ្យតំណាងសហព្រះរាជអាជ្ញាជាតិហ្នឹង តាំងសំណួរលោកសាឡើងវិញ សាជាថ្មីម្តងទៀត។

**លោក គឹម វុន៖**

បាទ សូមសួរម្តងទៀត។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** អរគុណលោក គឹម វុន។ ខ្ញុំព្យាយាមសួរឲ្យលោកស្តាប់តទៅទៀត។ នៅក្នុងខ្លឹមសារនេះ គឺពាក្យថា "ជយោ! ប្រជាជន និងកងកម្លាំងប្រដាប់អាវុធ ប្រជាជនរំដោះជាតិកម្ពុជាទូទាំងប្រទេសដ៏អង់អាចក្លាហាន។ ជយោ! ជ័យជម្នះដ៏អស្ចារ្យរបស់ប្រជាជន និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានៅគ្រប់សមរភូមិ"។ តើពាក្យនេះ លោកធ្លាប់ឮ ហើយត្រូវបាន លោកយល់ថាត្រូវបានបោះពុម្ពនៅរោងពុម្ពដែលលោកធ្វើការនេះដែរឬទេ?

**លោក គឹម វុន៖**

**ឆ៖** កន្លែងនេះ ខ្ញុំមិនចាំដែរ។

**ស៖** ខ្ញុំសួរមួយសាទៀត។ លោកៗមិនចាំរឿងបោះពុម្ព ឬក៏លោកមិនដែលឮគេនិយាយពាក្យហ្នឹង?

[១១:៣៦:៥៦]

**ធ៖** ពាក្យ “ជយោ!” នេះ ទាំងពីរនេះ គឺធ្លាប់ប្រើជាទូទៅនៅក្នុងសម័យរណសិរ្ស។

**ស៖** អរគុណលោក។ ខ្ញុំៗនឹងអានខ្លឹមសារមួយទៀតជូនលោក នៅក្នុងឯកសារ E3/637 ដដែល។ ខ្ញុំអានខ្លឹមសារទេ ដើម្បីឲ្យលោកយល់ថា តើខ្លឹមសារនេះ ត្រូវបានបោះពុម្ពនៅក្នុងរោងពុម្ពហ្នឹងដែរឬទេ? ខ្លឹមសារខ្ញុំសូមអានជូនលោកតែម្តង។ នៅក្នុងឯកសារខ្មែរ ERN 00442328, ERN ជាភាសាអង់គ្លេស 00740933, ERN ជាភាសាបារាំង 00752170។ ឯកសារទាំងនេះ ខ្ញុំសូមជូនសាក្សីស្តាប់ដូចតទៅ៖ “អាតន្ទ្រីខ្មោរបស់អា ច័ន្ទ រង្សី និងកម្លាំងជំនួយរបស់ខ្មាំងជាច្រើនកងទៀត ត្រូវកម្ទេចស្លាប់ របួស រត់ចោលជួរ និងចាប់ជាឈ្លើយ។ តាមស្ថិតិជាបឋម កម្លាំងរបស់ខ្មាំង១.៥៥០ក្បាលនោះត្រូវបានអា -- ក្នុងនោះមាន អាស័ក្តិ៥, អាស័ក្តិ៣, អាស័ក្តិ២, និង១ រាប់សិបក្បាលត្រូវយើងកម្ទេច។ ប្រជាជនរាប់ម៉ឺននាក់ត្រូវបានរំដោះ”។ ចំណុចខាងក្រោម “អំពីកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាយើង ក្នុងនោះប្រាំមួយទីតាំងសំខាន់ៗត្រូវបានរំដោះ ហើយកម្លាំងរបស់ខ្មាំងចំនួន១.២០០ក្បាល ត្រូវកម្ទេច”។ ខ្ញុំសូមសួរលោកថាតើ បើលោកមិនចាំនៅក្នុងការបោះពុម្ពនេះទេ តើលោកធ្លាប់ឮពាក្យនេះ ដែលត្រូវបានគេរៀបចំនៅក្នុងរោងពុម្ពហ្នឹងដែរឬទេ?

[១១:៣៩:៤០]

**ធ៖** តាមការពិតនៅសម័យនោះ យើងប្រើទាំងផ្សាយវិទ្យុ យើងប្រើទាំងផ្សាយក្នុងទស្សនាវដ្តី។

**ស៖** អរគុណលោក គឹម វុន។ ខ្ញុំតសំណួរទៅមុខបន្តិចទៀត។ ក្រោយពីការបោះពុម្ពឯកសារហើយ តើគេចែកចាយឯកសារហ្នឹងទៅណាទៀត? លោកបានដឹងទេ?

**ធ៖** ឯកសារនេះត្រូវបានយកទៅផ្សាយនៅឯមូលដ្ឋានរំដោះ។

**ស៖** លោកចងចាំទេពេលនុ៎ង តើអ្នកណាមកប្រមូលឯកសារដើម្បីយកទៅផ្សព្វផ្សាយនៅតាមមូលដ្ឋានរំដោះ?

**ធ៖** សៀវភៅដែលបានពុម្ពហើយនីរសារគេទៅយកពីកន្លែងរោងពុម្ពយកបញ្ជូនទៅឲ្យមូលដ្ឋាន។

**ស៖** តើលោកធ្លាប់ចូលរួមចែកផ្សាយឯកសារនេះដែរឬទេ?

**ធ៖** ជាធម្មតានៅក្នុងសម័យរណសិរ្សបានបែងចែកការងារនោះច្បាស់លាស់ អ្នកណាធ្វើការងារអីអ្នកនោះដឹង អ្នកណាមិនធ្វើការនោះអ្នកនោះមិនត្រូវដឹងទេ។ ដូច្នេះ ខ្ញុំមិនមែនអ្នកបែងចែកទេ ខ្ញុំជាអ្នកធ្វើការនៅរោងពុម្ព។

**ស៖** ខ្ញុំចង់សួរថា ដោយសារមូលហេតុឯកសារហ្នឹងជាឯកសារសម្ងាត់ ឬមួយក៏យ៉ាងម៉េចបាន លោកអត់មានសិទ្ធិនៅក្នុងការចែកចាយហ្នឹង?

**ឆ៖** តាមពិតទៅការងារខ្ញុំនៅក្នុងរោងពុម្ព ខ្ញុំអត់ដែលចេញទៅក្រៅផង មានតែនីរសារទេដែលគេចេញទៅក្រៅបាន។

**ស៖** អរគុណលោក។ លោកថា លោកមិនអាចចេញពីមូលដ្ឋានរោងពុម្ពបាន មានគេហាមឃាត់លោក ឬមួយក៏យ៉ាងម៉េចដែរ? សូមលោកជួបបញ្ជាក់មើល៍។

[១១:៤៣:០២]

**ឆ៖** ធម្មតានៅសម័យនោះ យើងត្រូវរក្សាការសម្ងាត់ បើបែកការសម្ងាត់គឺយន្តហោះទម្លាក់។ យន្តហោះអាមេរិកាំងនឹងទម្លាក់លើមន្ទីរ។ ដូច្នេះត្រូវតែស្ងាត់ ហើយអ្នកណាត្រូវចេញ ចេញ អ្នកណាអត់ត្រូវចេញ គឺអត់ទៅទេ។ គឺយន្តហោះទម្លាក់តែម្តង ហើយកម្លាំងមនុស្សក៏មិនត្រូវដើរទៅណាឆ្ងាយ អ្នកណាធ្វើអី គឺនៅហ្នឹង កន្លែងនោះ។

**ស៖** អ្នកណាប្រាប់លោក អ្នកណាមួយប្រាប់លោកថា ការងារនេះជាការសម្ងាត់ ហើយមិនឲ្យយើងចេញទៅឆ្ងាយហ្នឹង អ្នកណានៅពេលនោះ?

**ឆ៖** អ្នកទទួលខុសត្រូវដូចខ្ញុំបាននិយាយហើយ គឺមុនដំបូងមានគ្នាតែបួននាក់ទេ ក្រោយមកបានមានគ្នាច្រើន។ ហើយអ្នកនៅកន្លែងនៅកន្លែងរោងពុម្ពតែម្តង គឺ បងបាន គាត់សាស្ត្រាចារ្យ។ គាត់បានណែនាំ ការដឹកនាំសព្វបែបយ៉ាងនៅលើគាត់។

[១១:៤៤:៣៩]

**ស៖** ឥឡូវនេះខ្ញុំចូលសំណួរមួយទៀត ទាក់ទងនឹងការជាក់ស្តែងរបស់លោកវិញម្តង។ ក្នុងនាមឬក៏ក្នុងសមត្ថភាពរបស់លោកជាកុមារតូចអាយុ១២ឆ្នាំ តើលោកធ្វើការជាក់ស្តែងនៅទីនោះ ១អាទិត្យប៉ុន្មានថ្ងៃ? ហើយ ១ថ្ងៃលោកបានសម្រាកប៉ុន្មានម៉ោងដែរបាទ?

**ឆ៖** ក្នុងសម័យសង្គ្រាមយើងត្រូវបែងចែកការងារច្បាស់លាស់ មិនថាកុមារ ឬមនុស្សធំ ក្នុងសម័យនុ៎ងគឺ យើងត្រូវជួយធ្វើការងារគ្នាចុះឡើង ដាក់វេនគ្នាជាដាំបាយ ជាដងទឹក។ បើក្រៅពីការងាររៀនសរសេរ គឺមានតែការងារជីវភាព ព្រោះយើងនៅក្នុងព្រៃ យើងត្រូវសម្អាតអនាម័យ ការការពារសុខភាព ត្រូវហូបទឹកឆ្អិន មានបង្គន់ មានបត់ជើងតូច ជើងធំ។ បើមិនសម្អាត មិនអីចឹងទេ មិនដាក់វេនគ្នាធ្វើអីចឹងទេ យើងនឹងឈឺ ព្រោះយើងនៅក្នុងព្រៃស្រោង ព្រៃខ្ពស់ ហើយសុទ្ធតែមូស ហើយអត់ប៉ាន

ដុតភ្លើងទៀត។ ដូច្នេះត្រូវមានមុង ត្រូវមានអង្រឹង ហើយពិសេសការប្រុងប្រយ័ត្នយន្តហោះហ្នឹងតែម្តង។ ហើយការធ្វើការងារគឺមានម៉ោងពេលច្បាស់លាស់ ហើយចែកគ្នា។ ប៉ុន្តែដល់ពេលសម្រុកធ្វើការងារមែនទែន គឺយើងមិនមានម៉ោងពេលអីទេ ព្រោះត្រូវធ្វើការងារចាំបាច់ត្រូវធ្វើឲ្យហើយហ្នឹង នៅសល់តិចតួច យើងមិនគិតពីពេលវេលាទេ។

[១១:៤៦:៥២]

**ស៖** ខ្ញុំសូមសួរលោកតទៅទៀត។ ក្រៅពីការងារដែលលោកធ្វើការមមាញឹក ហើយលោកនៅតូចទៀត តើលោកបានជួបមេដឹកនាំរណសិរ្សសំខាន់ៗនៅពេលនោះ គឺមានអ្នកណាខ្លះ? សូមលោកជួយរៀបរាប់បន្តិចមក។

**ឆ៖** មេដឹកនាំដែលខ្ញុំស្គាល់ថាជាអ្នកដឹកនាំសម័យនោះ គឺបងហែម។

**ស៖** ខ្ញុំស្តាប់អំមិញអត់សូវបានទេ។ សូមលោកជួយបញ្ជាក់ម្តងទៀត ថាតើមេដឹកនាំពេលនោះដែលលោកឃើញជាក់ច្បាស់ហ្នឹងគឺឈ្មោះអី? ឈ្មោះបដិវត្តន៍ហើយបច្ចុប្បន្នហ្នឹង -- ឬមួយក៏លោកដឹងថាឈ្មោះអីពិតប្រាកដ? សូមលោកជួយបញ្ជាក់មួយសាទៀត។

**ឆ៖** ក្នុងសម័យនោះដោយខ្ញុំនៅក្មេង ខ្ញុំស្គាល់តែ បងហែម ដែលអ្នកចេញចូលកន្លែងនោះម្តងៗ។ ឯក្រោយមកទៀត ទើបខ្ញុំដឹងថា បងហែម គឺលោក ខៀវ សំផន។

**ស៖** ពេលដែលលោកៗជួប បងហែម ជាឈ្មោះសម្ងាត់នោះ តើលោកជួបនៅកន្លែងណា ហើយកាលៈទេសៈហ្នឹងគាត់កំពុងតែធ្វើអី? ឬក៏លោកធ្វើអី? ទី១ ខ្ញុំសួរលោកថា តើជួបកន្លែងណា? ហើយពេលនុ៎ងគាត់មកធ្វើអី? បាទ សូមលោកជួយបញ្ជាក់បន្តិច។

[១១:៤៨:៥៩]

**ឆ៖** តែង -- ពេលនោះ បងហែម មកកន្លែងរោងពុម្ព។ ជួនកាលគាត់មកសួរសុខទុក្ខអីអីចឹងទៅ មានយកបន្លែ ឬក៏ចំណីអីមកឲ្យក្មេងៗ និងឲ្យអ្នករោងពុម្ពហ្នឹងហូបខ្លះ ហើយលើកទឹកចិត្តអំពីការតស៊ូហ្នឹង ក្រោមការដឹកនាំរបស់សម្តេចឪ។

**លោក វេង ហ៊ាត់៖**

អរគុណលោកប្រធាន។ ខ្ញុំសូមបញ្ចប់សំណួរខ្ញុំប៉ុណ្ណេះ ហើយឲ្យសហការី ឃីត គាត់ជួយបន្តបាទ។ សូមអរគុណ។

[១១:៥០:២១]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមធ្វើការបង្ហាញខ្លួន។ ខ្ញុំឈ្មោះ ឃីត រេយ៍ន័រ ហើយខ្ញុំជាមេធាវីមកពីខាងប្រទេសអង់គ្លេស។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកសាក្សី គឹម វុន។ ខ្ញុំចង់ធ្វើការចោទសួរសំណួរលោកមួយចំនួន ហើយខ្ញុំស្នើសុំឲ្យលោកធ្វើការបញ្ជាក់។ ទី១ គឺយើងនិយាយអំពីចម្លើយរបស់លោកទាក់ទងនឹងថ្នាក់ដឹកនាំ។ កាលពីប៉ុន្មាននាទីមុននេះ លោកបាននិយាយថា រណសិរ្សរួមបញ្ចូលទាំងខាងសមរភូមិ និងថ្នាក់ដឹកនាំ ដែលនិយាយ -- ដែលសរសេរជាភាសាបារាំង រួមទាំងទូរលេខផងដែរ។ ថាតើគេឲ្យលោកធ្វើការនៅខាងបោះពុម្ពចាប់តាំងពីឆ្នាំ៧០ហ្នឹងគឺ តើញឹកញាប់ប៉ុនណាដែរ? ថាតើសេចក្តីប្រកាសព័ត៌មាន ឬក៏សេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំហ្នឹង គឺគេយកមកខាងមកខាងរោងពុម្ពហ្នឹង ញឹកញាប់ប្រហែលប៉ុនណាដែរ?

[១១:៥១:៤៤]

**លោក គឹម វុន៖**

**ឆ៖** មែនទែនទៅកន្លែងរណសិរ្ស ឯកសារមានច្រើនណាស់។ ហើយថ្នាក់ដឹកនាំ ជួនកាលមិនដែលមកផ្ទាល់ទេ ព្រោះគាត់ជាប់រវល់ច្រើន។ ដូច្នេះ ច្រើនតែនីរសារយកមកឲ្យ។

**ស៖** តើលោកស្នាក់នៅរោងពុម្ពនេះ គឺចាប់ពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៥ គឺស្នាក់នៅកន្លែងដដែលតែមួយហ្នឹង ឬក៏លោកផ្លាស់ប្តូរទៅកន្លែងណាផ្សេងទៀត?

**ឆ៖** តាមពិតទៅ យើងត្រូវផ្លាស់ប្តូរកន្លែងច្រើនកន្លែងណាស់ ប៉ុន្តែតាមខ្ញុំចាំ ខ្ញុំដឹងបីកន្លែង។ កន្លែងទី១ នៅតាមស្ទឹងជីនិត ជិតភ្នំគោល។ បានក្រោយមកទៀតផ្លាស់មកកន្លែងថ្មីមួយទៀត ហៅមន្ទីរ ២៤។ ហើយបានក្រោយមកទៀត ផ្លាស់មកនៅប-២០ ហើយក្រោយ៧៥ គឺផ្លាស់នៅមកជិតស្ពាតអូរឡាំពិក។

**ស៖** ដើម្បីបញ្ជាក់ច្បាស់ ខ្ញុំសូមបញ្ជាក់ឡើងវិញ គឺលោកធ្វើការងារពាក់ព័ន្ធនឹងខាងបោះពុម្ព គឺចាប់ពីឆ្នាំ១៩៧១ រហូតដល់ឆ្នាំ១៩៧៥ នៅពេលដែលលោកធ្វើការនៅជិតស្តាតអូឡាំពិក។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវបាទ។

[១១:៥៤:០៦]

**ស៖** នៅក្នុងរយៈពេលនេះគឺឆ្នាំ៧១ ដល់ ៧៥ នេះ តើអ្នកណាជាអ្នកសម្រេចទៅលើការបោះពុម្ពផ្សាយ?

**ឆ៖** ជាលម្អិត ខ្ញុំមិនដឹងថាអ្នកណាដែរ។ ប៉ុន្តែច្រើនតែយើងបានឯកសារហ្នឹងមកតាមៗនីរសារយកមកឲ្យ។ បើយកមកឲ្យផ្ទាល់ -- ថ្នាក់ដឹកនាំយកមកឲ្យផ្ទាល់ កម្រយកមកឲ្យផ្ទាល់ណាស់ ច្រើនតែមាននីរសារយកមកឲ្យ។

[១១:៥៥:00]

**ស៖** លោកក៏បានបញ្ជាក់ផងដែរថា មានព័ត៌មានដែលត្រូវផ្សព្វផ្សាយតាមវិទ្យុ។ ដូច្នេះ សំណួររបស់ខ្ញុំគឺថា តើស្ថានីយវិទ្យុហ្នឹងនៅម្តុំណាដែរ បើធៀបជាមួយនឹងរោងពុម្ពនោះ?

**ឆ៖** ស្ថានីយវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជាគឺនៅស្រុកចិនឯណោះ តាមខ្ញុំយល់ ព្រោះអង្គាល់ហ្នឹងយើងអាចធ្វើដំណឹងជាសរសេរវ៉ូម៉ាំងអ៊ីចឹង បញ្ជូនសារទៅឲ្យផ្សាយ។ ដោយឡែកនៅឆ្នាំ ១៩៧៣, ៧៤ ជិត ៧៥ នេះ មានបង្កើតវិទ្យុរណសិរ្សទីក្រុងភ្នំពេញនៅប-២០។ ដូច្នេះនៅជិតរោងពុម្ពខ្ញុំដែរ វិទ្យុផ្សាយសំឡេង។

**ស៖** លោកបានបញ្ជាក់ថា រោងពុម្ពហ្នឹងគឺនៅមន្ទីរប-២០ តើលោកអាចប្រាប់បានទេថាប-២០ហ្នឹងមានទីតាំងភូមិសាស្ត្រនៅតំបន់ណា? ឬក៏នៅកន្លែងណាដែរ?

[១១:៥៦:៣៤]

**ឆ៖** ប-២០ តាមខ្ញុំដឹងស្ថិតនៅក្នុងស្រុកស្ទឹងត្រង់ ក្នុងតំបន់ព្រៃដែលមានព្រៃកៅស៊ូ មានសម្បូរដោយចេកព្រៃ ហើយជាដីក្រហមមានជីជាតិ។

**ស៖** ខ្ញុំចង់សួរលោកបែបនេះទៅវិញ គឺថាលោកបានចូលទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ៧៥។ ខ្ញុំចង់ឲ្យលោកប្រើប្រាស់ពេលវេលាឆ្នាំ៧៥ ខែមេសា។ ឥឡូវនេះថា តើមុនមេសា ៧៥ ហ្នឹងប្រហែលជាប៉ុន្មាននៅពេលដែលលោកដំបូងបំផុតថា តើមុន៧៥ ខែមេសានោះប្រហែលជាប៉ុន្មានដែរ ដែលលោកធ្វើការនៅប-២០?

**ឆ៖** រៀបរើវំដោះទីក្រុងទីក្រុងភ្នំពេញ ខ្ញុំនៅប-២០។ បានវិទ្យុពេលហ្នឹងខាងផ្នែករោងពុម្ពខ្ញុំមិនទាន់ទៅទេ ប៉ុន្តែគេយកវិទ្យុហ្នឹងទៅមុន។ ហើយក្នុងរវាងប្រហែលជាថ្ងៃ២០ ឬ២០ជាងបានខ្ញុំទៅដល់ភ្នំពេញ ដោយធ្វើដំណើរពីព្រែកក្តាមឡើងទៅពេទ្យព្រះកេតុមាលា ហើយឈប់សម្រាកនៅទីនោះមួយរយៈ។ យើងធ្វើដំណើរតាមទឹក ពីព្រោះផ្លូវលេខ៥ត្រូវកាត់ផ្តាច់ជាកង់អស់។ ដូច្នេះត្រូវធ្វើដំណើរ

តាមផ្លូវទឹកបានទៅដល់ភ្នំពេញ។

**ស៖** ថាតើក្នុងរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែ ថាតើលោកស្នាក់នៅបេ-២០ នៅស្ទឹងត្រង់ហ្នឹង ប្រហែលជាប៉ុន្មានថ្ងៃ ប៉ុន្មានខែ ឬក៏រយៈពេលប៉ុន្មានដែរ?

[១១:៥៩:១១]

**ឆ៖** នៅកន្លែងនោះ ខ្ញុំមិនចាំ ប៉ុន្តែប្រហែលជារាប់ឆ្នាំដែរ ព្រោះចេញពី២៤ មកៗនៅប-២០។

**ស៖** តាមការបកប្រែភាសាអង់គ្លេស គឺថាលោកស្នាក់នៅប-២០ រយៈពេល ១០ឆ្នាំ។ តើលោកចង់និយាយអ៊ីចឹងមែនអត់?

**ឆ៖** មិនមែនក្នុងរយៈពេល ១០ឆ្នាំទេ ព្រោះមែនទែនសង្គ្រាមនៅសម័យនោះធ្វើតែប្រាំឆ្នាំទេ។ រវាងរណសិរ្សរួបរួមជាតិកម្ពុជា និងលន់ នល់ និងអាមេរិក គឺធ្វើសង្គ្រាមតែប្រាំឆ្នាំទេ។ ដូច្នេះ នៅក្នុងចន្លោះប្រាំឆ្នាំហ្នឹង មិនដឹងជានៅប-២០ ហ្នឹងប៉ុន្មានឆ្នាំ ព្រោះខ្ញុំអត់ចាំ វាយូរពេកហើយ។

**ស៖** ទោះបីថា លោកនៅប្រហែលប៉ុន្មានក៏ដោយ ប៉ុន្តែអ្វីដែលខ្ញុំចង់សួរ ថាតើរោងពុម្ពហ្នឹងធ្វើការបោះផ្សាយរហូតឬមួយក៏យ៉ាងណាក្នុងរយៈពេលលោកស្នាក់នៅ ធ្វើការនៅរោងពុម្ពហ្នឹង?

[១២:០០:៣៦]

**ឆ៖** មែនទែនតាំងពីផ្លាស់មន្ទីរប៉ុន្មានកន្លែងហ្នឹងមក ខ្ញុំនៅធ្វើការកន្លែងរោងពុម្ពហ្នឹងរហូតៗមកដល់ភ្នំពេញ។ មកដល់ភ្នំពេញ ខ្ញុំមានការងារផ្សេងពីហ្នឹង ខាងរោងពុម្ពគឺគេប្រើៗបោះពុម្ពជាអក្សរ *ទីប៉ូ* ហើយ។ ខ្ញុំគ្រាន់តែជួយធ្វើការងារខ្លះ ដូចជាការសរសេរចំណងជើង ឬក៏ធ្វើ *ឃ្លីស្សេ* សម្រាប់ដាក់កាសែត ឬក៏ធ្វើក្របឯកសារផ្សេងៗ។ ដូច្នេះ ការងារខ្ញុំត្រូវទៅធ្វើការងារថតរូប សម្រាប់បម្រើកាសែត និងទស្សនាវដ្តី។ ដូច្នេះ ខ្ញុំចូលនៅក្នុងក្រុមនិពន្ធ ហើយមិនសូវពាក់ព័ន្ធនឹងបច្ចេកទេសខាងរោងពុម្ពនេះទៀតទេ គឺនៅប្រយោលវិញ។ ឯខាងការងារផ្ទាល់នៅភ្នំពេញរបស់ខ្ញុំ គឺទៅធ្វើកាសែតម្តង ទៅធ្វើទស្សនាវដ្តីរូបភាព។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះ ដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាបសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកសម្រាប់សាក្សីរូបនេះ នៅក្នុងអំឡុងពេល

សម្រាកពិសាអាហារថ្ងៃត្រង់ ហើយឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១២:០២:៣៣]

**លោក ហ្សាស្តើ ប៉ោះ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំសូមអនុញ្ញាតធ្វើការតាមដានកិច្ចសវនាការនីតិវិធីពីបន្ទប់ឃុំឃាំងជាន់ក្រោមដោយសារតែគាត់ឈឺក្បាល ឈឺខ្នង ហើយមិនអាចផ្តង់អារម្មណ៍បាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់សុំទៅតាមដានកិច្ចដំណើរការសវនាករពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ ដោយមូលហេតុមានបញ្ហាសុខភាពមិនអាចអង្គុយតាមដានដោយផ្ទាល់បាន។ អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ។ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:០៣:៣៨]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ។ ដោយ

ឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** លោក គឹម វុន ខ្ញុំបានសួរលោកអំពីប-២០ នៅស្ទឹងត្រង់ មុនពេលដែលលោកចូលមកភ្នំពេញ។ នៅប-២០ តើនរណាគេជាប្រធានរបស់លោក?

**លោក គឹម វុន៖**

**ឆ៖** ប្រធាននៅកន្លែងហ្នឹងមានតែ បងបាន។

**ស៖** តើ បាន នេះរាយការណ៍ទៅណាវិញដែរ?

**ឆ៖** បងបាន គាត់រាយការណ៍ទៅថ្នាក់លើទៀត មិនដឹងរាយទៅខាងណា ខ្ញុំមិនដឹងដែរ ព្រោះមានថ្នាក់លើតទៅទៀត។

[១៣:៣៤:២០]

**ស៖** នៅប-២០ តើអគារកន្លែងគេធ្វើការនោះ នៅកន្លែងណាដែរ?

**ឆ៖** កន្លែងនោះសម័យសង្គ្រាមមិនមានអគារទេ ព្រោះនៅជ្រកក្នុងព្រៃចេក ក្នុងដំណាំៗដែលដាំ។ ដូច្នេះការពារក្រែងយន្តហោះទម្លាក់គ្រប់បែកអីហ្នឹង នៅក្រោមដើមឈើ ឬក៏ក្រោមដើមកៅស៊ូ។ ដូច្នេះ សង់ធ្វើជាជំរំប្រក់ស្បូវ ឬក៏ -- ជារួមគឺប្រក់ស្បូវ ឬប្រក់ស្លឹកខាន់ម៉ា។

[១៣:៣៥:១២]

**ស៖** លោកថា បាន ជាប្រធានរបស់លោក តើនរណាគេជាអ្នកក្តោបរួបនៅប-២០ នេះ?

**ឆ៖** ក្តាប់រួបនៅនឹង ប៉ង់ ដដែល។

**ស៖** នៅពេលដែលលោកនៅស្ទឹងត្រង់ តើលោកធ្លាប់ឃើញៗមេដឹកនាំណាម្នាក់នៅប-២០ ដែរ ឬទេ?

**ឆ៖** នៅក្នុងឆ្នាំ៧៥ ជិតឈ្នះភ្នំពេញ មិនសូវឃើញផង ឃើញតែលោកស្រី យុន យ៉ាត។ ក្រៅពីនុំងមិនដែលឃើញ។

**ស៖** លោក គឹម វុន ខ្ញុំនិយាយអំពីប-២០ ខ្ញុំមិននិយាយអំពីឆ្នាំ៧៥ នៅពេលដែលលោកមកដល់ភ្នំពេញនេះនោះទេ។ ខ្ញុំនិយាយអំឡុងពេលឆ្នាំ -- មុនឆ្នាំ៧៥។ នៅប-២០ នៅស្ទឹងត្រង់ តើលោកធ្លាប់ឃើញមេដឹកនាំណាម្នាក់ដែរឬទេ?

[១៣:៣៦:៤៧]

**ឆ៖** នៅខាងដើមមានលោកស្រី យុន យ៉ាត។

**ស៖** នៅក្នុងការឆ្លើយរបស់លោកជាមួយនឹងចៅក្រមស៊ើបអង្កេត ឯកសារគឺ E3/380 ខ្មែរគឺ 00357200, បារាំង 00485433, អង់គ្លេសគឺ 00365645។ នៅត្រង់ទំព័រនុំង លោកបានលើកឡើងពាក្យថា "វគ្គសិក្សាមូលដ្ឋាន -- វគ្គអប់រំមូលដ្ឋាន"។ តើនៅប-២០ នេះ ធ្លាប់មានហៅប្រជុំរៀនសូត្រជាមូលដ្ឋានដែរឬទេ?

**ឆ៖** និយាយរួមទាំងយុទ្ធជន យុទ្ធនារីនៅក្នុងសម័យរណសិរ្ស ម្នាក់ណាក៏ត្រូវរៀននយោបាយដែរ រៀនពីកម្មវិធីនយោបាយរណសិរ្ស រៀនអំពីការប្រមូលកម្លាំង ដើម្បីធ្វើសង្គ្រាមរំដោះជាតិ។

**ស៖** តើលោកអាចជួយពន្យល់ឲ្យបានលម្អិតជាងនេះដែរឬទេ ដែលលោកហៅថាការប្រជុំប្រមូលកម្លាំងរំដោះប្រទេសនោះ? ហើយគេ នៅពេលរៀនសូត្រប្រជុំៗរៀនសូត្រនោះ តើមានពិភាក្សាបញ្ហាផ្សេងក្រៅពីហ្នឹងដែរឬទេ?

[១៣:៣៨:៤៩]

**ឆ៖** ក្នុងការរៀនសូត្រសម័យនោះ គឺផ្តោតទៅលើការធ្វើសង្គ្រាមរំដោះជាតិ។ ដូច្នេះគឺមានតែអប់រំរៀនសូត្រអំពីស្មារតីស្នេហាជាតិ ការលះបង់តស៊ូ។ ដល់យើងមិនបានទៅសមរភូមិមុខ យើងនៅខាងក្រោយ ឧទាហរណ៍ដូចខ្ញុំបាទនៅរោងពុម្ពអ៊ីចឹង គឺខិតខំធ្វើការងាររបស់ខ្លួនហ្នឹងឲ្យបានល្អ។ សាមគ្គី

ភាពគ្នាហ្នឹងនៅក្នុងផ្ទៃក្នុងហ្នឹងឲ្យបានល្អ ហើយក្នុងហ្នឹងទន្ទឹមសាមគ្គីភាព ក៏យើងនៅតែរក្សាការសម្ងាត់ទីកន្លែងរស់នៅ។ ព្រោះបើយើងមិនប្រយ័ត្នទេ សម័យនោះ គឺនឹងអាចមានគ្រោះថ្នាក់ច្រើន។ មិនថាតែយន្តហោះទេ សូម្បីតែថ្មើរជើង ឬកាំភ្លើងធំក៏អាចបាញ់ដល់យើងបានដែរ ឬមួយក៏កងកុម្ម៉ង់ដូហ្នឹងក៏អាចបំផ្លិចបំផ្លាញយើងបាន សម្លាប់យើងបានដែរ។ ដូច្នេះនៅក្នុងការអប់រំផ្សព្វផ្សាយ ការរៀនសូត្រគឺការពិគ្រោះពិភាក្សាគ្នានៅក្នុងការរៀនសូត្រ គឺផ្តោតទៅលើការប្រុងប្រយ័ត្ន ទៅលើការធ្វើការងារហ្នឹងឯង។

[១៣:៤០:១៦]

**ស៖** លោក គឹម វុន សូមអរគុណដែលលោកបានឆ្លើយលម្អិត។ តើនរណាគេជាអ្នកធ្វើបទឧទ្ទេសនាមនៅក្នុងការប្រជុំរៀនសូត្រនោះ?

**ឆ៖** នៅប-២០ តាមខ្ញុំចាំមានតែលោកស្រី យុន យ៉ាត។

**ស៖** នៅព្រឹកមិញលោកបានឆ្លើយត្រង់ចំណុចមួយថា លោកត្រូវបានគេលើកទឹកចិត្ត និងជំរុញក្នុងការងារ។ តើនេះជាលក្ខណៈនៃជីវិតការងាររបស់លោក ដែលត្រូវធ្វើដូច្នេះនៅប-២០ នៅស្ទឹងត្រង់នោះដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើនរណាគេជាអ្នកលើកទឹកចិត្ត ជំរុញទឹកចិត្តលោកនោះ?

**ឆ៖** ដូចខ្ញុំបាននិយាយពីខាងដើម ពីដំបូង គឺមាន បងហែម គឺគាត់ជាអ្នកលើកទឹកចិត្តដែរ ហើយក្រៅពីនោះមិត្តភក្តិដែលរួមធ្វើការងារ ក៏បងៗក៏មានការលើកទឹកចិត្តគ្នាដែរ មិនដែលៗថាលើកពេលណាមិនមានការលើកទឹកចិត្តទេ។ ព្រោះធម្មតាយើងនៅក្មេង បែកពីស្រុកភូមិឆ្ងាយយូរឆ្នាំ វាតែងតែមានអារម្មណ៍នឹងរំឭកដល់ស្រុកកំណើត ក្រុមគ្រួសារ។ ដូច្នេះហើយគឺថាមានតែការលើកទឹកចិត្តហាក់ដូចជាការលួងលោមគ្នាទៅវិញទៅមក ដើម្បីឲ្យធ្វើការងារហ្នឹងទៅបានល្អ ធ្វើការងារដោយយកចិត្តទុកដាក់មិនខ្ជីខ្ជា។

[១៣:៤២:៣១]

**ស៖** នៅពេលដែលលោក ហែម លើកទឹកចិត្ត ជំរុញទឹកចិត្តលោកនោះ តើគាត់បាននិយាយអ្វីខ្លះដែរ?

**ឆ៖** ការលើកទឹកចិត្តដូចខ្ញុំលើកពីខាងដើម។

**ស៖** នៅពេលដែលលោកនៅប-២០ នៅស្ទឹងត្រង់ តើមានអ្វីកើតឡើងដែរនៅក្នុងអំឡុងពេល

ចូលឆ្នាំខ្មែរនោះ?

**ឆ៖** ខ្ញុំដូចមិនដែលដឹងមានព្រឹត្តិការណ៍អីទេ ព្រោះសម័យបើមានព្រឹត្តិការណ៍ដែលយើងត្រូវប្រុងប្រយ័ត្ន គឺមានតែខ្មែរស។ ព្រោះពេលដែលជ័យជម្នះរបស់រណសិរ្សរួបរួមជាតិកម្ពុជា ចេះតែឈ្នះនៅលើសមរភូមិ ច្រើនតែមានបញ្ហាខ្មែរស។ ហើយខ្ញុំមិនដឹងថា ន័យថា "ខ្មែរស" ហ្នឹងយ៉ាងម៉េចទេ ប៉ុន្តែមានចលនាតស៊ូហ្នឹងតាំងពីជំនាន់ហ្នឹងមក។ តែងតែបាញ់បោះរំខាន ដោយអាវុធនៅផ្នែកខាងក្រោយ នៅសមរភូមិក្រោយ។

[១៣:៤៤:០៩]

**ស៖** លោកព្រឹកមិញបានលើកឡើងអំពីរណសិរ្ស ដែលរណសិរ្សនេះ គឺមានផ្តល់ព័ត៌មានពីសមរភូមិ។ ប្រសិនបើលោកយកការកំណត់ពេលវេលាណាមួយ នៅពេលដែលលោកមកដល់ភ្នំពេញ ក៏ប៉ុន្តែខ្ញុំចង់សួររយៈកាលមុននេះ តើលោកចាំទេ នៅពេលដែលលោកនៅស្ទឹងត្រង់នោះ ព័ត៌មានចុងក្រោយពីសមរភូមិនោះ គឺគេបានប្រាប់អ្វីខ្លះដែរ?

**ឆ៖** ព័ត៌មានចុងក្រោយ គឺមានតែមានការវាយសម្រុកនៅថ្ងៃ០១ មករា គឺជាទិសរបស់រណសិរ្សរួបរួមជាតិកម្ពុជា គឺវាយសម្រុកផ្តាច់ព្រ័ត្រចាប់ពីថ្ងៃ០១ មករា។

**ស៖** តើនៅថ្ងៃ០១ មករា នោះ តំបន់ណាខ្លះ ដែលត្រូវរងការវាយប្រហារនោះ?

**ឆ៖** ០១ មករា ប្រហែលជាសមរភូមិជុំវិញភ្នំពេញ។

**ស៖** នរណាជាអ្នកផ្តល់ព័ត៌មានពីសមរភូមិថា គឺតំបន់នៅជុំវិញភ្នំពេញនេះ?

**ឆ៖** អត្ថបទរបស់រណសិរ្សរួបរួមជាតិកម្ពុជាធម្មតានៅពេលនោះ តែងតែមានខ្សែបណ្តាញសារទូរលេខផ្ញើទាក់ទងគ្នាទៅមក មកថ្នាក់ដឹកនាំ។ ឯអត្ថបទដែលសរសេរគឺគេអាចនឹងស្រង់យកព័ត៌មានពីសមរភូមិពិត អំពីកម្លាំងពិត ដែលប្រយុទ្ធគ្នានៅលើសមរភូមិ។

[១៣:៤៦:៤៩]

**ស៖** នៅក្នុងថ្ងៃដែលលោករស់នៅក្នុងស្ទឹងត្រង់ តើលោកមានទទួលការណែនាំណាមួយថា គេឲ្យលោកទៅកន្លែងណា កន្លែងណីដែរឬទេ? ហើយគេមានណែនាំលោកថា ភារកិច្ចនោះ ត្រូវធ្វើអ្វីខ្លះទៀតដែរឬទេ នៅពេលដែលលោកចេញពីស្ទឹងត្រង់នោះ?

**ឆ៖** ដើម្បីត្រៀមរៀបចំទៅធ្វើការងារថ្មី ខាងប្រធានគ្រប់គ្រងនៅទីនោះ គេប្រាប់ថា ឲ្យយើងត្រៀម ព្រោះគេថា ជ័យជម្នះៗ ជិតមកដល់ហើយ។ ហើយមែនទែនវិទ្យុដែលនៅជិតហ្នឹង ក៏យើងបាន

ស្តាប់រាល់ថ្ងៃដែរ វិទ្យុរណសិរ្សក្រុងភ្នំពេញ ដែលនៅ -- បោះនៅ ប-២០ ហ្នឹង ក៏គេផ្សាយដែរ។ ប៉ុន្តែ មិនដឹងកន្លែងណាទេ ប៉ុន្តែខ្ញុំដឹងថា ទីតាំងច្បាស់ជាបោះនៅ ប-២០ ហ្នឹងឯង។ ព្រោះអ្នកពីរោងពុម្ពទៅ ទៅអានវិទ្យុនៅកន្លែងហ្នឹងដែរ។ ធ្វើការវិទ្យុផង ធ្វើការរោងពុម្ពផង។

**ស៖** នៅពេលដែលលោកនៅប-២០ មុនពេលដែលលោកចូលមកទីក្រុងភ្នំពេញ ការផ្សាយតាម វិទ្យុ លោកបានស្តាប់។ តើការផ្សាយវិទ្យុនេះ គេធ្វើឡើងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** វិទ្យុក្នុងសម័យនោះ គឺធ្វើក្នុងមួយថ្ងៃគេផ្សាយរហូតទៅ។ ផ្សាយតាមពេលម៉ោងត្រូវផ្សាយ ចាប់ពីម៉ោងប៉ុន្មានទល់ម៉ោងប៉ុន្មាន ប៉ុន្តែខ្ញុំមិនចាំ។ ប៉ុន្តែដឹងថា ចាប់ពីពេលព្រឹកទៅ គឺចាប់ផ្តើមផ្សាយ ផ្សាយដំណឹងសមរភូមិ។

[១៣:៤៩:០៦]

**ស៖** តើសំឡេងនៅក្នុងពេលផ្សាយក្នុងវិទ្យុនោះ សំឡេងនរណាគេដែរ ដែលជាអ្នកផ្សាយ?

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន សាក្សី! អត់ទាន់មាន -- ចាំភ្លើងក្រហមសិនណ៎ា!

**លោក គឹម វុន៖**

**ឆ៖** សំឡេងវិទ្យុរណសិរ្សក្រុងភ្នំពេញ ជំនាន់រណសិរ្ស គឺមាន បងផៃ មួយ ហើយនិងបងមួយ ផ្សេងទៀត ទាំងអស់មានគ្នាបួននាក់។ ហើយមិត្តស៊ន ហើយនិងមិត្ត យ៉េត។ មានស្រីតែម្នាក់ទេ មុន ដំបូង ក្រោយមកបានថែមមិត្ត មល មួយទៀត។

[១៣:៥០:០៦]

**ស៖** តើលោកធ្លាប់ឮសំឡេងមេដឹកនាំនិយាយតាមការចាក់ផ្សាយវិទ្យុដែរឬទេ?

**ឆ៖** ក្នុងវិទ្យុរណសិរ្សក្រុងភ្នំពេញ កម្រមានសំឡេងផ្ទាល់របស់ថ្នាក់ដឹកនាំណាស់។ ប៉ុន្តែដូចជា មានសេចក្តីថ្លែងការណ៍ ប៉ុន្តែខ្ញុំមិនចាំថា ជាសេចក្តីថ្លែងការណ៍របស់អ្នកណាទេ ប៉ុន្តែមានសេចក្តីថ្លែង ការណ៍។

**ស៖** ខ្ញុំសូមបញ្ជាក់ មានសំឡេងផ្សាយពីមេដឹកនាំ -- បានន័យថា មេដឹកនាំមានផ្សាយនៅក្នុង វិទ្យុដែរ ក៏ប៉ុន្តែលោកមិនចាំខ្លឹមសារ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោក គឹម វុន ខ្ញុំមិនទាន់បានទទួលចម្លើយពីលោកនោះទេ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ ក្នុង

ពេលដែលលោកនៅ ប-២០ នៅស្ទឹងត្រង់ មានការចាក់ផ្សាយវិទ្យុដល់ -- មានសំឡេងមេដឹកនាំផ្សាយ នៅក្នុងវិទ្យុផងដែរ។ ក៏ប៉ុន្តែលោកមិនចាំថា ខ្លឹមសារលើកឡើងនោះអ្វីនោះទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៣:៥១:៥២]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ! ឆ្លើយអំមិញអត់មានភ្លើង -- ក្បាលមីក្រូមិនទាន់ឲ្យភ្លើងក្រហមផង។

**លោក គីម វុន៖**

**ឆ៖** បាទ។

**លោក ឃីត វេយ៍ន័រ៖**

**ស៖** លោកនិយាយអំពីកប៉ាល់ ដែលលោកជិះចូលមកទីក្រុងភ្នំពេញ។ នៅពេលដែលលោកជិះ ក្នុងកប៉ាល់ចូលមកទីក្រុងភ្នំពេញនោះ លោកដឹងថា គេបើកតម្រង់ទៅណាដែរឬទេ?

**ឆ៖** ខ្ញុំដឹងថា មានដំណាក់នៅពេទ្យព្រះកេតុមាលា ចេញពីព្រែកក្តាមមក ទៅ -- ចូលទៅកន្លែង ហ្នឹង សំណាក់នៅហ្នឹង។

**ស៖** ខ្ញុំចង់សួរអំពីការចាក់ផ្សាយវិទ្យុវិញម្តង តើមានក្រុមអ្នកផ្សាយវិទ្យុនៅ ប-២០ នោះចំនួន ប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំចាំតែអ្នកអាន មានទាំងអស់ប្រាំនាក់ ប្រុសបី ស្រីពីរ។

[១៣:៥៣:២៥]

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ តើអត្ថបទសរសេរចុងក្រោយនោះគឺនិយាយអំពីអ្វី ដែរ នៅពេលដែលលោកចូលរួមសរសេរចុងក្រោយគេនោះ មុនពេលដែលលោកចាកចេញពី ប-២០?

**ឆ៖** មែនទែននៅក្នុងទំព័រទស្សនាវដ្តី ភាគច្រើននិយាយពីរឿងសមរភូមិ ឬក៏ចុះផ្សាយអំពី សេចក្តីថ្លែងការណ៍ផ្សេងៗរបស់ថ្នាក់ដឹកនាំ អំពាវនាវដល់កម្មាភិបាល យុទ្ធជន យុទ្ធនារី ដល់ប្រជាជន ឲ្យរួបរួមគ្នាក្នុងការធ្វើការតស៊ូឲ្យបានជ័យជម្នះ។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់លោក គីម វុន។ តើនៅពេលនោះលោកនៅតែចម្លងដោយដៃ ដដែល ឬក៏យ៉ាងម៉េច? គឺបានន័យថាចម្លងព័ត៌មានដោយដៃផ្ទាល់នៅដដែល ឬក៏មានការបោះពុម្ពផ្សាយ ធ្វើឡើងរួចទៅហើយនៅពេលនោះ?

**ឆ៖** នៅពេលសម័យនៃ ប-២០ ខ្ញុំនៅតែសរសេរដៃដដែល។

[១៣:៥៥:០៣]

**ស៖** លោកនិយាយថាមេដឹកនាំធ្វើការថ្លែងការណ៍។ តើលោកដឹងទេសមាជិកមេដឹកនាំណាមួយដែលជាអ្នកសរសេរទៅលើសេចក្ដីថ្លែងការណ៍នោះ?

**ឆ៖** ខ្ញុំមិនដឹងថា អ្នកណាជាអ្នកសរសេរទេ ពីព្រោះអ្នកនិពន្ធមានច្រើនដែរ។ ប៉ុន្តែឃើញចុះក្នុងហ្នឹង ច្រើនតែសេចក្ដីថ្លែងការណ៍របស់លោក ខៀវ សំផន។

**ស៖** លោកនៅប-២០ សេចក្ដីថ្លែងការណ៍ចម្បងៗនោះ គឺធ្វើឡើងដោយ ខៀវ សំផន។ លោក តើលោកគិតថាចម្លើយសេចក្ដីថ្លែងការណ៍ ខៀវ សំផន នោះ គឺប្រហែលប៉ុន្មានដែរ?

**ឆ៖** សេចក្ដីថ្លែងការណ៍របស់លោកមានច្រើនទំព័រដែរ ប៉ុន្តែខ្ញុំមិនចាំថាប៉ុន្មានទេ។ មានខ្លះអាចទៅដល់ជិត១០ទំព័រ ហើយខ្ញុំនឹកស្មានថា មិនមែនលោក ខៀវ សំផន គាត់សរសេរខ្លួនឯងទាំងអស់ទេ ព្រោះនៅក្នុងក្រុមដឹកនាំរបស់រណសិរ្សរួបរួមជាតិកម្ពុជា ទាល់តែមានការសម្រេចពីសម្ដេចព្រះ នរោត្តម សីហនុ ដែរ បានលោក ខៀវ សំផន អាចនឹងធ្វើបាន។ នេះតាមការសន្និដ្ឋានរបស់ខ្ញុំទេ ប៉ុន្តែចំពោះថាគាត់ធ្វើដោយឯកតោភាគី ឬក៏ភាគីណាមួយ ខ្ញុំមិនដឹងទេ ប៉ុន្តែជាគោលការណ៍របស់រណសិរ្សរួបរួមជាតិកម្ពុជា ថ្នាក់ដឹកនាំត្រូវតែឆ្លងកាត់ការយល់ព្រមពីសម្ដេចព្រះ នរោត្តម សីហនុ ព្រោះជាសេចក្ដីថ្លែងការណ៍ចំពោះជាតិធំៗ។

[១៣:៥៧:២១]

**ស៖** ប្រសិនបើមានសេចក្ដីថ្លែងការណ៍ដោយលោក ខៀវ សំផន តើគេផ្ញើមកប-២០ នោះដោយរបៀបណាដែរ?

**ឆ៖** គេឲ្យនីរសារយកមកសរសេរអត្ថបទទាំងស្រុង ជាវាយអង្គុលីលេខ ឬក៏សរសេរដៃ។

**ស៖** ប្រសិនបើសេចក្ដីថ្លែងការណ៍នោះជារបស់ ខៀវ សំផន តើគេថតចម្លងប៉ុន្មានច្បាប់ដែរ?

**ឆ៖** ការថតចម្លងខ្ញុំមិនដឹងដែរ ព្រោះថាអាចផ្សាយវិទ្យុក៏មាន ការផ្សាយក្នុងទស្សនាវដ្ដីក៏មាន។

**ស៖** ខ្ញុំសូមបញ្ជាក់លោកត្រង់ចំណុចនេះ។ ប្រសិនបើមានសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដោយ ខៀវ សំផន នោះ គឺក៏គេយកមកផ្សាយដោយផ្ទាល់មាត់ដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ ដូចកម្រអានផ្ទាល់មាត់ណាស់ ព្រោះភាគច្រើនផ្សាយច្រើនតែអ្នកអានថតហើយផ្ទៀងផ្ទាត់ បានយកចាក់ផ្សាយបាន។ បើសំឡេងផ្ទាល់ ដូចមិនដែលឮ។

**សៈ** ក៏ប៉ុន្តែសំឡេងនោះ គឺសំឡេងរបស់លោក ខៀវ សំផន តែម្តងដែលផ្សាយវិទ្យុនោះ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អត់ទាន់មាន -- ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ។

**លោក គឹម វុន៖**

**ឆៈ** អត្ថបទភាគច្រើន គឺច្រើនតែផ្សាយជាអត្ថបទដែលថតជាខ្សែអាត់ហើយ បានយកចាក់ផ្សាយនៅវិទ្យុ។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**សៈ** តែខ្ញុំចង់សួរថា សំឡេងនោះគឺជាសំឡេងផ្ទាល់របស់ ខៀវ សំផន តែម្តងនៅក្នុងខ្សែអាត់នោះ ឬក៏យ៉ាងម៉េចបាទ?

[១៣:៥៩:៥៥]

**ឆៈ** ថតចម្លង បានន័យថា អ្នកដែលអានវិទ្យុហ្នឹង គេយកមកអានហើយ គេថតជាកាសែត។ ថតបានអ៊ីចឹងហើយ បានយកទៅចាក់ផ្សាយ ថតបានហើយ ធម្មតាមុននឹងផ្សាយ គេច្រើនតែផ្ទៀងផ្ទាត់ក្រែងវាខុសពីច្បាប់ដើម។ អ៊ីចឹងបានផ្សាយបាន។

**សៈ** ប្រសិនបើមានសេចក្តីថ្លែងការណ៍ធ្វើឡើងដោយ ខៀវ សំផន នៅប-២០ តើខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះ ជាក់លាក់នោះគេលើកឡើងពីអ្វីដែរ?

**ឆៈ** តាមខ្ញុំចាំសេចក្តីថ្លែងការណ៍នោះ គឺច្រើនតែនិយាយជំរុញ ការវាយសម្រុក យកជ័យជម្នះនៅលើសមរភូមិ ហើយនិងការអំពាវនាវឲ្យប្រជាជននៅតំបន់រំដោះ ក៏ដូចជាកម្មាភិបាល យុទ្ធជនយុទ្ធនារីហ្នឹង ជួយឧបត្ថម្ភគាំទ្រគ្នា ទាំងសមរភូមិមុខ និងសមរភូមិក្រោយ។

**សៈ** សូមអរគុណលោកសាក្សី គឹម វុន។ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត។ ប្រធានបទបន្តទៀត គឺការប្រាស្រ័យ -- ការទំនាក់ទំនងជាទូទៅ។ គឺ ឯកសារ E3/380 ខ្មែរគឺមាន 00357200, បារាំងគឺ 00485433, អង់គ្លេស 00365645។ នៅទំព័រនេះ គឺលោកនិយាយថា៖ “ថ្នាក់លើទំនាក់ទំនងទៅថ្នាក់កណ្តាល និងថ្នាក់ក្រោមតាមរយៈលិខិត។ ហើយពេលខ្លះថ្នាក់កណ្តាល និងថ្នាក់ក្រោមត្រូវបានកោះហៅឲ្យទៅជួប ដើម្បីទទួលយកផែនការ”។ ឥឡូវនេះ ខ្ញុំនិយាយអំពីលិខិតសិន។ តើគេបញ្ជូនលិខិតពីថ្នាក់លើហ្នឹង តាមរបៀបណាដែរ?

**ឆ៖** របៀបរបបបញ្ជូនសំបុត្រ គឺគេមានចាត់តាំងជានីរសារ បានន័យថា អ្នកដឹក -- អ្នកនាំសំបុត្រហ្នឹងទៅឲ្យកន្លែងណាមួយ។ ដូច្នេះ គ្មានអ្នកណាដែលអត់មានមុខងារហ្នឹង ទៅនាំសំបុត្រហ្នឹងបានទេ។ ហៅឈ្មោះថា "នីរសារ" ទាល់តែអ្នកស្មោះត្រង់ អ្នកប៉ាានឆ្លងកាត់នូវឧបសគ្គជាច្រើន។ ដូច្នេះ មិនមានអ្នកណាអាចចេះតែយកសំបុត្រហ្នឹងទៅបានទេ។ ហើយសំបុត្រហ្នឹងទៀត តែសំបុត្រពីអង្គភាពមួយទៅអង្គភាពមួយ សុទ្ធតែជារឿងសម្ងាត់។

**ស៖** ឥឡូវនេះ យើងលើកឧទាហរណ៍មួយ នៃលិខិត ប្រសិនបើលិខិតហ្នឹងបញ្ជូនពីថ្នាក់លើទៅថ្នាក់កណ្ដាល។ តើលោកចង់មានន័យបែបណាដែរ នៅពេលដែលលោកមានប្រសាសន៍ថា ថ្នាក់កណ្ដាលនោះ?

[១៤:០៣:៥៦]

**ឆ៖** ថ្នាក់កណ្ដាលចង់និយាយថា--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញៗលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយហេតុថា តំណាងសហព្រះរាជអាជ្ញា លើកជាឧទាហរណ៍នូវការផ្ញើលិខិត ដោយមិនបានបង្ហាញពីលិខិតជាក់លាក់ទេ ហើយទង្វើបែបនេះបានសួរសំណួរមុន គាត់បានធ្វើអ៊ីចឹងដែរ លើកឧទាហរណ៍ អំពីសេចក្ដីថ្លែងការណ៍ណាមួយរបស់លោករបស់លោក ខៀវ សំផន ជាដើម។ អ៊ីចឹង ខ្ញុំសូមបដិសេធ ចំពោះសំណួរនេះ។

សូមអរគុណ។

[១៤:០៤:៣៤]

**លោក ឃីត រស្មីន័រ៖**

លោកប្រធាន គឺថាមានឱកាសមួយចំនួនដែលមានបញ្ហានេះ នៅក្នុងដំណើរការនីតិវិធីដែលជំរុញឲ្យខាងមេធាវីការពារក្ដី លើកយកនូវប្រធានបទសំខាន់ៗ ឬក៏ពាក់ព័ន្ធមួយចំនួននៅក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកគឺឲ្យមានការបញ្ជាក់ ឲ្យមានការចោទសួរនិងការដេញដោល ទៅលើចំណុចទាំងអស់នោះ។ សាក្សីរូបនេះបានបញ្ជាក់អំពីលិខិតនៅក្នុងបរិបទនៃប្រព័ន្ធ

ទាក់ទង។ ដូច្នេះ ខ្ញុំគ្រាន់តែស្នើសុំឲ្យគាត់ធ្វើការបំភ្លឺ ដើម្បីជួយដល់តុលាការតែប៉ុណ្ណោះ។

[១៤:០៥:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៥:៥០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងមូល -- សំអាងហេតុនៃសេចក្ដីជំទាស់មិនសមស្រប។ សាក្សី -- អង្គជំនុំជម្រះត្រូវការស្ដាប់ចម្លើយតបរបស់សាក្សី សូមសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញា!

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំសូមលើកឧទាហរណ៍៖ ថ្នាក់លើបានន័យថា មេខាងលើមេខ្ញុំទៀត។ ថ្នាក់កណ្ដាលបានន័យថា កម្មាភិបាលនៅក្នុងអង្គភាពហ្នឹងឯង ហើយថ្នាក់ក្រោមបំផុតគឺ ប្រសិនបើពាក់ព័ន្ធនឹងថ្នាក់ក្រោម គឺបុគ្គលិកនៅក្នុងហ្នឹង មិនមែនគណៈកម្មាធិការកណ្ដាលទេ។ ខ្ញុំចង់និយាយ អង្កាល់ឲ្យសម្អាសហ្នឹងគឺន័យខ្ញុំគឺអ៊ីចឹង ព្រោះពីលើមកកណ្ដាល កណ្ដាលនាំមកឲ្យអ្នកក្រោម។ ឧបមាថា ខ្ញុំបាទជាបុគ្គលិកថ្នាក់ក្រោម ដូច្នេះមេខ្ញុំកណ្ដាលហ្នឹងត្រូវផ្ដល់ព័ត៌មានមកអ្នកទីបី ពីលើមកកណ្ដាល ពីកណ្ដាលមកខ្ញុំ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** តើលោកអាចផ្ដល់ឧទាហរណ៍មួយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោក ថាតើការណែនាំ ឬក៏ការបញ្ជា ដែលគេផ្ដល់ឲ្យក្នុងនាមលោកជាអ្នកនៅក្រោមបង្គាប់ហ្នឹង តើគេផ្ដល់ឲ្យតាមលិខិតហ្នឹង តើអាចលើកឧទាហរណ៍មួយនៃការផ្ដល់ជាលិខិតណែនាំអីបានទេ?

**ឆ៖** ជាធម្មតា ថ្នាក់ក្រោមមិនបានទទួលក្រៅពីសំបុត្រផ្ទាល់ខ្លួន។ ឧបមាថា សំបុត្រពីឪពុកម្ដាយ បងប្អូនមកពីស្រុក ហ្នឹងគឺថ្នាក់ក្រោមបានទទួល។ ប៉ុន្តែបើមេនៅក្នុងអង្គភាព ហៅថា កណ្ដាលហ្នឹង មិនបានបញ្ជូនមកឲ្យក៏អត់ដឹងដែរខ្លួនឯងហ្នឹង។ ប៉ុន្តែបើនិយាយរួមលិខិតនេះផ្ទាល់ខ្លួនគឺជាលិខិតដែលមិនមានពាក់ព័ន្ធអីហ្នឹងរឿងសម្ងាត់ រឿងអីៗទេ។ ប៉ុន្តែពីការដឹកនាំពីថ្នាក់លើមកអង្គភាព អាហ្នឹងជារឿងសម្ងាត់ គឺត្រូវតែមេទេដឹង។ អ្នកក្រោមទៀតទាល់គេផ្សាយបានយើងដឹង។

[១៤:០៨:១៧]

**ស៖** ឥឡូវនេះ ខ្ញុំបន្តទៅប្រធានបទថ្មីមួយទៀត ដែលនិយាយអំពីការរៀនសូត្រជាមូលដ្ឋាន។ ខ្ញុំ

និយាយជាទូទៅ ជារួមតែម្តងពីឆ្នាំ៧១ ដល់ ឆ្នាំ៧៩ មិនមែនត្រឹមតែនៅប-២០ នោះទេ គឺថាខ្ញុំផ្តោតទៅលើរយៈពេលទាំងមូលតែម្តង។ គឺនៅក្នុងទំព័រដែលទៅលើអ្វីដែលខ្ញុំទើបតែបានផ្តល់ជូន ហើយលោកបាននិយាយថា កម្មាភិបាលខ្មែរក្រហមជាទូទៅត្រូវបានគេកោះហៅ ដើម្បីចូលរួមប្រជុំរៀនសូត្រជាមូលដ្ឋាន ដើម្បីឱ្យពួកគេចេះដឹងមុនពេលដាក់ផែនការឱ្យអនុវត្ត។ សំណួរទី១របស់ខ្ញុំ ថាតើកម្មាភិបាលត្រូវបានគេកោះហៅប្រជុំទៅរៀនសូត្រជាមូលដ្ឋានហ្នឹង គេកោះហៅតាមរបៀបណាដែរ?

**ឆ៖** របៀបរបបធ្វើការងារជាធម្មតា គឺគេប្រាប់សាមីខ្លួនឱ្យទៅរៀននៅកន្លែងណាមួយ។ ខ្ញុំចង់និយាយថា រៀនជាមូលដ្ឋាននេះមិនមែនទៅរៀនជាបច្ចេកទេសទេ។ ធម្មតាជាទម្លាប់យើងតាំងពីសម័យសង្គ្រាម ៥ឆ្នាំហ្នឹងមក ការរៀនសូត្រភាគច្រើនផ្តោតលើការរៀនសូត្រនយោបាយ។ បានន័យថា ធ្វើឱ្យមនុស្សយល់ហើយ ចាំឱ្យទៅធ្វើការងារ។

[១៤:១០:០២]

បើមិនបានឆ្លងកាត់ការរៀនសូត្រ ការប្រជុំជីវភាព ការពិភាក្សាឱ្យយល់អំពីសាច់រឿងរបស់ឯកសារទេ គឺមិនអាចអនុវត្តការងារហ្នឹងបានត្រូវគេ។ ដូច្នេះ ដើម្បីមានជំហរមួយឯកភាពគ្នាក្នុងការធ្វើការងារ គឺត្រូវដាក់ចេញ ដាក់ចេញជាផែនការ ជាអីមក បានឱ្យធ្វើសកម្មភាពក្នុងការធ្វើការងារ។ ជាធម្មតា របៀបរបបធ្វើការងារគឺត្រូវតែយល់អំពីបញ្ហាដែលត្រូវធ្វើ។ អ៊ីចឹងគឺថា កម្មាភិបាលត្រូវតែប្រជុំរៀនសូត្រ រៀនសូត្រជាផែនការ រៀនសូត្រជាទិស។ ធ្វើអីមួយ គឺត្រូវតែឱ្យមនុស្សយល់។

**ស៖** តើអ្នកណាជាអ្នកដាក់ផែនការ អ្នកណាជាអ្នកកំណត់ផែនការមុនដំបូងគេ?

**ឆ៖** សមត្ថភាពខ្ញុំ គឺមិនអាចឆ្លើយរួចទេ។ ប៉ុន្តែខ្ញុំសរុបថា មានតែថ្នាក់លើទេ។

**ស៖** ថាតើពាក្យថា ថ្នាក់លើ ឬក៏អាជ្ញាធរថ្នាក់លើហ្នឹងមានន័យបែបណាដែរចំពោះលោកផ្ទាល់នោះ? តើលោកយល់យ៉ាងម៉េចដែរ?

**ឆ៖** ថ្នាក់លើបានន័យថា ថ្នាក់ដឹកនាំជាន់ខ្ពស់។ បានចេញជាផែនការអ្វីមួយបាន ទាល់តែថ្នាក់លើជាន់ខ្ពស់ហ្នឹងអនុម័តជាឯកសារ ធ្វើឯកសារសម្រាប់យកមកអប់រំ។

**ស៖** ថាតើអ្នកណាគឺជាមេដឹកនាំជាន់ខ្ពស់នោះ?

**ឆ៖** កាលខ្ញុំនៅក្មេង ការយល់ភាគច្រើនជាវិញ្ញាណ ឯនៅលើវិចារណញ្ញាណ ខ្ញុំនៅតិចជាងវិញ្ញាណ។ ហើយមកដល់សម័យនេះ ខ្ញុំវាយតម្លៃថា នៅក្នុងថ្នាក់ដឹកនាំខ្ពស់បំផុត។

[១៤:១៣:០៧]

**ស៖** លោកបាននិយាយនូវពាក្យមួយដែលថា នយោបាយ គឺការ -- គឺលទ្ធិនយោបាយ -- គឺការបំពាក់បំប៉ននយោបាយ។ តើសារនយោបាយដែលគេបំពាក់បំប៉នហ្នឹង វាមានអីខ្លះដែរ?

**ផ៖** បាទ សម័យសង្គ្រាម គឺណែនាំអំពីការធ្វើសង្គ្រាម។ ដល់សម័យមកដល់កសាង គឺភាគច្រើន គឺនិយាយពីកសាង។ ប៉ុន្តែនៅក្នុងសម័យមុន ក្នុងសង្គ្រាមគឺគិតតែពីរឿងសង្គ្រាមទេ។ គឺ -- ប៉ុន្តែនៅក្នុងពេលសន្តិភាព គឺមានការពារប្រទេស និងកសាងប្រទេស។ ដូច្នេះ ខ្លឹមសារធំគឺមានប៉ុណ្ណឹង។

**ស៖** តើមានអ្នកចូលរួមរៀនសូត្រជាមូលដ្ឋានហ្នឹងប្រហែលប៉ុន្មាននាក់ដែរ?

**ផ៖** ការរៀនសូត្រក្នុងសម័យសង្គ្រាម ក៏ដូចជាសម័យសន្តិភាពហ្នឹងគឺមានច្រើន។ ច្រើនជាងកម្មាភិបាលសំខាន់ៗ។ ហើយបន្ទាប់មកក៏មានយុទ្ធជន យុទ្ធនារីនៅតាមក្រសួងមន្ទីរ គឺរៀនទាំងអស់គ្នា។

[១៤:១៤:៥៥]

**ស៖** ឥឡូវនេះ យើងនិយាយអំពីពេលវេលាក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ -- ក្រោយឆ្នាំ១៩៧៥ ថ្ងៃ១៧ មេសា ហ្នឹងតើការរៀនសូត្រមូលដ្ឋានហ្នឹងគេធ្វើនៅទីណាដែរ?

**ផ៖** រៀនសូត្រហ្នឹងនៅបុរីកីឡា តាមខ្ញុំចាំ។

**ស៖** តើការរៀនសូត្រហ្នឹងគេរៀនទៀងទាត់កម្រិតណាដែរ?

**ផ៖** ការរៀនសូត្របើគិតទៅ បើថ្នាក់លើរៀនរាប់ខែអ៊ីចឹងទៅ។ បើថ្នាក់ក្រោមទេ អាចកន្លះខែ ឬក៏ក្នុងមួយអាទិត្យអី រៀនតាមថ្នាក់ដែរ។

**ស៖** ឥឡូវនេះយើងគិតថា ប្រសិនបើយើងរៀនសូត្រតែ ២សប្តាហ៍ ថាតើអ្នកណាជាអ្នកបំពាក់បំប៉ននយោបាយនៅក្នុងវគ្គរៀនសូត្រនោះ?

[១៤:១៦:១៣]

**ផ៖** នៅជំនាន់ក្រោយឆ្នាំ៧៥ ខ្ញុំច្រើនតែទទួលការអប់រំពីក្រសួង។ ក្រសួងឃោសនាអប់រំ ព្រោះខ្ញុំនៅក្នុងក្រសួងឃោសនាអប់រំ ដូច្នេះមានរដ្ឋមន្ត្រីម្នាក់ជាស្ត្រីហ្នឹង លោកស្រី យុន យ៉ាត ដែលខ្ញុំនិយាយពីខាងដើមហ្នឹង គាត់ជារដ្ឋមន្ត្រីក្រសួងឃោសនាអប់រំ។ ដូច្នេះការអប់រំនយោបាយគឺគាត់អប់រំតែម្នាក់គាត់ទាំងអស់នៅក្នុងក្រសួង។

**ស៖** ប្រសិនបើកម្មាភិបាលចូលរួមការរៀនសូត្រជាមូលដ្ឋាន ហើយបានទទួលនូវព័ត៌មានពីការរៀនសូត្ររយៈពេល ២សប្តាហ៍នេះ ថាតើគេរំពឹងថាកម្មាភិបាលដែលរៀនសូត្រហ្នឹង នឹងធ្វើអ្វី ឬក៏យក

ព័ត៌មានហ្នឹងទៅធ្វើអ្វី ប្រសិនបើគេមានការរៀនអ៊ីចឹង?

[១៤:១៧:២០]

**ឆ៖** ដូចខ្ញុំបាននិយាយពីខាងដើម គឺទិសមានតែពីរទេ។ ទី១ ការពារប្រទេស។ ទី២ កសាងប្រទេសតាមជំនាញរបស់គេ។ ឧបមាខ្ញុំបាទនៅរោងពុម្ពអ៊ីចឹងទៅ គឺខំធ្វើការងារក្នុងរោងពុម្ពហ្នឹងទៅធ្វើការងាររបស់ខ្លួនឯងឲ្យបានល្អ។

**សៈ** ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត គឺនិយាយអំពីរោងពុម្ព បន្ទាប់ពីថ្ងៃ១៧ មេសា ៧៥ ដូច្នេះចំណុចនេះគឺខ្ញុំនិយាយអំពីរោងពុម្ពនៅមុខស្ពាតអូឡាំពិក គឺឯកសារ E3/380 ភាសាខ្មែរគឺ 00357197, ភាសាបារាំងគឺ 00485429 រហូតដល់ 30, និងភាសាអង់គ្លេស គឺមានលេខ 00365642។ លោកបាននិយាយថា "ខ្ញុំត្រូវបានគេចាត់តាំងឲ្យរៀបចំនៅរោងពុម្ព"។ តើអ្នកណាជាអ្នកចាត់តាំងលោកឲ្យរៀបចំរោងពុម្ពនោះ?

[១៤:១៨:៥៤]

**ឆ៖** តាមពិតទៅមកដល់ភ្នំពេញ ទស្សនាវដ្ដីដែលខ្ញុំបន្តសរសេរដៃបានមួយក្បាល ផ្សព្វផ្សាយអំពីផែនការការពារប្រទេស កសាងប្រទេស។ ហើយរួចពីហ្នឹងទៅខ្ញុំលែងពាក់ព័ន្ធនឹងបច្ចេកទេសហ្នឹងទៀតហើយ ព្រោះខ្ញុំមានការងារថ្មីត្រូវទៅដឹកនាំក្រុមថតរូប ដើម្បីត្រៀមធ្វើកាសែត ធ្វើទស្សនាវដ្ដី។ ដូច្នេះការងាររោងពុម្ពនេះ ដូចខ្ញុំបានជម្រាបពីខាងដើម គឺខ្ញុំនៅគ្រាន់តែជួយការងារខ្លះ ដូចជាធ្វើចំណងជើង ដូចជា *ឃ្លីស្សេ* ដូចជា ទាក់ទងអីដែលយកទៅបកកាសែតនោះ គឺខ្ញុំជួយជាសរសេរអក្សរខ្លះជាចំណងជើង ឬក៏ធ្វើក្បាលកាសែតអីខ្លះ។ ដូច្នេះអត់ជាប់ពាក់ព័ន្ធនឹងការងារបច្ចេកទេសហ្នឹងតទៅទៀតទេ ព្រោះខ្ញុំត្រូវមានការងារថ្មីមួយទៀតតាមការចាត់តាំង។

[១៤:២០:១១]

**សៈ** ខ្ញុំគិតថាសំណួរដែលខ្ញុំសួរ គឺសំណួរត្រង់ ខ្ញុំចង់ដឹងថា អ្នកណាជាអ្នកបញ្ជា ឬក៏ជាអ្នកបញ្ជូនលោកឲ្យទៅបំពេញការងារនោះ?

**ឆ៖** រដ្ឋមន្ត្រីខ្ញុំដដែល។ រដ្ឋមន្ត្រីក្រសួងឃោសនាអប់រំ។

**សៈ** តើរដ្ឋមន្ត្រីហ្នឹង គាត់ឈ្មោះអីដែរ?

**ឆ៖** គាត់ឈ្មោះ យុន យ៉ាត ភេទស្រី។

**សៈ** ទាក់ទងទៅនឹងមន្ទីរ ក ជាច្រើនហ្នឹង គឺក-២៥ រហូតទៅដល់ក-២៦, ២៧, ២៨, ២៩,

៣០, និង ៣១ ថាតើទាំង ក ទាំងប៉ុន្មានហ្នឹង គឺជាផ្នែកមួយនៃរោងពុម្ពរដ្ឋ ឬមួយក៏វាជាផ្នែកនៃអង្គភាព ឬក៏ស្ថាប័នផ្សេង?

[១៤:២១:២៤]

**ឆ៖** ចាប់ពីក-២៥ ដល់ ៣១ គឺជាមន្ទីររបស់ក្រសួងឃោសនាអប់រំ។ ដោយឡែកមន្ទីរក-២៥ គឺជាកន្លែងដែលរដ្ឋមន្ត្រីគាត់នៅ ធ្វើការងារអីហ្នឹង។ បាទ ឥឡូវក៏ដូចជាកន្លែងក្រសួងមួយដែរ ទាល់មុខស្តាតអូឡាំពិក។ កន្លែងដែលខ្ញុំធ្វើការនេះនៅជាប់នឹងអតីតកាសែតសង្គ្រោះជាតិ ពីជំនាន់ លន់ នល់។

**ស៖** សូមលោកជួយខ្ញុំទៅលើបញ្ហានេះបន្តិច។ កាសែតសង្គ្រោះជាតិ ឬក៏កាសែតរំដោះសង្គ្រោះជាតិនោះ តើៗ ថាតើកាសែតនោះ គឺជាកាសែតដែលមានមុនពេលដែលលោកមកដល់ភ្នំពេញហ្នឹង ឬមួយក៏យ៉ាងម៉េចដែរ? តើកាសែតហ្នឹងវាមានមុន តាំងពីមុនមក ឬក៏យ៉ាងណា?

**ឆ៖** កាសែងសង្គ្រោះជាតិ តាមពិតកើតនៅជំនាន់រដ្ឋាភិបាល លន់ នល់។ នៅទាល់មុខស្តាតអូឡាំពិក។ នៅជាប់នឹងក្លឹបប្រដាល់*ស៊ីជូ* នៅជាប់គ្នាហ្នឹង។

**ស៖** ដូច្នេះខ្ញុំច្បាស់ហើយថា កាសែតហ្នឹងវាមានដំណើរការ។ គឺជាទីកន្លែងកាសែតដែលមានដំណើរការ ហើយវាមានម៉ាស៊ីន មានអ្វីៗគ្រប់គ្រាន់ដែលអាចបោះពុម្ពកាសែតបានតែម្តង។ តើអីចឹងមែនដែរឬទេ?

ឆ៖ *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:២៣:៣៣]

**ប្រធានអង្គជំនុំ៖**

ឆ្លើយ សាក្សីឆ្លើយ! អំមិញឆ្លើយអត់ទាន់មានភ្លើងផង អត់ស្តាប់អត់បានទេណា៎។ អត់ចូលក្នុងប្រព័ន្ធសំឡេងទេ។

**លោក គឹម វុន៖**

**ឆ៖** កន្លែងនោះអាចបោះពុម្ពអីក៏បានដែរ ព្រោះជាកន្លែងកាសែតចាស់។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំបន្តទៅប្រធានបទមួយទៀត។ តើក-២៥ ហ្នឹងគេផលិតអី ឬក៏បោះពុម្ពអី? ឯកសារខ្មែរ 00357205, ភាសាបារាំងគឺ 00402997, ភាសាអង់គ្លេសគឺមានលេខ 00365528។ គឺឯកសារដែលមានលេខ E3/381។ លោកនិយាយថា កន្លែងហ្នឹងគឺបោះពុម្ពទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តី

យុវជន យុវនារី។

[១៤:២៤:៥៧]

ហើយមានក្រុមអ្នកនិពន្ធ មានអ្នកសម្ភាស មានផ្នែកនិពន្ធ និងផ្នែកកែសម្រួល។ លោកសាក្សី ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ ក៏ដូចជួយដល់អង្គសវនាការ ដើម្បីឲ្យលោកអាចពន្យល់បន្ថែម ប្រសិនបើលោកមើលទៅលើទំហំនៃសាលសវនាការនេះ ឬក៏មើលទៅលើអគារហ្នឹង តើលោកអាចធៀបបានទេថាអគារសាលសវនាការហ្នឹងធៀបជាមួយនឹងរោងពុម្ព វាមានទំហំប្រហែលគ្នា ឬមួយក៏តូចជាង ឬក៏ធំជាង?

**ឆ៖** កន្លែងរោងពុម្ពនៅក-២៥ មានទំហំតូច។ នៅ២៦ ទ្រើសជាង ២៥បន្តិច ឯនៅ២៧ ជារោងពុម្ពដែលបោះ*អ៊ុបសិត* វាទំនើបជាងគេ។ ប៉ុន្តែនៅ២៦ អាចបោះ*អ៊ុបសិត* បានដែរ ប៉ុន្តែកន្លែងនោះគ្រាន់តែបោះជាក្រប ជាក្របទង់បដិវត្ត ឬក៏ក្របយុវជន យុវនារី។ ឯជាមូលដ្ឋាននៅ ២៦ ច្រើនតែបោះកាសែតបដិវត្តន៍។ ដោយឡែកនៅ ២៥ គឺត្រូវបោះឯកសារទង់បដិវត្ត និងឯកសារផ្សេងៗ ហើយក្នុងនេះក៏មានយុវជន យុវនារីដែរ ប៉ុន្តែក្របបោះនៅ ២៦។ ឯ ២៧ គឺបោះ -- ជួនកាលមានឯកសារទាក់ទងនឹងភាសាបារាំង អង់គ្លេសខ្លះ ប៉ុន្តែនៅកន្លែងនេះជាមូលដ្ឋានគឺបោះទស្សនាវដ្តីរូបភាពកម្ពុជា។

**ស៖** នៅក្នុងផ្នែកទាំងបួននៅក-២៥ ដែលលោកបានបញ្ជាក់ តើផ្នែកណាមួយដែលលោកធ្វើការ?

[១៤:២៧:១៥]

**ឆ៖** នៅក-២៥ កន្លែងធ្វើការដំបូង ខ្ញុំនៅជាជំនួយធ្វើការងារខាងផ្នែករោងពុម្ព ដែលទាក់ទងនឹងការធ្វើចំណងជើង សរសេរចំណងជើង ក្បាលកាសែតអីខ្លះ។ ប៉ុន្តែក្រោយមក ក្រោយពីការរៀនសូត្រខាងផ្នែកថតរូប ម្នាក់ៗស្ទាត់ជំនាញហើយ បានខ្ញុំចូលមកសរសេរកាសែតវិញ កាសែតបដិវត្តន៍។

**ស៖** ឥឡូវនេះខ្ញុំនិយាយអំពីផ្នែកទី១ គឺនិយាយអំពីការសរសេរចំណងជើង សរសេរចំណងជើងអត្ថបទ។ តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ ដែលថាលោកអានឯកសារមុនពេលដែលលោកសរសេរចំណងជើង? តើឯកសារ -- តើចំណងជើងហ្នឹងគេសរសេរ -- តើលោកពិនិត្យមើលអត្ថបទហើយសរសេរ ឬមួយក៏គេឲ្យចំណងជើងហ្នឹងមកតែម្តង?

[១៤:២៨:៤៤]

**ឆ៖** ធម្មតាមុននឹងធ្វើកាសែត យើងត្រូវមានក្បាលកាសែត ឈ្មោះកាសែតមួយ ហើយក្នុងហ្នឹងធម្មតាក្នុងកាសែតត្រូវគេសរសេរ នៅក្នុងក្បាលអត្ថបទខ្លះ។ ដូច្នេះ ខ្ញុំត្រូវសរសេរអក្សរហ្នឹង ព្រោះ

អង្កាល់ហ្នឹង គេមិនយកអក្សរដែលបោះជា*ទីហ៊ុ*ទ ដូច្នេះគេចង់ឲ្យយើងសរសេរហ្នឹង ដើម្បីឲ្យវាស្អាតជាង ហើយវាប្លែកពីអក្សរពុម្ព។ ដល់ខ្ញុំធ្លាប់សរសេរអ៊ីចឹងទៅ សរសេរឲ្យស្អាតអ៊ីចឹង យើងសរសេរហ្នឹងទឹកខ្មៅចិន *អង់ក្រេដឺស៊ីន* ហ្នឹង។ សរសេរជាខ្មៅហើយ បានគេយកទៅថតជា*ហ្គ្លីស្សេ* ឬក៏ជា*អ៊ុបសិត* ព្រោះថ្នាក់ដឹកនាំមិនចង់បានអក្សរពុម្ពយកទៅពង្រីកទេ ប៉ុន្តែអក្សរពុម្ពអាចពង្រីកបាន ប៉ុន្តែគេមិនចូលចិត្តយកអក្សរហ្នឹងទេ ចង់ឲ្យអក្សរដៃសរសេរទៅវាស្អាតជាង។ អ៊ីចឹងដែលខ្ញុំចង់និយាយថា ចំណងជើងហ្នឹងមិនមែនធ្វើចំណងជើងជាអត្ថបទ ជាប្រធានបទសម្រាប់សរសេរទេ ដែលខ្ញុំថាជំនួយការរោងពុម្ពហ្នឹង គឺជួយគេធ្វើហ្នឹង។ ព្រោះធម្មតាយើងអាចយកអក្សរ*ទីប៉ូ* ដែលៗសាកល្បងហើយហ្នឹងអូសរ៉ូឡូហើយហ្នឹង យកមកធ្វើចំណងជាជើងអីបានហើយ ប៉ុន្តែអក្សរហ្នឹង វាពង្រីកទៅវាអត់ស្អាត ដល់អ៊ីចឹងយើងត្រូវសរសេរពង្រីកវិញ បើដូចឥឡូវយើងប្រើកុំព្យូទ័រ ចង់ពង្រីកម៉េចក៏វាស្អាតដែរ។ កាលសម័យនោះ ទាល់តែយើងសរសេរសិន សរសេររួចហើយថតជា*អ៊ុបសិត ឬហ្គ្លីស្សេ* សិន។ ត្រូវពង្រីក ពង្រួមអីទៅតាមហ្នឹង ប៉ុន្តែភាគច្រើន ច្រើនតែពង្រួម។

**ស៖** ដូច្នេះ អត្ថបទដែលសរសេរដៃនោះ គឺវាល្អសម្រាប់ការបោះពុម្ព។ សំណួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងចំណងជើង ប្រសិនជាយើងគិតថា ឥឡូវយើងមើលទៅលើអត្ថបទកាសែតមួយ ដែលលោកអានហើយសង្ខេប។ ហើយនៅខាងលើអត្ថបទហ្នឹង គឺវាមានចំណងជើងនៃអត្ថបទនោះ។ ថាតើអ្នកណាជាអ្នកម្ចាស់គំនិត បានថាផ្តើមគំនិតសរសេរអត្ថបទចំណងជើងហ្នឹង តើលោកជាអ្នកបញ្ចេញគំនិតសរសេរអត្ថបទហ្នឹងផ្ទាល់ ឬមួយក៏អ្នកដទៃ?

[១៤:៣១:២៦]

**ឆ៖** ធម្មតារដ្ឋមន្ត្រីថ្នាក់ក្រសួង គាត់តែងតែប្រជុំអ្នកនិពន្ធ ដើម្បីប្រមូលមតិថាយ៉ាងម៉េច ឲ្យវាហៅថាឲ្យវាស្អាត ហើយវាសមស្របនឹងធ្វើកាសែត ឬធ្វើទស្សនាវដ្តី។ ដល់អ៊ីចឹងទៅ មតិជាច្រើន ចេញមតិមក គឺថាឯកភាពគ្នា ភាគច្រើនថាម៉េច គឺអនុវត្តទៅតាមហ្នឹង។

**ស៖** នៅពេលមុន តើ ឆយ នោះគឺជាប្រធានក្រុមសរសេរ ឬក៏មិនមែនទេ?

**ឆ៖** បងឆយ ជានិស្សិតនៅសាកលវិទ្យាល័យភ្នំពេញ។ ធម្មតាក្នុងសម័យ៣ឆ្នាំ អ្នកដែលជាប់ជាខ្សែតស៊ូនៅក្នុងក្រុងភ្នំពេញ ច្រើនតែពួកនិស្សិត ហើយនិងគ្រូ និងសាស្ត្រាចារ្យ។ អ៊ីចឹងបានទាំងនោះច្រើនតែយកមកធ្វើការនៅកន្លែងកាសែត ខាងសរសេរអត្ថបទអី ឬមួយពួកខ្ញុំមកពីរោងពុម្ពចាស់អ៊ីចឹងរួមគ្នា សរសេរអត្ថបទ ហើយ បងឆយ អង្កាល់គាត់បានទៅជាប្រធាន។ ព្រោះក្នុងចំណោមនោះ គាត់

ចំណាស់ជាងគេ ហើយអ្នកតស៊ូជើងចាស់ ប៉ុន្តែគាត់នៅតស៊ូជាមួយ លន់ នល់ នៅភ្នំពេញនេះ។ អ៊ីចឹង ពេលនោះ គាត់បានទៅជាប្រធាន។

[១៤:៣៣:២៥]

**ស៖** នៅពេលណាជាពេលលើកដំបូង ដែលលោកបានឃើញទំព័រនៃទស្សនាវដ្តីទង់បដិវត្តនោះ។ តើលោកឃើញទំព័រនោះ នៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់យល់។ ទំព័រហ្នឹង ចង់បញ្ជាក់យ៉ាងម៉េច? ឃើញជាលើកដំបូង ឬក៏ទំព័រដំបូង?

**ស៖** បាទ សំណួរវាមិនសូវល្អសម្រាប់លោក។ ដូច្នេះ ខ្ញុំសូមរៀបចំសំណួរនេះឡើងវិញ។ តើលោកបានដឹងដែរឬទេ លេខដំបូងនៃទស្សនាវដ្តីទង់បដិវត្តនោះ ចេញនៅក្នុងពេលណាដែរ? ក្នុងឆ្នាំណាដែរ?

**ឆ៖** តាមពិត ទង់បដិវត្តបោះពុម្ពផ្សាយតាំងពី -- តាមខ្ញុំដឹងតាំងពីឆ្នាំ ខ្ទង់ចូល៧០ហើយ មិនដឹងជា៧១ ឬ៧២ ឬ៧៣។ ពេលខ្ញុំចូលធ្វើការរោងពុម្ព គឺមានស្រេចទៅហើយ។ បែងចែកទៅជាពីរ គឺមានទង់បដិវត្ត ហើយនិងរណសិរ្សកម្ពុជា។ យុវជន យុវនារី អត់ទាន់មានទេ។ ដូច្នេះមានតែពីរទេ មុនដំបូង នៅឆ្នាំ៧១។ ប៉ុន្តែខ្ញុំមិនចាំថា មិនដឹងជាឆ្នាំ៧១, ៧២ ឬក៏ ៧៣ ទេ ដែលបោះពុម្ពទង់បដិវត្តហ្នឹង ប៉ុន្តែបើរណសិរ្សបោះពុម្ពតាំងពីយូរមកហើយ ដែលខ្ញុំបានឃើញជាដំបូង។

**ស៖** ប្រធានបទមួយផ្សេងវិញទៀត។ ប្រភពឯកសារដែលគេយកមកសរសេរ ប្រភពឯកសារនេះ គឺឯកសារ E3/381, បារាំងគឺ 00402998, អង់គ្លេសគឺ 00365528។ លោកបាននិយាយថា៖ "អ្នកដែលជាអ្នកនិពន្ធ អ្នកសរសេរនោះ ចេញមកពីមជ្ឈិមបក្ស"។ តើអ៊ីចឹងដែរឬទេ? តើអ្នកដែលសរសេរនោះ អ្នកនិពន្ធនោះ ដែលចេញជា -- ចេញមកពីមជ្ឈិមបក្សនោះគឺជានរណាដែរ?

[១៤:៣៦:២៨]

**ឆ៖** ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំអត់ដែលបានចូលបក្សផង។ ប៉ុន្តែខ្ញុំសន្និដ្ឋានថា ច្បាស់ជាចេញពីបក្សកុម្មុយនីស្តកម្ពុជាហើយ។ ប៉ុន្តែមិនដឹងអ្នកណាជាអ្នកសរសេរ ហើយមកសម័យក្រោយមក ខ្ញុំឃើញនៅលើកំណែ អក្សរគឺអក្សរ អ៊ំប៉ុល។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកកម្រិតឆ្លើយត្រឹមតែលោក អ្វីដែលលោកដឹង លោកឮ លោកឃើញ លោកចងចាំ ឬក៏បទពិសោធន៍ជួបប្រទះបានហើយ។ លោកមិនអាចឆ្លើយអ្វីដែលមិនដឹង ដោយស្មានថាជា

ការសន្និដ្ឋាននោះទេ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំមិនច្បាស់ថា លោកប្រធានគាត់ឮចំណុចឆ្លើយ ចុងក្រោយនោះយ៉ាងម៉េចនោះទេ គឺថាកុំឲ្យលោកឆ្លើយអ្វីក្រៅតែពីចំណេះដឹងផ្ទាល់ខ្លួនរបស់លោក។ ក៏ប៉ុន្តែសំណួររបស់ខ្ញុំនោះ គឺខ្ញុំចង់សួរអំពីការសរសេររបស់ បងប៉ុល តាមអ្វីដែលលោកបានដឹង ហើយលោកកុំផ្អែកទៅលើអ្វីដែលលោកមិនដឹង។ តើលោកស្គាល់អក្សរសរសេរដៃ របស់បងប៉ុល ដែរឬទេ?

**លោក គឹម វុន៖**

**ឆ៖** ប្រហែលជាស្គាល់ខ្លះ ព្រោះឯកសារខ្លះដែលខ្ញុំយកមកសរសេរ អាចមានចំណារហ្នឹងខ្លះ ហើយខ្ញុំចាំ។ ប៉ុន្តែមិនដឹងអ្នកណាសរសេរ ខ្ញុំមិនដឹង ខ្ញុំដឹងតែនៅលើចំណារ។

[១៤:៣៨:៣៧]

**ស៖** ដោយពិចារណាទៅលើពេលជារួម គឺពេលទាំងអស់ដែលលោកធ្វើការនោះ គឺលោកចាត់ចែងទៅឯកសារសរសេរដោយដៃ។ ដូច្នេះ លោកកំពុងតែនិយាយថា លោកស្គាល់នូវអក្សរសរសេរដៃរបស់មេដឹកនាំមួយចំនួន តើមែនដែរឬទេ?

**ឆ៖** ខ្ញុំទើបមកស្គាល់ក្រោយ ជំនាន់ក្រោយនេះទេ។ ដល់ពីមុនៗមក ខ្ញុំអត់ដឹង គ្រាន់តែដឹងប្រភពចេញ -- បើទង់បដិវត្ត គឺមិនមានថ្នាក់ក្រោមសរសេរបានទេ ព្រោះចេញមកសុទ្ធតែគោលនយោបាយ សុទ្ធតែរឿងសំខាន់ៗ ដែលមិនមានអ្នកណាដឹង ហើយថ្នាក់ក្រោមក៏មិនចេះតាក់តែងទ្រឹស្តីរបៀបហ្នឹងដែរ ព្រោះមិនបានរៀនផង។ ដូច្នេះ ខ្ញុំជឿថា មានតែថ្នាក់លើទេ ប៉ុន្តែខ្ញុំមិនដឹងថា ថ្នាក់លើហ្នឹងជានរណា ហើយខ្ញុំនិយាយអំមិញ គឺនិយាយលើចំណារ ព្រោះនៅក្នុងអត្ថបទដែលខ្ញុំសរសេរដៃជួនកាលក៏មានអក្សរខ្លះកែនៅលើដែរ ប៉ុន្តែខ្ញុំអត់ដឹងអ្នកនិពន្ធជាអ្នកណា អត់ដឹងទេ។

[១៤:៤០:០៧]

**ស៖** ខ្ញុំសូមសួរបញ្ជាក់ ឯកសារដែលលោកពិនិត្យមើលនោះ ប្រសិនបើមានចំណារណាមួយ ដូច្នេះ លោកនិយាយថា លោកអាចស្គាល់ចំណារហ្នឹងដែរ មែនដែរឬទេថា ជាចំណាររបស់អ្នកណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*។

**ស៖** លោក គឹម វុន ខ្ញុំអត់ទាន់បានទទួលចម្លើយពីលោកទេ ដូច្នេះលោកចង់ឲ្យខ្ញុំសួរសំណួរឡើងវិញ ឬក៏យ៉ាងម៉េចលោក?

**ឆ៖** បាទ សួរម្តងទៀត។

**ស៖** សំណួររបស់ខ្ញុំហ្នឹងគឺ ខ្ញុំបានសួរថា ពាក់ព័ន្ធទៅនឹងឯកសារទាំងឡាយ ឯកសារជាសរសេរដោយដៃ ដែលលោកបានពិនិត្យឃើញនៅពេលដែលលោកធ្វើការងារនៅរោងពុម្ពនោះ ដែលឯកសារទាំងអស់នោះមានចំណារនៅលើនុ៎ង ដូច្នេះលោកនិយាយថា លោកស្គាល់ចំណារដែលសរសេរនៅពីលើឯកសារទាំងអស់នោះ តើមែនដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:៤១:៣៧]

**ប្រធានអង្គជំនុំ៖**

ឆ្លើយសាក្សី! សូមឆ្លើយ ឆ្លើអំមិញ ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ។ អ៊ីចឹងឆ្លើយហ្នឹងវាស្មើនឹងអត់ឆ្លើយ។ បើមិនទាន់ឆ្លើយវាអត់បានចូលសំឡេង ស្តាប់អត់បានទាំងអស់គ្នា។

**លោក គឹម វុន៖**

**ឆ៖** ចំពោះសំណួរលោក ពេលខ្ញុំយល់ហើយថា ចំណារហ្នឹងខ្ញុំស្គាល់។ ព្រោះធម្មតាអត្ថបទបើទាក់ទងនឹងខ្ញុំសរសេរ ឬគេសរសេរតែងតែកន្លែងណាសរសេរអក្សរមិនច្បាស់តែងតែសួរគ្នា ដល់អ៊ីចឹងអាចឃើញតែចំណារហ្នឹងទេ មិនដឹងជាអ្នកណានិពន្ធទេ។ ឧបមាថា មានកែអីដាក់អីឲ្យបោះពុម្ពអីៗហ្នឹង គឺមានអក្សរបន្តិចមក -- ពីរបីម៉ាត់អីអ៊ីចឹងទៅ។ ហើយអក្សរនុ៎ងអាចស្គាល់បាន អ៊ីចឹងបានខ្ញុំឆ្លើយថា ជាអក្សរ បងប៉ុល ហើយ ព្រោះ ស៊ំ មុននឹងសរសេរកន្លែងខ្លះអត់ច្បាស់គាត់មកសួរ ខ្ញុំដែរ។ ហើយខ្ញុំអ្នកសរសេរបើខ្ញុំមិនច្បាស់ ខ្ញុំសួរ ស៊ំ ដែរ។

[១៤:៤២:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

ហើយជម្រាបតំណាងសហព្រះរាជអាជ្ញា សូមនៅពេលដែលចូលត្រឡប់មកវិញ សូមផ្តល់នូវពេលវេលាដែលនឹងបន្តទៅទៀតក្នុងការតាំងសំណួរ និងការបែងចែកជាមួយនឹងក្រុមមេធាវីនាំមុខ

តំណាងដើមបណ្ដឹងរដ្ឋប្បវេណី នៃការពេលវេលាដែលត្រូវសួរដេញដោលចំពោះសាក្សីរូបនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយមុននឹងសួរដេញដោលសាក្សី សូមតំណាងសហព្រះរាជអាជ្ញាផ្ដល់ពេលវេលាចាំបាច់ដែលលោកត្រូវធ្វើសវនាការដេញដោលសាក្សីរូបនេះ និងពេលវេលាដែលបែងចែកទៅឲ្យភាគីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ យ៉ាងម៉េចដែរ?

**លោក ឃីត វេយ៍ន៍រ៖**

លោកប្រធាន ខ្ញុំសូមពន្យល់នូវដំណើរការបែបនេះ គឺថាខាងព្រះរាជអាជ្ញាបានធ្វើសំណើជាបឋមចំពោះលោក គឹម វុន គឺសុំមួយថ្ងៃកន្លះ ដើម្បីចែករំលែកជាមួយខាងដើមបណ្ដឹងរដ្ឋប្បវេណីជាមួយនឹងខាងសហព្រះរាជអាជ្ញា។ ហើយការបែងចែកហ្នឹង គឺបែកចែកបីភាគបួន នៃថ្ងៃគឺបែងចែកជាមួយខាងដើមបណ្ដឹងរដ្ឋប្បវេណី និងបីភាគបួនទៀតមកខាងព្រះរាជអាជ្ញា។ ប៉ុន្តែដោយសារសប្ដាហ៍មុនគឺថាព្រះរាជព្រះរាជអាជ្ញាសុំពេលវេលាបន្ថែម គឺបន្ថែមពីបីភាគបួន ទៅមួយថ្ងៃ។

លោកប្រធាន ដូច្នេះខ្ញុំស្នើសុំដោយការគោរព ជូនចំពោះលោកប្រធាន ក៏ដូចជាអង្គជំនុំជម្រះព្រោះថា ដោយសារតែសាក្សីហ្នឹងគាត់មាននូវព័ត៌មានច្រើន ព្រោះយ៉ាងណាក៏ដោយ ខ្ញុំសូមស្នើដល់ពេល ស្នើសុំពេលវេលាបន្ថែមទៀត ចំពោះហេតុផលនេះ។ ព្រោះថាលោក គឹម វុន គឺជាសាក្សីដ៏សំខាន់គាត់មានចំណេះដឹង គាត់មានការផ្ដល់ព័ត៌មានបានយ៉ាងច្រើន ទាក់ទងទៅនឹងរយៈពេលនេះ។ ដូច្នេះខ្ញុំធ្វើដូច្នេះ ដើម្បីចៀសវាងកុំឲ្យកោះហៅគាត់មកម្ដងទៀត ដើម្បីផ្ដល់សក្ខីកម្ម។

[១៥:០៤:១៩]

ហើយទី៣ គឺថាការពិនិត្យសួរដេញដោលរបស់ខ្ញុំ គឺរួមបញ្ចូលទាំងការវាយតម្លៃទៅលើទស្សនាវដ្ដីទង់បដិវត្ត។ គឺថាឯកសារដែលសាក្សីនេះគាត់មានព័ត៌មានដឹង។ ដូច្នេះហើយ គឺដូចដែលខ្ញុំបានធ្វើជាមួយនឹងសាក្សីមុន គឺលោកស្រី ស សៀក គឺយើងបានកាត់បន្ថយពេលប្រហែលជាកន្លះថ្ងៃ។

ដូច្នេះ ខ្ញុំស្នើសុំដល់លោកប្រធានទៅលើសំណើមួយនេះ។ កន្លងមក គឺព្រះរាជអាជ្ញាបានចំណាយពេល១ម៉ោងកន្លះ ជាមួយនឹងសាក្សីនេះរួចមកហើយ។ ហើយយើងនៅសល់ពេលកន្លះថ្ងៃ -- ១ថ្ងៃកន្លះទៀត ដើម្បីចែករំលែកជាមួយនឹងខាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះដោយសារហេតុផលទាំងអស់នេះហើយ គឺខ្ញុំស្នើសុំយ៉ាងទទូចដល់លោកប្រធាន ក៏ដូចជាលោកចៅក្រម គឺសុំ១ថ្ងៃកន្លះ ដើម្បីចែករំលែក ១ថ្ងៃកន្លះបន្តដើម្បីចែករំលែកជាមួយនឹងខាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ -- ហេតុដូច្នេះហើយ គឺថាយើងមានគោលដៅដើម្បីចោទសួរទៅលើសាក្សីរូបនេះ ដើម្បីផ្ដល់ព័ត៌មានដែលពាក់ព័ន្ធ ដើម្បីជួយដល់តុលាការ។ ហេតុដូច្នេះហើយ គឺខ្ញុំស្នើសុំរយៈពេល១ថ្ងៃកន្លះដើម្បីចែករំលែកជាមួយខាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៥:០៥:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមបំភ្លឺអង្គជំនុំជម្រះ។ ខ្ញុំសូមបញ្ជាក់ថាសាក្សីនេះនឹងត្រូវចោទសំណួរដោយមេធាវី បេនី យេ តែម្នាក់តែប៉ុណ្ណោះ ដែលគាត់ត្រូវការយ៉ាងច្រើនបំផុត១ម៉ោងកន្លះ។ គឺថាចន្លោះពី ១ម៉ោង ទៅ១ម៉ោងកន្លះ លោកប្រធាន។

[១៥:០៦:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៧:១៤]

**ប្រធានអង្គជំនុំ៖**

លោក១ ម៉ែខល កាណាវាស ចង់មានបញ្ហា -- មានមតិយោបល់អី? សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ជាដំបូងគឺជា គឺខ្ញុំទុកសិទ្ធិជូនអង្គជំនុំជម្រះដើម្បីបែងចែកពេលវេលា មិនមែនទុកឲ្យភាគីនានា ភាគីនីមួយៗគាត់មកធ្វើការសម្រេច ថាខ្ញុំត្រូវការពេលនេះសម្រាប់សាក្សីនេះ ឬក៏សម្រាប់សាក្សីនោះទេ។ ដូច្នេះ គឺថាជាសិទ្ធិសម្រេចរបស់អង្គជំនុំជម្រះក្នុងការធ្វើការសម្រេចពេលវេលាជាមុន។ ដូច្នេះ ការបែងចែកពេលវេលាសម្រាប់សាក្សីមួយៗហ្នឹង គឺថាអាចថាពេលខ្លះ ដោយសារតែភាគីមួយមិនមាន ឬក៏មិនត្រូវការពេលវេលាចោទសួរច្រើន មានន័យថាទុកពេលហ្នឹងឲ្យភាគីដទៃទៀតឬក៏យ៉ាងណានោះទេ។

[១៥:០៨:១៤]

ហេតុដូច្នេះ ដើម្បីកុំឲ្យខាងព្រះរាជអាជ្ញាបានពេលវេលាច្រើន គឺយើងត្រូវប្រើពេលវេលាឲ្យអស់នោះ។ ដូច្នេះដើម្បីឲ្យមានប្រសិទ្ធភាព យើងគួរតែប្រើប្រាស់ត្រឹមតែពេលវេលាដែលយើងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពតែប៉ុណ្ណោះ។ ប៉ុន្តែដូច្នេះ ដូចដែលព្រះរាជអាជ្ញាបានលើកឡើងថា គឺដោយសារតែព្រះរាជអាជ្ញា ដោយសារតែខាងមេធាវីការពារក្តីមិនបានប្រើប្រាស់ពេលវេលាឲ្យអស់ទេ។ ដូច្នេះ ខ្ញុំសូមយកពេលនេះមកប្រើ។ វាមិនអាចនិយាយបែបនេះបានទេ។ ដូច្នេះ ចំពោះទឡ្ហីករណ៍ដែលលើកឡើងថា ហេតុអ្វីបានត្រូវការពេលវេលាយ៉ាងច្រើន ដែលព្រះរាជអាជ្ញាបានលើកឡើងនោះ ព្រោះគឺជាអ្វីដែលយើងចង់និយាយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់ដូច្នេះ។ បញ្ហាទី១ គឺអង្គជំនុំជម្រះមិនទាន់ពិចារណាសម្រេចលើបញ្ហានេះទេ។ សុំឲ្យតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួររបស់ខ្លួនតទៅទៀត រហូតដល់រសៀលនេះ ដើម្បីស្អែកយើងពិចារណាមើល ថាតើគួរដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច?

បញ្ហាទី២ គឺកត់សម្គាល់ឃើញថា ភាពមិនសមស្របមួយដែលថា សុខចិត្តលះបង់ពេលវេលាមិនសួរសាក្សីមួយ ហើយចង់យកពេលវេលានោះមកបូក ដើម្បីដំណើរការជាមួយសាក្សីផ្សេងទៀត។ ការដែលមានបំណងធ្វើដូច្នេះមិនសមស្របទេ។

[១៥:០៩:៤១]

សាក្សីមួយសម្រាប់តែដោះស្រាយបញ្ហាតែមួយប៉ុណ្ណោះ មិនអាចទូទាត់កាត់ពេលវេលាសម្រាប់សាក្សីនោះ ទុកពេលវេលាដែលបានកាត់ចេញនេះ យកទៅសួរសាក្សីដទៃទៀតនោះទេ។ ការធ្វើដូច្នេះ

មិនសមស្របឡើយ។ ប៉ុន្តែអង្គជំនុំជម្រះនឹងពិចារណានូវភាពចាំបាច់នៃការផ្តល់ពេលវេលាសមស្រប វាអាស្រ័យទៅលើភាពចាំបាច់នៃសំណួរដែលពាក់ព័ន្ធ ទៅនឹងសារៈសំខាន់នៃសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ។ សូមអញ្ជើញ!

[១៥:១០:២៤]

ហើយសូមជម្រាបអ៊ីចេះថា ការកំណត់កាលបរិច្ឆេទ បើយើងមិនច្រឡំទេគឺភាគីទាំងអស់ ការសួរសាក្សីរូបនេះ មានពេលតែ១ថ្ងៃកន្លះទេ។ ភាគីទាំងពីរ ទាំងភាគីចោទ ទាំងភាគីដោះបន្ទុក ខាងការពារក្តី មានតែ១ថ្ងៃកន្លះទេ។ មិនអាចសុំថាមួយភាគីខ្លួនឯងហ្នឹង សុំដល់១ថ្ងៃកន្លះទេ។ បានន័យថា ការបែងចែកកន្លងមកនេះ គឺទាំងភាគីទាំងសងខាងតែ១ថ្ងៃកន្លះទេ។ អ៊ីចឹងពេលវេលានេះ គឺអាចបើថែមថយ គឺថែមបន្តិចបន្តួចដែរ។ សូម្បីតែគណនាពេលវេលាដែលខាតបង់នេះ ក៏យើងបានគណនារួចហើយថាអស់៩នាទី ឬក៏អស់១០នាទី យើងកត់ចូលរួចហើយ។

សូមអញ្ជើញ!

**សួរដោយលោក ឃឹត វេយ្យន័រ៖**

**ស៖** លោក គឹម វុន មុនពេលដែលយើងបានសម្រាកហ្នឹង គឺយើងនិយាយអំពីចំណារជាសរសេរផ្ទាល់ដៃ ហើយលោកនិយាយថា លោកអាចស្គាល់នូវអក្សរដៃរបស់លោក ប៉ុល ពត។ ថាតើចំណារសរសេរដៃបែបណា ដែលលោកអាចស្គាល់បាន?

[១៥:១១:៥២]

**លោក គឹម វុន៖**

**ឆ៖** ក្នុងចំណារច្រើនតែថា អត្ថបទនេះអាចបោះពុម្ពឲ្យបានឆាប់។ អត់មានអីច្រើន មានតែប៉ុណ្ណឹងៗ។

**ស៖** ដូច្នេះខ្ញុំបន្តទៅប្រធានបទមួយទៀត គឺនិយាយពីខ្លឹមសារនៃទស្សនាវដ្តីទង់បដិវត្ត គឺឯកសារ E3/381។ ខ្មែរគឺមានលេខ 00357205, ភាសាបារាំងគឺមានលេខ 00402998, និងភាសាអង់គ្លេសគឺមាន 00365528។ លោក គឹម វុន លោកបាននិយាយថា “ខ្លឹមសារនៃទស្សនាវដ្តីទង់បដិវត្ត គឺនិយាយអំពីគោលការណ៍ណែនាំផ្ទៃក្នុងបក្សរបស់ថ្នាក់លើ ដើម្បីដាក់ឲ្យកម្មាភិបាលថ្នាក់ក្រោមអនុវត្ត និងដើរតាម”។ ពាក់ព័ន្ធទៅនឹងគោលការណ៍ណែនាំ ដូចដែលលោកបានផ្តល់រួចទៅហើយ គឺថាខ្លឹមសារគឺនិយាយអំពីមាគ៌ានយោបាយ ទ្រឹស្តី និងមនោគមន៍វិជ្ជា។ តើលោកអាចបានជម្រាបបានដែរឬទេ ថាតើ

លោកអាចផ្តល់ឧទារហណ៍បានដែរឬទេ អំពីមាគ៌ានយោបាយ?

[១៥:១៣:៤៤]

**ឆ៖** ខ្ញុំសូមជម្រាបឧទាហរណ៍មួយ។ ឧបមាថាផែនការកសាងប្រទេស។ ក្នុងន័យហ្នឹងគឺនិយាយអំពីអី គឺនិយាយពីការកសាងប្រទេស។ ធម្មតាកសាងប្រទេស មានផែនការបង្កើតផលស្រូវ ឧទាហរណ៍ថា បីតោនក្នុងមួយហិកតា ហ្នឹងជាខ្លឹមសារ។ ហើយមួយទៀតឧបមាថា ទិសដៅធំ វាយសម្រុក ការពារ កសាងប្រទេសតាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ។ នេះខ្ញុំគ្រាន់តែលើកជាឧទាហរណ៍ទេ ហើយលម្អិតទៀតខ្ញុំមិនដឹង ហើយខ្ញុំមិនចាំ ព្រោះខ្ញុំមិនបានចាប់អារម្មណ៍ហ្នឹងមើល ហើយខ្លួនឯងក៏មានភារកិច្ចអីត្រូវមើលទង់បដិវត្តរបស់បក្សដែរ។

[១៥:១៤:៥៨]

**ស៖** ថាតើលោកជាបក្ខជនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អត់ទាន់ប្រតិបត្តិការទេ លោកសាក្សី។ អ៊ីចឹង កាលណាលោកសាក្សី បញ្ហារឹតតែយឺតទៀតណេះ ព្រោះលោកអាចនិយាយពីរដងណ៎ះ! ព្យាយាមបន្តិច ដើម្បីបង្អង់រង់ចាំរហូតដល់ក្បាលមីក្រូធ្វើប្រតិបត្តិការសឹមនិយាយ។

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំអត់បានចូលបក្សទេ ខ្ញុំជាសម្ព័ន្ធយុវកកក្នុងសម័យនោះ។

**ស៖** ពាក់ព័ន្ធទៅនឹងទស្សនាវដ្តីទង់បដិវត្តដែលលោកធ្លាប់ឃើញ ថាតើជោគជ័យថ្ងៃ១៧ មេសា ៧៥ មានធ្លាប់ត្រូវបានគេលើកយកមកផ្សព្វផ្សាយនៅក្នុងទស្សនាវដ្តីទង់បដិវត្តដែរឬទេ?

**ឆ៖** ខ្ញុំអត់បានផ្ទៀងផ្ទាត់មើលដែរ ព្រោះពេលចូលមកភ្នំពេញ គឺមិនបានមើលទេ ព្រោះខ្ញុំដាច់ពីរោងពុម្ពហ្នឹងហើយ ទៅខាងនិពន្ធកាសែត។ ដូច្នេះ ខ្លឹមសារយ៉ាងម៉េចៗ ខ្ញុំអត់បានដឹង។

**ស៖** ប្រសិនបើខ្ញុំនិយាយខុស សូមលោកជួយកែខ្ញុំផង ប៉ុន្តែនៅព្រឹកនេះ លោកបានផ្តល់ចម្លើយថា នៅពេលដែលលោកមកដល់ភ្នំពេញដំបូង គឺលោកមានតួនាទី ក្នុងការរៀបចំឯកសារ ឬក៏រៀបចំនូវសារព័ត៌មាន។ តើខ្ញុំនិយាយនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ដូច្នេះ ចំពោះឯកសារដែលលោកធ្វើការរៀបចំ គឺថាឯកសារដែលលោកធ្វើភ្លាមៗក្រោយ

ការជម្លៀសភ្នំពេញហ្នឹង តើវាជាឯកសារអ្វី? តើឯកសារដែលលោករៀបចំហ្នឹង ឯកសារអ្វី?

[១៥:១៧:២៧]

**ឆ៖** ឯកសារ ដូចខ្ញុំមិនបានរៀបចំអីផង។ ព្រោះអង្កាល់នោះ ភារកិច្ច បើនិយាយខាងផ្នែកកាសែត ដើរត្រួតពិនិត្យមើលរោងពុម្ពហ្នឹង បណ្ណាគារ ដើម្បីរក្សាសៀវភៅល្អៗហ្នឹងទុក ហើយរោងពុម្ពកត់ចំនួនហ្នឹងមានប៉ុន្មាន នៅក្នុងក្រុងភ្នំពេញហ្នឹង។ ឯរៀបចំជាខ្លឹមសារផ្សេងទៀត គឺនៅជំនាន់នោះ គឺយើងអ្នកនិពន្ធកាសែត គេចាប់អារម្មណ៍តែទៅលើការធ្វើឱ្យមានខ្លឹមសារទូលាយ សម្រាប់មហាជនទូទៅអាចមើលបាន។ ដូច្នេះ ការសរសេរកាសែត គឺជាការសរសេរឱ្យទូលំទូលាយដូចវិទ្យុដែរ។ វាអាចផ្សាយជាចំហ។ តែដូចខ្លឹមសារទង់បដិវត្តនេះ អ្នកនិពន្ធកម្របានជួបប្រទះណាស់ ច្រើនជួបប្រទះតែការណែនាំផ្សេងៗក្នុងការសរសេរទេ ផ្នែកកាសែត។ បើថាឱ្យឃើញស្គាល់ឯកសារហ្នឹងគ្រប់គ្រាន់តែម្តង កម្របានជួបណាស់។

[១៥:១៨:៤៦]

**ស៖** ក្រៅពីមាគ៌ានយោបាយទ្រឹស្តី និងគោលការណ៍មនោគមន៍វិជ្ជានោះ តើទិវាជ័យជម្នះ១៧មេសា តើខួបជ័យជម្នះហ្នឹង តើមានរៀបចំជាឯកសារសរសេរ ឬមួយក៏មានជាឯកសារអ្វីដែរឬទេ?

**ឆ៖** ជាធម្មតា នៅពេលគម្រប់ខួប១៧មេសា តែងតែមានរៀបចំពិធី។ ឯខាងផ្នែកផ្សាយកាសែតអី គឺត្រូវផ្សាយ។ ផ្សាយច្រើនច្បាប់ សម្រាប់បោះឱ្យច្រើន សម្រាប់ផ្សព្វផ្សាយអំពីទិវាជ័យជម្នះ១៧មេសា។

**ស៖** សូមអរគុណលោក។ ថាតើថ្ងៃខួបកំណើតបក្សកុម្មុយនីស្តកម្ពុជា ពីឆ្នាំ១៩៦០ ថាតើមាននៅក្នុងទស្សនាវដ្តីទង់បដិវត្តនោះដែរឬទេ?

[១៥:២០:០៥]

**ឆ៖** ខ្ញុំមិនចាំច្បាស់។ ប៉ុន្តែពេលបើកពិធីខួបនៅស្អាត ដូចមានថ្លែងរបស់ អ៊ំប៉ុល ដែរ ថ្លែងការណ៍ អាចមាននិយាយ ប៉ុន្តែខ្ញុំមិនចាំថា លេខប៉ុន្មានៗទេ ព្រោះសៀវភៅហ្នឹង គេមិនងាយឱ្យខាងមកកាសែតទេ។ បើយើងចង់មើលអី ទាល់តែទៅសុំគេ ព្រោះយើងនៅឆ្ងល់កន្លែងណាៗអីហ្នឹង គឺសុំគេមើលព្រោះយើងអត់មានឯកសារសម្រាប់សរសេរ។

**ស៖** ឥឡូវនេះ ខ្ញុំបន្តទៅនឹងប្រធានបទថ្មីមួយទៀត គឺនិយាយពីឯកសារ E3/380 គឺ ERN ភាសាខ្មែរ គឺមានលេខ 00357200, ភាសាបារាំង គឺមានលេខ 00485433, និងភាសាអង់គ្លេស គឺ

មានលេខ 00365645។ នៅពេលដែលលោកនិយាយ អំពីអ្នកណាជាអ្នកទទួលទស្សនាវដ្ដីទង់បដិវត្ត គឺលោកនិយាយថា មានតែកម្មាភិបាលបក្ស ខាងភូមិភាគ តំបន់ ខាងស្រុក ហើយលោកក៏និយាយថា វាជាឯកសារសម្ងាត់ផងដែរ។ សំណួរទី១ ដែលខ្ញុំចង់សួរគឺថា ហេតុអ្វីបានជាទស្សនាវដ្ដីទង់បដិវត្ត ត្រូវបានបែងចែកតែទៅចំពោះកម្មាភិបាលប៉ុណ្ណោះ?

[១៥:២១:៥៤]

**ឆ៖** តាមខ្ញុំយល់ កម្មាភិបាលត្រូវការចាំបាច់ ព្រោះដឹកនាំគេ។ ដូច្នេះត្រូវយល់អំពីការណែនាំនៅក្នុងខ្លឹមសារទស្សនាវដ្ដីទង់បដិវត្ត ព្រោះទង់បដិវត្តជាមតិណែនាំរបស់បក្ស។

**ស៖** តាមការដឹងរបស់លោក ថាតើវាជាការចាំបាច់ដែរឬទេ ដែលកម្មាភិបាលត្រូវតែអានទស្សនាវដ្ដីទង់បដិវត្ត?

**ឆ៖** តាមទស្សនៈខ្ញុំនៅក្នុងរយៈពេល៣ឆ្នាំក៏ដោយ ក្នុងពេលសង្គ្រាមក៏ដោយ កម្មាភិបាលត្រូវការខ្លឹមសារណែនាំហ្នឹងច្បាស់លាស់ បើមិនអ៊ីចឹងទេ អនុវត្តខុស។

**ស៖** តើកម្មាភិបាលនីមួយៗ គាត់ធ្វើយ៉ាងម៉េចដឹងថា វាជាការចាំបាច់ ឬក៏ជាការសំខាន់ ដែលគាត់ហ្នឹងត្រូវអានទស្សនាវដ្ដីទង់បដិវត្តនោះ?

**ឆ៖** មែនទែននៅក្នុងខ្លឹមសារ ដូចខ្ញុំបានលើកពីខាងដើម តែងតែចុះផ្សាយអំពីសារៈសំខាន់ ការការពារប្រទេស និងការកសាងប្រទេស។ ប៉ុន្តែគ្រាន់ថាអ្នកធម្មតា គេមិនឲ្យដឹង ព្រោះកម្មាភិបាលត្រូវដឹងហើយ យកទៅផ្សព្វផ្សាយបន្តទៅទៀត ហើយតាមមើលត្រូវតែដឹង។

[១៥:២៤:០១]

**ស៖** ដូច្នេះ ពាក់ព័ន្ធទៅនឹងសំណៅចម្លើយរបស់លោក បានន័យថា កម្មាភិបាលគាត់ត្រូវអានខ្លឹមសារ នៃទស្សនាវដ្ដីហ្នឹងតែជាបុគ្គល ឬមួយក៏គាត់អានជាក្រុម។ តើគេជំរុញឲ្យពួកគាត់ហ្នឹងអានម្នាក់ឯង ឬក៏អានជាក្រុម?

**ឆ៖** ខ្ញុំមិនដឹងដែរ ព្រោះអត់ដឹង មិនដឹងជាគាត់យកទៅអនុវត្តជាក្រុម ឬក៏ជាបុគ្គល ប៉ុន្តែតាមមើលតាមគេចែក ចែកជាបុគ្គល។ បុគ្គលហ្នឹងយកទៅផ្សព្វផ្សាយបន្ត ព្រោះនៅកន្លែងខ្ញុំមាន បងឆយ គាត់កម្មាភិបាលជាបក្ខជនអ៊ីចឹង បើចង់មើលទស្សនាវដ្ដីហ្នឹង ទាល់តែទៅសុំគាត់ ហើយបើមានអីដែលទាក់ទងការសរសេរគាត់យកទស្សនាវដ្ដីយកមកអាន សម្រាប់ឲ្យអ្នកនិពន្ធហ្នឹងស្ដាប់បញ្ហាបាន ស្ដាប់បញ្ហាបាន ស្ដាប់ខ្លឹមសារបានដើម្បីយកមកបំប៉ែកសរសេរ។

[១៥:២៥:១៥]

**ស៖** សូមអរគុណ។ ខ្ញុំចង់ឲ្យលោកជួយបន្តិចថា តើគេបោះពុម្ពផ្សាយទស្សនាវដ្ដីទង់បដិវត្តហ្នឹង ប្រហែលជាប៉ុន្មានច្បាប់ដែរ ក្នុងពេលបោះពុម្ពម្ដងៗ?

**ឆ៖** មិនដឹងចំនួនប៉ុន្មានទេ បើខ្ញុំឃើញច្រើន ព្រោះគរជាគីបៗមិនដឹងប៉ុន្មាន។

**ស៖** ប្រធានបទបន្ទាប់ គឺការបែងចែកឯកសារដែលមានលេខ E3/380 ភាសាខ្មែរគឺមានលេខ 00357197, ភាសាបារាំងគឺមានលេខ 00485430 និងភាសាអង់គ្លេសគឺមានលេខ 00365642។ នៅទំព័រនេះ គឺលោកនិយាយថា "ទស្សនាវដ្ដីទង់បដិវត្ត ត្រូវបានបែងចែកនៅទូទាំងប្រទេស"។ សំណួរទី១ តើលោកអាចជម្រាបបានដែរឬទេ ថាតើអ្នកណាជាអ្នកមកទទួលយកនូវទស្សនាវដ្ដីទង់បដិវត្តហ្នឹង មុនពេលដែលគេធ្វើការបែងចែក?

[១៥:២៦:៤៩]

**ឆ៖** ខ្ញុំមិនដឹងថា អ្នកណាមកទទួលទេ ព្រោះឃើញដឹកតាមឡានទៅ ឃើញដាក់ទាំងគីបៗ ហើយគ្រាន់តែដាក់ផ្លាស់ថា ទៅតំបន់ណា ទៅកន្លែងណា គឺសរសេរជារូមៗអត់ដាក់ថា ចំពោះបុគ្គលណាទេ។ ឧបមាថា ទៅ៣០៤ គេសរសេរតែលេខ ៣០៤ហ្នឹងទៅ។ ជួនកាលគេមិនប្រើលេខទេ គេដាក់ថា ទៅបូព៌ាអីចឹងទៅ ដាក់តែបូព៌ាទៅ។ អត់មានជូនចំពោះអ្នកណាៗទេ។

**ស៖** លោក គឹម វុន ខ្ញុំសូមបញ្ជាក់បន្តិចនៅពេលដែលលោកនិយាយថា ផ្សព្វផ្សាយ -- លោកនិយាយអំពីស្រុក តើស្រុក៣០៤ ឬក៏៣០៤ ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ម្ដងទៀតអត់ទាន់ ប្រព័ន្ធ -- លោកនិយាយអត់ទាន់ អត់ចូលប្រព័ន្ធសំឡេងទេអំមិញ។

**លោក គឹម វុន៖**

**ឆ៖** លេខ៣០៤ ហ្នឹងជាលេខភូមិភាគឧត្តរ។

[១៥:២៨:២៤]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** សូមអរគុណ។ ថាតើមេដឹកនាំបក្សបានទទួលនូវទស្សនាវដ្ដីនេះដែរឬទេ?

**លោក គឹម វុន៖**

**ឆ៖** បាទ បើចេញពីគាត់ហើយ ជួនកាលគាត់អាចយកទៅវិញដែរ។

**ស៖** ប្រហែលជាខ្ញុំស្ដាប់សំណួរលោកមិនយល់ តើលោកចង់និយាយថា គេមកទទួលយក ឬយកទៅវិញអ្វីដែលខ្ញុំចង់សួរគឺថា តើមេដឹកនាំបក្សហ្នឹងបានទទួលទស្សនាវដ្ដីហ្នឹងដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់ប្រតិបត្តិការទេ ក្បាលមីក្រូ ឱ្យបង្អង់បន្តិចណ៎ះ!

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំថា បើតាមភូមិភាគតាមតំបន់បាន ហើយអ្នកនៅភ្នំពេញហ្នឹងក៏បានដូចគ្នាដែរ។ ព្រោះក្នុងអង្គភាពខ្ញុំគឺមេខ្ញុំមានហ្នឹងដែរ។ ដូច្នេះអាចមានទាំងអស់គ្នា ឱ្យតែបក្ខជន ឬកម្មាភិបាល។

[១៥:៣០:០១]

**ស៖** ដូច្នេះ ខ្ញុំនិយាយ អាចនិយាយបានថា គេបញ្ជូន ថាតើគេបញ្ជូនហ្នឹង បញ្ជូនទៅទាំងកម្មាភិបាលដែលធ្វើការនៅក្រៅប្រទេសដែរឬក៏អត់ទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកដែលមានការទទួលការតវ៉ាថាកម្មាភិបាលនោះមិនដែលទទួលបាននូវឯកសារទាំងនេះដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកដឹងដោយរបៀបណា ប្រសិន -- ថាតើនោះ គេទទួលនោះ ទទួលឯកសារទង់បដិវត្តនោះដោយរបៀបណា? ហើយថាតើការបញ្ជូនទៅហ្នឹង បញ្ជូនទៅដល់ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។ ខ្ញុំដឹងថា គេដាក់ដឹកទៅទាំងគីបៗ យកទៅ ប៉ុន្តែមិនដឹងថាដល់ ឬមិនដល់យ៉ាងម៉េច អត់ដឹងដែរ។

[១៥:៣១:២៥]

**ស៖** សូមអរគុណលោក គឹម វុន។ ខ្ញុំនៅពេលនេះ សូមចូលសួរទៅដល់ឯកសារជាក់លាក់មួយ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញលោក គឹម វុន ឯកសារចេញពីខាងសហព្រះរាជអាជ្ញា

យើងខ្ញុំសូមបង្ហាញ គឺឯកសារមានបីទំព័រជាភាសាអង់គ្លេស។ ឯកសារ E3/5 គឺទំព័រខាងមុខនៃទស្សនាវដ្តីទង់បដិវត្ត។ ហើយនិងការដកស្រង់មួយចំនួននៅក្នុងឯកសារទង់បដិវត្តនេះ ដែលខ្ញុំនឹងផ្តល់ ERN នាពេលក្រោយ។ ដូច្នេះហើយ លោកប្រធានខ្ញុំសូមអនុញ្ញាតបញ្ជូនឯកសារទាំងអស់នេះ ទៅកាន់លោក គឹម វុន គឺឯកសារលេខ E3/4.5។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៥:៣៣:០៨]

**សួរដោយលោក ឃើត រេយ៍ន័រ៖**

**ស៖** នេះគឺជាទំព័រដំបូងនៃទស្សនាវដ្តីទង់បដិវត្ត លេខ៨ លេខរៀងទី៨ ខែសីហា ឆ្នាំ៧៥។ លោក គឹម វុន ជាអត្ថបទដំបូងនោះ គឺទំព័រដំបូងនៃទស្សនាវដ្តីទង់បដិវត្ត លេខ៨ ចុះខែសីហា ឆ្នាំ៧៨ -- ៧៥ សូមកែតម្រូវ។ ERN គឺខ្មែរ 00063311, បារាំងគឺ 00538951, អង់គ្លេសគឺ 00401476។ យើងមើលឯកសារនេះបន្តិច លោកបាននិយាយប្រាប់យើងខ្ញុំនាពេលមុននោះថា ថាតើទំព័រ លោកបានជម្រាបថា ទំព័រខាងមុខនេះ គឺបានផលិត និងបោះពុម្ពនៅ ក-៧។ តើអ៊ីចឹងទេ លោកបាននិយាយអ៊ីចឹងទេ ក-២៧?

**លោក គឹម វុន៖**

**ឆ៖** មិនដែលបោះទេ នៅ២៧។ បោះនៅ២៥។ ប៉ុន្តែក្របនេះបោះនៅ២៦។

[១៥:៣៤:៤៥]

**ស៖** យើងកំណត់ពេលវេលាមួយសម្រាប់សំណួរនេះ។ លេខចុះខែសីហា ឆ្នាំ៧៥ ដូច្នេះយើងដឹងហើយថា គឺ៤ខែ ក្រោយពីពេលដែលលោកធ្វើការងារនៅក្រសួងនោះ។ នៅពេលដែលយើងមើលទំព័រខាងមុខនេះ យើងឃើញមានទង់ចំនួនប្រាំ នៅខាងលើចំណងជើងនៃឯកសារនេះ។ តើមានអត្ថន័យអ្វីដែលឆ្លុះបញ្ចាំងតាមរយៈទង់ទាំងប្រាំនេះដែរឬទេ? ទង់ទាំងប្រាំនេះបង្ហាញន័យយ៉ាងម៉េចដែរ? តើមានន័យរបស់វាដែរឬទេ?

**ឆ៖** ន័យយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំមិនមែនជាបក្ខជនផង ហើយមិន -- គ្រាន់តែឃើញ

ប៉ុន្តែមិនបានអានអីច្រើន។

**ស៖** លោក គឹម វុន ខ្ញុំសូមសួរបន្តិចថាតើសំឡេងនោះ គឺលោកៗស្រីឮដែរឬទេ? ខ្ញុំហាក់ដូចជាឮផង ចំពោះខ្លួនឯង។ លោក គឹម វុន -- បាទឮហើយ -- ខ្ញុំៗសូមចូលទៅទំព័របន្តដើម្បីពន្យល់ភាគីអង្គជំនុំជម្រះ និងអស់លោក លោកស្រី គឺឯកសារ E3/5 ដដែល។ ERN គឺខ្មែរ 00063324, បារាំង 00538963, អង់គ្លេសគឺ 00401488។ លោក គឹម វុន ចំណងជើងនៅក្បាលទំព័រ សរសេរថា "ជយោ! កងទ័ពបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជាដ៏មហាអស់ស្ចារ្យ"។ ឯកសារគឺចាប់ផ្ដើមសរសេរដូចតទៅ៖ "កាលពីថ្ងៃ២២ កក្កដា ១៩៧៥ ក្នុងឱកាសពិធីចាត់តាំងកងទ័ពបដិវត្តន៍របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ សមមិត្តប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្សបានធ្វើសន្និសីទនយោបាយមួយដ៏សំខាន់។ ជូនតំណាងគ្រប់អង្គភាពនៃកងទ័ពបដិវត្តន៍ប្រមាន៣០០០នាក់របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា"។ នៅពេលនេះ ខ្ញុំសួរថាតើលោកចាំទេ ចាំពិធីហ្នឹងដែលគេរៀបចំនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥?

[១៥:៣៨:១៤]

**ឆ៖** ខ្ញុំបាទ អត់បានចាំផង ហើយអត់ដឹងថាគេរៀបចំនៅណាផង។ ព្រោះជួនការអាចរៀបចំនៅស្តាត ប៉ុន្តែជួនកាលខ្ញុំចេញទៅធ្វើការបាត់ទៅមិនដឹង ហើយក៏មិនដែលបានចូលរួមក្នុងពិធីសំខាន់ៗហ្នឹងផង។

**ស៖** ខ្ញុំចង់សួរខ្លឹមសារនៃឯកសារមួយនេះម្ដង។ នៅពេលនេះ ខ្ញុំគិត -- ខ្ញុំចង់សួរលោកថាតើអ្វីដែលខ្ញុំអាចចេញពីក្នុងនេះ គឺដូចនឹងអ្វីដែលលោកបញ្ជាក់ដែរឬទេ? ឯកសារ E3/5 ដដែល។ ERN គឺខ្មែរ 00063341, បារាំង 00538976, អង់គ្លេសគឺ 00401401 -- 1501។ នៅពេលនេះ គឺខ្ញុំសូមឲ្យបញ្ចាំងទំព័រនេះ ដែលខ្ញុំនឹងអានជាភាសាអង់គ្លេស។

[១៥:៣៩:៣០]

នេះគឺជាការដកស្រង់ចេញពីឯកសារនេះ គឺសរសេរដូចតទៅ។ ខ្ញុំសង្ឃឹមថាលោកមើលក្នុងអានក្នុងប្រអប់ពណ៌ក្រហម។ ខ្ញុំអានជាភាសាអង់គ្លេសឲ្យលោកមើលជាភាសាខ្មែរ។ គឺឯកសារដកស្រង់ដែលមានសម្ដីដូចតទៅ៖ "ឥឡូវយើងដណ្ដើមបានហើយ យើងត្រូវការពារប្រទេស ពីព្រោះខ្មាំងខាងក្រៅនិងខ្មាំងខាងក្នុងវា វាចង់ដណ្ដើមយកទៅវិញ។ ដើម្បីជាចំហជាសង្គ្រាម ដើម្បីជាសតិអារម្មណ៍ ជានយោបាយ ជាសេដ្ឋកិច្ច ជាចារកម្ម ជាចំហ ជាសម្ងាត់គ្រប់បែបយ៉ាង ដើម្បីនឹងចេញជាសង្គ្រាមតទៅ

ទៀត"។ នេះគឺជាការដកស្រង់សម្ដី ដែលនិយាយអំពីការការពារប្រទេស។ ដូចទៅនឹងអ្វីដែលលោកបានពន្យល់ប្រាប់ជូនតុលាការកាលពីព្រឹកមិញនេះដែរឬទេ?

[១៥:៤០:៤៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើខ្ញុំយល់ការបញ្ជាក់របស់លោកប្រធានកាលពីថ្ងៃសុក្រនោះ សហព្រះរាជអាជ្ញាគឺត្រូវដំបូង សួរទៅកាន់សាក្សី ថាតើសាក្សីបានធ្លាប់ឃើញឯកសារនេះដែរឬទេមុនពេលដែលអានផ្នែកណាមួយនៃឯកសារនេះ? ប្រសិនបើមិនធ្លាប់ឃើញនោះទេ គឺយើងអាចនឹងដកឯកសារនេះចេញ ប្រសិនបើយើងអានអ៊ីចឹង វាអាចឲ្យសាក្សីច្រឡំ។ ដូច្នេះ យើងខ្ញុំមិនឯកភាពជាមួយនឹងអ្វីដែលធ្វើឡើងនេះទេ។ នេះជាអ្វីដែលយើងយល់ទៅតាមវិធាន ហើយសហព្រះរាជអាជ្ញាក៏ត្រូវគោរពតាមវិធាននេះផងដែរ។

[១៥:៤១:៣៧]

**លោក ឃីត វេយ៍ន័រ៖**

វិធានដែលបានលើកឡើងនឹងណែនាំដោយចៅក្រម ឡាវែន៍ កាលពីសប្ដាហ៍មុន គឺខ្ញុំយល់ដូចតទៅ៖ "ប្រសិនបើសាក្សីមិនឃើញ ធ្លាប់ឃើញឯកសារនេះពីមុននោះទេ យើងនៅតែអាចសួរសំណួរដដែល។ យើងអាចដកស្រង់សម្ដីឯកសារនេះ"។

លោក ប៉ោ គាត់បានលើកឡើងហើយជាការរៀបរាប់នៅក្នុងកថាខណ្ឌនៅពេលដែលគាត់សួរ។ ដូច្នេះខ្ញុំសូមធ្វើការសង្កេតដូចតទៅ៖ "ប្រសិនបើយើងដកឯកសារជាលាយលក្ខណ៍អក្សរនេះ គាត់ស្ដាប់តែអ្វីដែលខ្ញុំអាន ខ្លឹមសារនៅក្នុងឯកសារ គាត់មិនអាចតាមដាន តាមទាន់ទៅលើចំណុចនោះនោះទេ។ ខ្ញុំនឹងធ្វើការអនុវត្តតាមវិធាននេះឲ្យជាក់លាក់"។

[១៥:៤២:៤០]

ដូច្នេះ ប្រសិនបើមានភាពខុសគ្នារវាង -- គឺមានភាពខុសគ្នារវាងសាក្សីដែលមានឯកសារនៅចំពោះមុខ និងស្ដាប់។ ហើយប្រសិនបើមានភាពខុសគ្នាមែននោះ គឺថាខ្ញុំនឹងធ្វើតែអានតែប៉ុណ្ណោះ ចំពោះ

តែឯកសារខ្លឹមសារនេះ។ ដូច្នេះខ្ញុំស្នើសុំថា ប្រសិនបើសាក្សីគាត់បានដឹងអំពីខ្លឹមសារនៃឯកសារនេះ ដូចដែលមាននៅក្នុងទស្សនាវដ្ដីទង់បដិវត្ត ដូច្នេះហើយដូចតែការពន្យល់របស់ចៅក្រម ឡាវែន៍ ប្រសិនបើសំណួរនោះវាពាក់ព័ន្ធទៅនឹងខ្លឹមសារ សំណួរនោះគឺនៅតែអាចសួរបាននៅចំពោះមុខតុលាការ។

ចំពោះខ្ញុំ ទោះបីឯកសារនេះដកចេញ ឬក៏មិនដកចេញក៏ដោយ សាក្សីខ្ញុំជឿថា គឺគាត់អាចជួយយើងបាន ប្រសិនបើគាត់មានឯកសារនៅចំពោះមុខគាត់ ដែលឯកសារនេះជាឯកសារដែលភស្តុតាងដែលយើងទទួលយករួចមកហើយ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ យើងខ្ញុំទុកឆន្ទានុសិទ្ធិនេះឲ្យអង្គជំនុំជម្រះសម្រេច។

[១៥:៤៣:៤៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៨:១៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្ដល់ -- ប្រគល់ភារកិច្ចជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីឆ្លើយតបទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមព្យាយាមរំឭកនូវអ្វីដែលខ្ញុំបាន -- ដែលបាននិយាយនៅក្នុងកិច្ចប្រជុំសវនាការ គឺថាក្នុងករណីឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ឯកសារនោះ យើងអាចយកខ្លឹមសារមកចោទបានសម្រាប់ជាមូលដ្ឋាន ដោយភាគីទាំងអស់។ ហើយឯកសារនោះ អាចដាក់ជូនសាក្សីបាន ហើយប្រសិនបើ -- បើសិនជាលោកប្រធានយល់ឃើញថា ឯកសារនោះ អាចជះឥទ្ធិពលទៅលើចម្លើយសាក្សីនោះ គឺយើងត្រូវដកឯកសារនោះចេញពីមុខសាក្សី។ ក៏ប៉ុន្តែប្រសិនសាក្សីដឹង ស្គាល់ឯកសារនេះ ហើយក៏ធ្លាប់ឃើញ ធ្លាប់អីអីចឹង យើងមិនចាំបាច់ធ្វើការដកឯកសារនោះចេញពីសាក្សីនោះទេ ឬក៏មិនចាំបាច់ដកចេញពីអេក្រង់ទូរទស្សន៍នោះទេ។ ខ្ញុំគិតថាចម្លើយនេះ ឆ្លើយតបទៅនឹងការជំទាស់ហើយ។ ហើយដូច្នេះការជំទាស់នេះ គ្មានប្រសិទ្ធភាពនោះទេ។

[១៥:៥០:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរ!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក គឹម វុន ខ្ញុំអំមិញ -- អម្បាញ់មិញនេះ គឺអានការដកស្រង់នៃចេញពីទស្សនាវដ្តីទង់បដិវត្ត ដែលខ្លឹមសារនោះបង្ហាញអំពីការការពារប្រទេស។ ខ្ញុំចង់សួរលោកថាតើការដកស្រង់សម្តីនៅក្នុងទស្សនាវដ្តីទង់បដិវត្តនេះ គឺដូចនឹងអ្វីដែលលោកនិយាយអំពីខ្លឹមសារដែលគេបង្រៀនអំពីការពារប្រទេសនេះដែរឬទេ?

**លោក គឹម វុន៖**

**ឆ៖** រហូតដល់ពេលនេះ ខ្ញុំមិនចាំអស់ដែរ ប៉ុន្តែបើឲ្យខ្ញុំឆ្លើយក្នុងឯកសារនេះគឺ ខ្ញុំអត់មានសមត្ថភាពឆ្លើយច្រើនទេ។ ព្រោះនៅក្នុងហ្នឹង ដូចខ្ញុំបានជម្រាបពីខាងដើម ខ្ញុំអ្នកកាសែត ហើយដល់និយាយរឿងផ្ទៃក្នុងបក្ស និយាយរឿងទង់បដិវត្តមកទាំងដុល ខ្ញុំអត់ដឹងទេ។ ព្រោះមេខ្ញុំច្រើនតែយកទង់បដិវត្ត គេស្រង់តែចំណុចណាយកមកផ្សព្វផ្សាយ ដើម្បីយើងសរសេរ។ ដូច្នេះ សមត្ថភាពខ្ញុំគឺឆ្លើយជាគម្រោង ជាគោលនយោបាយ ឬជាផែនការទាំងដុលតែម្តង ខ្ញុំឆ្លើយអត់បានទេ ព្រោះខ្ញុំវាអត់យល់អីជ្រាលជ្រៅ ព្រោះខ្ញុំអ្នកកាសែត វាធ្វើការតែរឿងទូលាយទេ។

[១៥:៥១:៤៥]

**ស៖** លោក គឹម វុន ខ្ញុំសូមសួរបញ្ជាក់។ លោកបានឆ្លើយនៅក្នុងសក្ខីកម្មរបស់លោកថ្ងៃនេះរួចមកហើយ លោកបានឆ្លើយថា៖ "ខ្លឹមសារនៅក្នុងទស្សនាវដ្តីទង់បដិវត្ត រួមមានលើកឡើងអំពីនយោបាយ មនោគមន៍វិជ្ជា និងទ្រឹស្តី"។ ខ្ញុំមិនសួរថាតើលោកធ្លាប់ឃើញ ចំណុចដែលខ្ញុំអានអម្បាញ់មិញនៅក្នុងទស្សនាវដ្តីទង់បដិវត្តនោះទេ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់សួរលោកនោះគឺថា តើពាក្យថា "យើងត្រូវការពារប្រទេស" គឺជាសារនយោបាយមួយដែលលោកធ្លាប់ឃើញ តើមែនដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ទាំងរៀនទៀត ហើយធ្លាប់យកមកសរសេរកាសែត។ ធម្មតា យើងត្រូវពិភាក្សាគ្នាព្រោះកាសែតត្រូវសរសេរឲ្យទូលាយ សម្រាប់មនុស្សទូទៅ គឺមិនមែនសម្រាប់ៗជាការសម្ងាត់នោះទេ។ ព្រោះនៅក្នុងឯកសារទាំងដុលក្នុងទង់បដិវត្តគេច្រើនតែយកទៅរៀនសូត្រ នៅក្នុងកម្មាភិបាលទូទាំងប្រទេសអីចឹង។ អីចឹង ដូចខ្ញុំបានជម្រាបលោកពីខាងដើមហើយថា បើសួរនៅលើឯកសារជាខ្លឹមសារទាំងដុលខ្ញុំមិនដឹងទេ។ ប៉ុន្តែខ្ញុំដឹងថា ត្រឹមការពារ កសាងប្រទេសហ្នឹង គឺការពារមុនការកសាង ដឹងតែខ្លឹមសារអីចឹង។ ប៉ុន្តែបើនិយាយខ្លឹមសារលម្អិត ចូលកាន់តែជ្រៅនៅក្នុងបក្សនោះ ខ្ញុំឃើញថាឯកសារទាំងនេះវានិយាយលម្អិតទៅលើខ្លឹមសារទាក់ទងនឹងបក្ស។ ហើយដូចខ្ញុំជម្រាបហើយ ខ្ញុំមិនដែលចូលបក្សផង

ខ្ញុំដឹងតែត្រឹមសម្ព័ន្ធយុវកក។ ដូច្នេះសម្ព័ន្ធយុវកកគឺ បើនិយាយរឿងទង់បដិវត្តហ្នឹង គេបើក្រៅពីហ្នឹងនិពន្ធហ្នឹងក៏មិនងាយបានដឹងទៀត។ ខ្ញុំដឹងតែសម្រាយ ដែលចូលខ្លឹមសារធំៗអ៊ីចឹងពិបាក ប៉ុន្តែខ្ញុំយល់ស្របថា វាអាចចូលក្នុងពាក្យដើមដែលខ្ញុំនិយាយហើយ។ ប៉ុន្តែបើលម្អិត គឺខ្ញុំមិនដឹងដែរ ព្រោះមែនទែនឯកសារនេះ ជារូបភាពខ្ញុំបានឃើញ ប៉ុន្តែខ្លឹមសារពិត ខ្ញុំមិនបានឃើញទេ ព្រោះខ្ញុំជាប់រវល់ការងារផ្សេងដែរ។ ការចាត់តាំងវាអ៊ីចឹង។

[១៥:៥៤:៣១]

**ស៖** សំណួរខាងក្រោយនេះ គឺមិនកម្រិតតែទស្សនាវដ្ដីបដិវត្តនោះទេ ក៏ប៉ុន្តែចន្លោះឆ្នាំ៧៥ ដល់ ៧៩ នោះ តើចន្លោះឆ្នាំហ្នឹង លោកមានចាំទេ តើគេមានបាននិយាយ -- លោកមានចាំថា គេមានធ្លាប់និយាយអំពីបញ្ហាខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅដែរឬទេ?

**ឆ៖** ធ្លាប់តើ ធ្លាប់ឮតើ។ ប៉ុន្តែគេមិននិយាយលម្អិតអ៊ីចឹងទេ គេនិយាយពីរឿងខ្មាំងយួន ពីរឿង សេ.អ៊ី.អា, កា.ហ្សេ.បេ ប៉ុន្តែដល់លម្អិតទាំងអស់នេះ ខ្ញុំមិនសូវបានដែរ។ ព្រោះបទឧទ្ទេសនាមនីមួយៗក្នុងការណ៍នេះ ក៏គេមិនចែកជាឯកសារទេ គឺគេឲ្យយើងកត់ ការទទួលការងារក៏ដោយ ការរៀនសូត្រអីក៏ដោយគឺយើងមានសៀវភៅ យើងមានប៊ិក គឺយើងកត់តាមបទឧទ្ទេសនាមនុំងទៅ ហើយបើដូចអ្នកកាសែតអ៊ីចឹងចេះធ្វើកំណត់ហេតុ ឬក៏ចេះវិជ្ជា *ទីណូតក្រាហ្វី* អ៊ីចឹង យើងអាចសរសេរកាត់បានយកមកប្រើការបាន។

**ស៖** សូមអរគុណច្រើនលោក គឹម វុន។ ខ្ញុំសូមចូលទៅដល់ឯកសារមួយទៀត។ ឯកសារ E3/3 180(ស៊ីក)។ ERN គឺខ្មែរ 00357202, បារាំង 00485434 នេះគឺជាចម្លើយរបស់លោកផ្តល់ជូនចៅក្រមស៊ើបអង្កេត។ ខ្ញុំនឹងអានការដកស្រង់ចេញពីឯកសារនេះ ហើយបន្ទាប់មកបង្ហាញលោក។ លោកនៅក្នុងឯកសារនេះនិយាយអំពីសម្តេច សីហនុ។ "សម្តេច សីហនុ គឺជា -- ជាដំបូង -- មុនដំបូង សម្តេចសីហនុ ជាប្រធានរដ្ឋ តែក្រោយមកសម្តេច សីហនុ បានផ្ទេរតំណែងនោះឲ្យទៅ ខៀវ សំផន។ ខ្ញុំបានឃើញឯកសារនោះ នៅកន្លែងរោងពុម្ពដែលខ្ញុំធ្វើការ ហើយខ្ញុំបានឃើញឯកសារនោះជាភាសាបារាំង ជាភាសាអង់គ្លេស"។

[១៥:៥៧:០៧]

**លោក ឃីត ជេយ៍ន័រ៖**

លោកប្រធាន នៅពេលនេះ ខ្ញុំសូមផ្តល់ជូនឯកសារពាក់ព័ន្ធមួយទៅដល់លោក គឹម វុន សូម

អនុញ្ញាតលោកប្រធាន។ ខណៈពេលដែលផ្តល់ឯកសារនេះ ជូនទៅដល់សាក្សី ខ្ញុំសូមជម្រាបអង្គសវនាការ និងភាគីថា ឯកសារនេះគឺពាក់ព័ន្ធទៅនឹងឯកសារនៅក្នុងកិច្ចប្រជុំសម័យពេញអង្គលើទី១ នៅក្នុងសភាតំណាងប្រជាជនកម្ពុជា។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក គឹម វុន ខ្ញុំនឹងឲ្យលោកមើលផ្នែកនៅក្នុងឯកសារនេះ បន្ទាប់មកខ្ញុំនឹងសួរលោកតើលោកធ្លាប់ឃើញឯកសារនេះដែរឬទេ? ឬក៏ឯកសារនេះ ឲ្យលោកនឹកឃើញដែរឬទេ? ឯកសារ E3/262 ប្រសិនបើលោកមើលឯកសារទំព័រដំបូង គឺនិយាយអំពីសេចក្តីប្រកាសព័ត៌មានថ្ងៃចេញនោះ គឺថា ១៤ មេសា ឆ្នាំ១៩៧៦ ទំព័រនេះនៅខាងក្រោមបានបង្ហាញថា "ការិយាល័យគណៈបេសកម្មនៃកម្ពុជាប្រជាធិបតេយ្យប្រចាំនៅបារាំង"។

[១៥:៥៨:៤៣]

ទំព័របន្ទាប់ទៀត ខ្មែរនោះ គឺថា 00622986, បារាំង 00004706, អង់គ្លេស 00528389 គឺសេចក្តីប្រកាសព័ត៌មានដដែល ថ្ងៃ១៤ ខែមេសា ឆ្នាំ៧៦។ ជួរដំបូងនៃក្នុងអត្ថបទនេះ គឺចែង និងសរសេរដូចទៅ ខ្ញុំសូមដកស្រង់សម្តី៖ "ក្រោយពីការបោះឆ្នោតជ្រើសតាំងសមាជិកសភាតំណាងប្រជាជនកម្ពុជានៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ប្រកបដោយជោគជ័យ ហើយសភាតំណាងប្រជាជនកម្ពុជាបានបើកកិច្ចប្រជុំសន្និបាតពេញអង្គលើកទី១ នីតិកាលទី១ របស់ខ្លួន"។ បន្ទាប់មកទំព័រខ្មែរ 00622989, បារាំង 00004708, អង់គ្លេសគឺ 00528391 គឺខ្ញុំសូមឲ្យៗជួយពិនិត្យមើលផង ថាតើលោកសាក្សី គឹម វុន នោះមានបានបើកត្រង់ទំព័រ 00622986 ដែរឬទេ។

ចំណងជើងនៅក្នុងឯកសារនេះ សរសេរជាអក្សរដិតធំ "អំពីការពិនិត្យ ការវិនិច្ឆ័យ និងសម្រេចលើការសុំចូលនិវត្តន៍របស់សម្តេច នរោត្តម សីហនុ ដែលបានធ្វើឡើងតាមសេចក្តីថ្លែងការណ៍របស់សម្តេច ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ និងលើសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលចុះថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៦"។ នៅក្នុងខ្លឹមសារឯកសារនេះ បានសរសេរថា "យល់ស្របតាមសំណូមពរសុំចូលនិវត្តន៍របស់សម្តេច នរោត្តម សីហនុ"។ ទំព័របន្ទាប់ទៀត ខ្មែរ 006229--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមជំទាស់ចំពោះរបៀបតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញានេះ។ ដោយហេតុថា តំណាងសហព្រះរាជអាជ្ញាបានចូលជ្រៅទៅលើខ្លឹមសារយ៉ាងច្រើន ហើយដោយមិនទាន់បានឲ្យសាក្សីបញ្ជាក់ថា តើលោកសាក្សីធ្លាប់បានឃើញឯកសារនេះពីមុនមក ឬអត់នោះទេ?

បាទ នេះខ្ញុំបាទយល់ឃើញថាការអនុវត្តរបៀបនេះ គឺមិនត្រឹមត្រូវទេ។ សូមអរគុណលោកប្រធាន។

[១៦:០១:៥៥]

**លោក ឃីត រេយ៍នរ៍៖**

លោកប្រធាន យើងត្រូវតែយល់ឲ្យច្បាស់ទាំងអស់គ្នា។ ខ្ញុំស្នើនៅពេលនេះតែម្តងថា ឲ្យមេធាវីការពារក្តីយល់អំពីវិធានដែលយើងអនុវត្ត។ តាមខ្ញុំយល់ទៅលើសេចក្តីសម្រេចដីកាបង្គាប់របស់អង្គជំនុំជម្រះ ខ្ញុំសូមសួរសំណួរដែលមេធាវីការពារក្តីក៏ចង់សួរ។ ដូច្នេះ វាមិនចាំបាច់ឲ្យសួរសំណួរដំបូងថាធ្លាប់ឃើញឯកសារនេះពីមុនដែរឬទេ? ហើយថាតើសាក្សីនោះធ្លាប់ឃើញឯកសារនេះដែរឬទេ? ហើយវាពាក់ព័ន្ធដែរឬទេ?

ដូច្នេះហើយឲ្យយើងសួរថា បង្កើត -- ឲ្យយើងបង្កើតមូលដ្ឋានសម្រាប់ឯកសារនេះពីសាក្សីដើម្បីឲ្យយើងអាចយោងទៅលើឯកសារនេះបាន។ ដូច្នេះហើយ វាមិនចាំបាច់ តាមអ្វីដែលខ្ញុំយល់នោះវិធាន តាមវិធាននោះគឺថា យើងមិនចាំបាច់សួរទៅលើសាក្សីថា ធ្លាប់អានឯកសារនេះ ឬក៏ធ្លាប់ឃើញនោះ ដែរឬទេ។ ចៅក្រម ឡាវែន៍ បានបញ្ជាក់ហើយថា យើងនៅតែអាចសួរសំណួរដដែល ទោះបីជាយើងមិនសួរសំណួរដូចដែលបានបញ្ជាក់នេះក៏ដោយ។

មេធាវីទាំងអស់ និងភាគី គួរតែយល់ទៅលើចំណុចនេះ។

[១៦:០៣:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៥:៥២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់មិនមានមូលដ្ឋានសមស្របទេ។ សេចក្តី

ជំទាស់មិនមានប្រសិទ្ធភាព។ សាក្សីត្រូវ -- លោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរ ហើយសាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា។

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំសូមឲ្យផ្នែកមន្ត្រីតុលាការជួយពិនិត្យមើលសាក្សី តើគាត់បើកទំព័រចំដែរឬទេ ជាភាសាខ្មែរ?

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ឯកសារដែលខ្ញុំចង់លើកនេះ គឺថា ERN 00622990, បារាំង 0004709, អង់គ្លេស 00528392។ ឯកសារនេះ គឺមានគូសប្រអប់ពណ៌ក្រហមចំពោះលោក គឹម វុន គឺការតែងតាំងគណៈប្រធានរដ្ឋសម្រាប់កម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីបានពិភាក្សាយ៉ាងហ្មត់ចត់ និងល្អិតល្អន់លើលក្ខណៈសម្បត្តិផ្សេងៗគ្រប់ទិដ្ឋភាពមក។ សភាបានអនុម័តជ្រើសតាំងគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលមានសមាសភាពដូចតទៅ៖ ១) មិត្ត ខៀវ សំផន ប្រធាន។ យើងឈប់ត្រង់នេះបន្តិច។ ឯកសារនេះគឺបានលើកឡើងថា “សម្តេច នរោត្តម សីហនុ បានចូលនិវត្តន៍បន្ទាប់មក គឺគេតែងតាំង ខៀវ សំផន ជាគណៈប្រធានរដ្ឋ”។

[១៦:០៧:៥០]

តើឯកសារនេះគឺជាឯកសារមួយដែលលោកធ្លាប់ឃើញដែរឬទេ? ប្រហែលជាឯកសារជាភាសាបារាំង ដែលលោកធ្លាប់ឃើញ។ តើលោកធ្លាប់ឃើញឯកសារនេះនៅរោងពុម្ពដែរឬទេ? ដែលនិយាយថាមុនដំបូងនោះសម្តេច សីហនុ ជាគណៈប្រធានរដ្ឋ ក្រោយមកបានផ្ទេរមុខដំណែងនេះទៅឲ្យលោក ខៀវ សំផន។ តើលោកធ្លាប់ឃើញ ធ្លាប់ដឹងទេ?

**លោក គឹម វុន៖**

**ឆ៖** ខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ តាមពិតឯកសារនេះជាភាសាខ្មែរ។ កាលដែលខ្ញុំឃើញបោះនៅ២៧ ខ្ញុំគ្រាន់តែឃើញទេ ដឹងថាខ្លឹមសារជារួម ដឹងថាសម្តេចឪនឹងលាពីតំណែងហើយ។ ហើយក្នុងនឹងក៏ដឹងថាលោក ខៀវ សំផន នឹងឡើងទៅជាប្រធានគណៈប្រធានរដ្ឋ។ ហើយឲ្យខ្ញុំចាប់អារម្មណ៍ជ្រៅថាពីរឿងកែប្រែរចនាសម្ព័ន្ធយ៉ាងម៉េច នៅសម័យនោះ ខ្ញុំអត់បានចាប់អារម្មណ៍ទេ គឺថាគ្រាន់តែដឹងជាវិញ្ញាណទេ បើឲ្យគិតវិចារណញ្ញាណថាយ៉ាងណាៗគឺខ្ញុំមិនដឹង។ ប៉ុន្តែឯកសារជាភាសាខ្មែរនេះខ្ញុំអត់ដែលឃើញ។ ហើយនៅក្នុងភាសាដែលឃើញហ្នឹង តាមខ្ញុំចាំដូចជាភាសាបារាំង ឬក៏ភាសាអង់គ្លេស។ ប៉ុន្តែដល់យើងមិនសូវចាប់អារម្មណ៍អីចឹងទៅ យើងមិនឲ្យតម្លៃថា ឯកសារហ្នឹងយ៉ាងម៉េចៗទេ ព្រោះនឹក

យើញគ្រាន់ថាសម្ដេចឪសុំលាឈប់ហើយ។ គ្រាន់ដឹងប៉ុណ្ណឹង។ ហើយការប្រកាសចេញអីៗ ដោយការងារខ្ញុំច្រើនអ៊ីចឹង ខ្ញុំមិនបានចាប់អារម្មណ៍ប៉ុន្មាន ព្រោះចាប់អារម្មណ៍តែការងារផ្ទាល់ខ្លួន។ ព្រោះដល់ទៅគិតថ្នាក់ដឹកនាំផ្សេងៗ ជួនកាលផ្ទៃក្នុងមិនសូវបានផ្សាយទេ ចាំតែផ្សាយតាមវិទ្យុ។ បើបានស្ដាប់វិទ្យុដឹង។ ហើយឯកសារជាភាសាខ្មែរនេះ ខ្ញុំមិនដែលឃើញទេ ហើយក៏មិនដឹងលម្អិតអំពីរចនាសម្ព័ន្ធថ្មីដែលត្រូវតែងតាំងថ្មីអត់ អត់ដឹង។

[១៦:១០:១៣]

**លោក ឃីត រេយ៉ន័រ៖**

លោក គឹម វុន គឺខ្ញុំសូមអរគុណច្រើន។ លោកប្រធាននៅពេលនេះម៉ោងបួនដប់នាទីហើយ ដូច្នេះហើយតើវាជាពេលសមរម្យសម្រាប់យើងសម្រាកដែរឬទេ? ហើយប្រសិនបើដល់ពេលសម្រាកហើយនោះ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គជំនុំជម្រះ ដែលបានផ្ដល់ការអនុញ្ញាតឱ្យខ្ញុំតាំងសំណួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន អរគុណសាក្សី។ ឥឡូវនេះដល់ពេលត្រូវសម្រាកហើយ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២២ ខែសីហា ឆ្នាំ ២០១២ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ គឺនឹងបន្តស្ដាប់សក្ខីកម្មសាក្សី គឹម វុន ដែលនឹងបន្តសួរដេញដោលដោយក្រុមសហព្រះរាជអាជ្ញា និងមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលវេលាដំបូងនៃព្រឹកស្អែក ហើយនិងពេលវេលាបន្ទាប់គឺនឹងបន្តការតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្ដី។ សូមភាគី និងសាធារណជនជ្រាប។

[១៦:១១:២៣]

លោក គឹម វុន ការស្ដាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះត្រូវបន្តស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់មក

កាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១២ នាទី)*